ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ



ក្រសួងអភិវឌ្ឍន៍ជនបទ

ផែនការយុទ្ធសាស្ត្រ
ស្តីពី
ការធ្វើពិពិធកម្មសេដ្ឋកិច្ចក្រួសារនៅតំបន់ជនបទ
ឆ្នាំ២០២៦-២០៣៣

ព.ស. ២៥៧០

គ.ស. ២០២៦

មាតិកា

បុព្វកថា i
១. សេចក្តីផ្តើម ១
២. ចក្ខុវិស័យ ២
៣. បេសកកម្ម ២
៤.តោលបំណងនិងតោលដៅ ៣
៤.១. តោលបំណង ៣
៤.២. តោលដៅ ៣
៥. ក្របខ័ណ្ឌយុទ្ធសាស្ត្រ ៣
៥.១. ការវិភាគជាយុទ្ធសាស្ត្រ ៤
៥.២. ទិសដៅយុទ្ធសាស្ត្រ ៨
៥.៣. យុទ្ធសាស្ត្រ ៩
៦. សកម្មភាពការងារ ១៣
៦.១. គោលការណ៍អនុវត្ត ១៣
៦.២. វិធីសាស្ត្រអនុវត្ត ១៤
៦.៣. បរិយាកាសគាំទ្រការអនុវត្ត ១៥
៦.៤. សកម្មភាពអាទិភាព ១៦
៧. ធនធានហិរញ្ញវត្ថុ ១៨
៧.១. តម្រូវការធនធានហិរញ្ញវត្ថុ ១៨
៧.២. ប្រភពហិរញ្ញប្បទាន ១៩
៧.៣. ការគ្រប់គ្រងនិងប្រើប្រាស់ធនធានហិរញ្ញវត្ថុ ១៩
៨. ការតាមដានត្រួតពិនិត្យ និងវាយតម្លៃ ២០
៨.១. ក្របខ័ណ្ឌលទ្ធផលនិងសូចនាករ ២១
៨.២. យន្តការ និងការទទួលខុសត្រូវ ២១
៨.៣. ការប្រើប្រាស់លទ្ធផលនៃការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ២២
៩. សេចក្តីសន្និដ្ឋាន ២២
បរិសិដ្ឋ ២៣
បរិសិដ្ឋទី១. ពាក្យគន្លឹះសំខាន់ៗនៃផែនការយុទ្ធសាស្ត្រ ២៣
បរិសិដ្ឋទី២. ពាក្យបច្ចេកទេសគាំទ្រការអនុវត្ត និងការតាមដានវាយតម្លៃ ២៥
បរិសិដ្ឋទី៣. ម៉ាទ្រីសបង្ហាញពីសកម្មភាពអាទិភាព និងលទ្ធផលរំពឹងទុក ២៧
បរិសិដ្ឋទី៤. ផែនការអនុវត្តសកម្មភាព ឆ្នាំ២០២៦-២០៣៣ ..... ៣១
បរិសិដ្ឋទី៥. តម្រូវការធនធានហិរញ្ញវត្ថុ និងប្រភពហិរញ្ញប្បទាន ៣៤
បរិសិដ្ឋទី៦. ក្របខណ្ឌលទ្ធផល និងសូចនាករ ៣៥
បរិសិដ្ឋទី៧. យន្តការអនុវត្ត និងការទទួលខុសត្រូវ ៣៧
បរិសិដ្ឋទី៨: ក្របខណ្ឌតាមដាន ត្រួតពិនិត្យ វាយតម្លៃ និងរាយការណ៍ ៤០

បុព្វកថា

ព្រះរាជាណាចក្រកម្ពុជាទទួលបានសន្តិភាព និងការឯកភាពជាតិពេញលេញ ព្រមទាំងមានការអភិវឌ្ឍរីកចម្រើនលើគ្រប់វិស័យ និងបានធ្វើសមាហរណកម្មចូលក្នុងសហគមន៍អន្តរជាតិប្រកបដោយជោគជ័យ ហើយកិត្យានុភាពជាតិត្រូវបានលើកស្ទួយខ្ពស់ត្រដែតលើឆាកអន្តរជាតិគួរជាទីមោទនៈ ក្រោមការដឹកនាំដ៏ឈ្លាសវៃ និងប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** តាមរយៈការអនុវត្តនយោបាយឈ្នះ-ឈ្នះ យុទ្ធសាស្ត្រត្រីកោណ និងយុទ្ធសាស្ត្រចតុកោណទាំងបួនដំណាក់កាលជាបន្តបន្ទាប់។ សមិទ្ធផលទាំងនេះបានបង្កើតមូលដ្ឋានគ្រឹះដ៏រឹងមាំសម្រាប់ការបន្តអភិវឌ្ឍប្រទេសជាតិ និងការលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជនទាំងនៅតំបន់ទីក្រុង ទីប្រជុំជន និងតំបន់ជនបទ ដោយបានរួមចំណែកយ៉ាងសំខាន់ក្នុងការកែលម្អលក្ខខណ្ឌនៃការរស់នៅ ការពង្រីកឱកាសសេដ្ឋកិច្ច និងការកាត់បន្ថយគម្លាតអភិវឌ្ឍន៍រវាងតំបន់ទីក្រុង និងជនបទ។

រាជរដ្ឋាភិបាលកម្ពុជា នីតិកាលទី៧ នៃរដ្ឋសភា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត និងភាពស្វាហាប់របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានដាក់ចេញនូវ "**យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាល ទី១**" ក្រោមបាវចនា "**កំណើន ការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព**" ដោយកំណត់អាទិភាពគន្លឹះចំនួន៥ គឺ **មនុស្ស ផ្លូវ ទឹក ភ្លើង និងបច្ចេកវិទ្យា(ឌីជីថល)** សំដៅកសាងមូលដ្ឋានគ្រឹះឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជាក្លាយជាប្រទេសមានចំណូលខ្ពស់នៅ ឆ្នាំ២០៥០។ ក្នុងក្របខណ្ឌនេះ ការអភិវឌ្ឍធនធានមនុស្ស ការបង្កើតការងារ ការលើកកម្ពស់សហគ្រិនភាព និងការជំរុញនវានុវត្តន៍ គឺជាកត្តាសំខាន់សម្រាប់លើកកម្ពស់ផលិតភាព ការប្រកួតប្រជែង និងកំណើនសេដ្ឋកិច្ចប្រកបដោយបរិយាបន្ន និងចីរភាព។

ស្របតាមយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ រាជរដ្ឋាភិបាលបានដាក់ចេញ "**គោលនយោបាយជាតិស្តីពីការអភិវឌ្ឍជនបទ ឆ្នាំ២០២៥-២០៣៥**" ដែលមានចក្ខុវិស័យ "**កសាងសង្គមជនបទកម្ពុជាឱ្យមានវិបុលភាពប្រកបដោយបរិយាបន្ន សមធម៌ និងចីរភាព**"។ ក្នុងចំណោមគោលដៅសំខាន់ៗនៃគោលនយោបាយជាតិនេះ ការជំរុញឱ្យប្រជាជននៅតំបន់ជនបទមានកំណើនប្រាក់ចំណូលប្រកបដោយចីរភាព គឺជាអាទិភាពមួយដែលទាមទារឱ្យមានការពង្រឹងមូលដ្ឋានសេដ្ឋកិច្ចគ្រួសារ ការបង្កើតនិងអភិវឌ្ឍមុខរបរការប្រើប្រាស់សក្តានុពលនិងធនធាននៅមូលដ្ឋាន ព្រមទាំងការបង្កើនឱកាសការងារ និងប្រភពចំណូលរបស់ប្រជាជននៅតំបន់ជនបទ។

ទោះបីសេដ្ឋកិច្ចនៅតំបន់ជនបទមានការរីកចម្រើនជាបន្តបន្ទាប់ក៏ដោយ ក៏គ្រួសារមួយចំនួននៅតែពឹងផ្អែកលើសកម្មភាពកសិកម្មតាមរដូវកាល។ ជាមួយគ្នានេះ ការកែច្នៃផលិតផល ការបង្កើនតម្លៃបន្ថែម ការទទួលបានឱកាសទីផ្សារ ជំនាញសហគ្រិនភាព ជំនាញបច្ចេកទេស ការប្រើប្រាស់នវានុវត្តន៍ និងបច្ចេកវិទ្យាសមស្របនៅមានកម្រិតសម្រាប់គ្រួសារនៅតំបន់ជនបទមួយចំនួន។

ដើម្បីឆ្លើយតបនឹងតម្រូវការ និងបញ្ហាប្រឈមខាងលើ ព្រមទាំងរួមចំណែកអនុវត្តគោលនយោបាយជាតិស្តីពីការអភិវឌ្ឍជនបទ ឆ្នាំ២០២៥-២០៣៥ ក្រសួងអភិវឌ្ឍន៍ជនបទបានរៀបចំ "**ផែនការយុទ្ធសាស្ត្រស្តីពីការធ្វើពិពិធកម្មសេដ្ឋកិច្ចគ្រួសារនៅតំបន់ជនបទ ឆ្នាំ២០២៦-២០៣៣**" គឺ ការយកគ្រួសារជនបទជាមជ្ឈមណ្ឌលនៃការអភិវឌ្ឍសេដ្ឋកិច្ច យកសហគមន៍ជាមូលដ្ឋាននៃការប្រមូលផ្តុំសក្តានុពល យកសហគ្រិនភាពនិងនវានុវត្តន៍ជាកម្លាំងចលករ និងយកការកើនឡើងនៃប្រាក់ចំណូលនិងគុណភាពជីវិតរបស់ប្រជាពលរដ្ឋជាវង្វាស់នៃភាពជោគជ័យ។ ក្នុងន័យនេះ ការអភិវឌ្ឍពិពិធកម្មសេដ្ឋកិច្ចគ្រួសារនៅតំបន់

ជនបទ ត្រូវផ្តោតលើការផ្លាស់ប្តូរផ្នត់គំនិត ពង្រឹងភាពម្ចាស់ការ ជំរុញការច្នៃប្រឌិត និងបង្កើតសមត្ថភាព ឱ្យប្រជាពលរដ្ឋអាចចាប់យកឱកាសសេដ្ឋកិច្ច និងកសាងជីវភាពរបស់ខ្លួនប្រកបដោយចីរភាព។ ផែនការយុទ្ធសាស្ត្រនេះក៏ផ្តល់សារៈសំខាន់ដល់ការអភិវឌ្ឍសហគមន៍ជនបទចម្រុះ ប្រកបដោយសមាហរណកម្ម និងការជំរុញចលនាភូមិគំរូ ដើម្បីកសាងសហគមន៍ដែលមានសាមគ្គីភាព ភាពម្ចាស់ការ សមត្ថភាពគ្រប់គ្រង និងសក្តានុពលសេដ្ឋកិច្ច។ ការអភិវឌ្ឍសេដ្ឋកិច្ចជនបទត្រូវអនុវត្តដោយផ្សារភ្ជាប់គ្នារវាងហេដ្ឋារចនាសម្ព័ន្ធ មូលធនមនុស្ស ផលិតកម្ម សេវាកម្ម ទីផ្សារ បរិស្ថាន និងអភិបាលកិច្ចល្អ ដើម្បីបង្កើតប្រព័ន្ធសេដ្ឋកិច្ចមូលដ្ឋានដែលមានភាពរស់រវើក និងមានភាពធន់។ការអភិវឌ្ឍជនបទក្នុងដំណាក់កាលថ្មី មិនត្រូវរាស់វែងត្រឹមតែចំនួនផ្លូវ ស្ពាន ឬហេដ្ឋារចនាសម្ព័ន្ធដែលបានកសាងនោះទេ ប៉ុន្តែត្រូវរាស់វែងតាមរយៈការកើនឡើងនៃប្រាក់ចំណូល ការរីកចម្រើននៃមុខរបរ និងឱកាសការងារ ការពង្រឹងសមត្ថភាពសហគមន៍ និងការកែលម្អគុណភាពជីវិតរបស់ប្រជាជននៅតំបន់ជនបទ ពោលគឺ«**ពិពិធកម្មសេដ្ឋកិច្ចជនបទ ដើម្បីគ្រួសារធូរធារ សហគមន៍រឹងមាំ និងវិបុលភាពប្រកបដោយចីរភាព**»។

ក្នុងនាមក្រសួងអភិវឌ្ឍន៍ជនបទ ខ្ញុំសូមសម្តែងនូវការគោរពដឹងគុណយ៉ាងជ្រាលជ្រៅចំពោះ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានផ្តល់ការដឹកនាំ និងតម្រង់ទិសជាយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍប្រទេសជាតិ និងការលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជននៅតំបន់ជនបទ។ ខ្ញុំសូមកោតសរសើរ និងថ្លែងអំណរគុណចំពោះថ្នាក់ដឹកនាំ មន្ត្រីរាជការ និងក្រុមការងារពាក់ព័ន្ធនៃក្រសួងអភិវឌ្ឍន៍ជនបទ ដែលបានចូលរួមចំណែកក្នុងការសិក្សាពិភាក្សា ផ្តល់ធាតុចូល និងរៀបចំផែនការយុទ្ធសាស្ត្រនេះ។ ទន្ទឹមនេះ ខ្ញុំសូមថ្លែងអំណរគុណចំពោះក្រសួង-ស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ វិស័យឯកជន និងអ្នកពាក់ព័ន្ធនានាដែលបានផ្តល់កិច្ចសហការ និងការគាំទ្រដល់ការអភិវឌ្ឍជនបទ។

ក្នុងនាមថ្នាក់ដឹកនាំក្រសួងអភិវឌ្ឍន៍ជនបទ ខ្ញុំសូមអំពាវនាវដល់គ្រប់អង្គភាពពាក់ព័ន្ធទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ វិស័យឯកជន អាជ្ញាធរមូលដ្ឋាន និងប្រជាជននៅតំបន់ជនបទ ចូលរួមសហការ គាំទ្រ និងអនុវត្តផែនការយុទ្ធសាស្ត្រនេះឱ្យមានប្រសិទ្ធភាព ប្រសិទ្ធផល និងចីរភាព សំដៅជំរុញការបង្កើតនិងអភិវឌ្ឍមុខរបរ ការលើកកម្ពស់ផលិតភាព និងការពង្រីកឱកាសសេដ្ឋកិច្ចដើម្បីរួមចំណែកធ្វើឱ្យប្រជាជននៅតំបន់ជនបទមានកំណើនប្រាក់ចំណូលប្រកបដោយចីរភាព។

ខ្ញុំមានជំនឿយ៉ាងមុតមាំថា តាមរយៈការអនុវត្តផែនការយុទ្ធសាស្ត្រនេះប្រកបដោយឆន្ទៈមោះមុត ការទទួលខុសត្រូវខ្ពស់ កិច្ចសហការល្អ និងការចូលរួមយ៉ាងសកម្មពីគ្រប់ភាគី យើងនឹងអាចជំរុញការផ្លាស់ប្តូរសេដ្ឋកិច្ចជនបទកម្ពុជាឱ្យឈានទៅដំណាក់កាលថ្មីមួយ ដែលគ្រួសារនៅតំបន់ជនបទមានមុខរបរចម្រុះ មានប្រាក់ចំណូលកើនឡើង មានជីវភាពធូរធារ សហគមន៍មានសេដ្ឋកិច្ចរឹងមាំ និងតំបន់ជនបទមានភាពរស់រវើក ប្រកបដោយវិបុលភាព បរិយាបន្ន និងចីរភាព។

ថ្ងៃ[illegible]ខែ.....ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០
រាជធានីភ្នំពេញ ថ្ងៃទី.....ខែ[illegible] ឆ្នាំ២០២៦

រដ្ឋមន្ត្រី

ឆាយ ឫទ្ធិសែន

១. សេចក្តីផ្តើម

រាជរដ្ឋាភិបាលកម្ពុជា នីតិកាលទី៧ នៃរដ្ឋសភា បានដាក់ចេញយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ក្រោមបាវចនា "**កំណើន ការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព**" និងអាទិភាពគន្លឹះ៥ គឺ **មនុស្ស ផ្លូវ ទឹក ភ្លើង និងបច្ចេកវិទ្យា(ឌីជីថល)** សំដៅកសាងមូលដ្ឋានគ្រឹះឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជាក្លាយជាប្រទេសមានចំណូលខ្ពស់នៅ ឆ្នាំ២០៥០។ ក្នុងក្របខណ្ឌនេះ ការអភិវឌ្ឍមូលធនមនុស្ស ការបង្កើតការងារ ការលើកកម្ពស់សហគ្រិនភាព និងការប្រើប្រាស់បច្ចេកវិទ្យា គឺជាកត្តាសំខាន់សម្រាប់ជំរុញកំណើនសេដ្ឋកិច្ចប្រកបដោយបរិយាបន្ន និងចីរភាព។ ស្របតាមទិសដៅនេះ ការធ្វើពិពិធកម្មសេដ្ឋកិច្ចគ្រួសារនៅតំបន់ជនបទ តាមរយៈការពង្រឹងចំណេះដឹងនិងជំនាញ ការជំរុញការបង្កើត និងអភិវឌ្ឍមុខរបរ ការលើកកម្ពស់សហគ្រិនភាព និងនវានុវត្តន៍ការងារ ព្រមទាំងការប្រើប្រាស់សក្តានុពល និងធនធានមូលដ្ឋានប្រកបដោយប្រសិទ្ធភាព គឺជាការរួមចំណែកជាក់ស្តែងក្នុងការបង្កើនឱកាសការងារ ផលិតភាព និងប្រាក់ចំណូល របស់ប្រជាជននៅតំបន់ជនបទ។

ដើម្បីរួមចំណែកអនុវត្តយុទ្ធសាស្ត្របញ្ចកោណ រាជរដ្ឋាភិបាលបានដាក់ចេញ គោលនយោបាយជាតិស្តីពីការអភិវឌ្ឍជនបទ ឆ្នាំ២០២៥-២០៣៥ ដែលមានចក្ខុវិស័យ "**កសាងសង្គមជនបទកម្ពុជាឱ្យមានវិបុលភាពប្រកបដោយបរិយាបន្ន សមធម៌ និងចីរភាព**" ដោយផ្តោតលើការលើកកម្ពស់ជីវភាពរស់នៅ និងសុខុមាលភាពរបស់ប្រជាជននៅតំបន់ជនបទ។ ក្នុងន័យនេះ ការបង្កើនប្រាក់ចំណូលរបស់ប្រជាជននៅតំបន់ជនបទប្រកបដោយចីរភាព តាមរយៈពិពិធកម្មមុខរបរ និងនវានុវត្តន៍ការងារ គឺជាការចាំបាច់ក្នុងការធ្វើឱ្យមានការអភិវឌ្ឍសេដ្ឋកិច្ច និងមុខរបរនៅមូលដ្ឋានឱ្យមានលក្ខណៈសកម្មនិងសំបូរបែប។ ដើម្បីសម្រេចគោលដៅនេះ ក្រសួងអភិវឌ្ឍន៍ជនបទបានកំណត់ ការលើកកម្ពស់ការធ្វើពិពិធកម្មសេដ្ឋកិច្ចជនបទ ជាកម្មវិធីអាទិភាពមួយក្នុងចំណោមកម្មវិធីអាទិភាពទាំង ៥ របស់ក្រសួង ដោយផ្តោតលើការបង្កើតនិងអភិវឌ្ឍមុខរបរ ការពង្រឹងសមត្ថភាពប្រជាជន និងការប្រើប្រាស់សក្តានុពល ធនធាន និងឱកាសក្នុងមូលដ្ឋាន។ ការអនុវត្តកម្មវិធីអាទិភាពនេះត្រូវផ្សារភ្ជាប់ជាមួយការរៀបចំផែនការសកម្មភាពនិងថវិការបស់ក្រសួងអភិវឌ្ឍន៍ជនបទ ដើម្បីជានាការពសុីសង្វាក់រវាងគោលនយោបាយ យុទ្ធសាស្ត្រ សកម្មភាពការងារ និងការបែងចែកធនធានសម្រាប់ការអនុវត្តប្រកបដោយប្រសិទ្ធភាព។

យោងតាមលទ្ធផលអង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០២៥ ប្រជាជនរស់នៅតំបន់ជនបទមានប្រមាណ ១០,៦លាននាក់ ស្មើនឹង ៦០,៤% នៃប្រជាជនសរុប ដែលមានប្រមាណ ២,៦លានគ្រួសារ ក្នុងនោះមានគ្រួសារប្រមាណ ៤០,២% ពឹងផ្អែកចម្បងលើចំណូលពីការងារដែលទទួលបានប្រាក់ឈ្នួល, ២៥,៩% ពឹងផ្អែកលើអាជីវកម្មគ្រួសារក្រៅពីកសិកម្ម និង ២៥,៨% ពឹងផ្អែកលើការធ្វើកសិកម្ម ឬនេសាទ។[1] ដោយឡែកតាមរបាយការណ៍អង្កេតកសិកម្មកម្ពុជា ឆ្នាំ២០២៤ បានបញ្ជាក់ថា មានគ្រួសារប្រមាណ ១,៨៦លានគ្រួសារ ដែលកាន់កាប់ផ្ទៃដីកសិកម្មសរុបប្រមាណ ៤,៤៣លានហិកតា ដោយជាមធ្យមមានដីកសិកម្មទំហំ ២,៤ហិកតា ក្នុងមួយគ្រួសារ ហើយមានគ្រួសារប្រមាណ ៤២% មានដីកសិកម្មតិចជាង ១ហិកតា ហើយផលិតកម្មកសិកម្មប្រមាណ ៥២% ប្រើប្រាស់សម្រាប់តម្រូវការគ្រួសារ ខណៈដែល ៤៨% ទៀតសម្រាប់លក់។[2] ទិន្នន័យបង្ហាញថាប្រជាជននៅតំបន់ជនបទមានតួនាទីសំខាន់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ច

[1] ឯកសារ "លទ្ធផលអង្កេតកម្លាំងពលកម្មកម្ពុជាឆ្នាំ២០២៥, ទំព័រ ១៣, ១៤, ៤០, និង ៤៥

[2] ឯកសារ "របាយការណ៍អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤, ទំព័រ ៨, ១២, និង ២៦

និងសង្គមនៅកម្ពុជា ពីព្រោះនៅតំបន់ជនបទមានសក្តានុពល និងធនធានចម្រុះសម្រាប់ការបង្កើត និងអភិវឌ្ឍមុខរបររួមមាន ធនធានធម្មជាតិ វត្ថុធាតុដើម កម្លាំងពលកម្ម ចំណេះដឹង និងជំនាញប្រពៃណី ព្រមទាំងឱកាសទីផ្សារ និងការរីកចម្រើននៃបច្ចេកវិទ្យា។ ទន្ទឹមនេះ គ្រួសារនៅតំបន់ជនបទមួយចំនួននៅមានកម្រិតផ្នែកចំណេះដឹង ជំនាញបច្ចេកទេស សមត្ថភាពគ្រប់គ្រងមុខរបរ ការប្រើប្រាស់នវានុវត្តន៍ និងការភ្ជាប់ទីផ្សារ ដែលជាបញ្ហាប្រឈមក្នុងការបង្កើត និងអភិវឌ្ឍមុខរបរចម្រុះ ការបង្កើនផលិតភាព និងប្រាក់ចំណូលគ្រួសារ។ ស្ថានភាពនេះបង្ហាញពីតម្រូវការចាំបាច់ក្នុងការពង្រឹងសមត្ថភាពប្រជាជន ជំរុញការប្រើប្រាស់សក្តានុពលនិងធនធាន មូលដ្ឋានប្រកបដោយប្រសិទ្ធភាព ដើម្បីលើកកម្ពស់សេដ្ឋកិច្ចគ្រួសារនៅតំបន់ជនបទប្រកបដោយចីរភាព។

ដើម្បីឆ្លើយតបនឹងបញ្ហាប្រឈម និងតម្រូវការអភិវឌ្ឍខាងលើ ការធ្វើពិពិធកម្មសេដ្ឋកិច្ចគ្រួសារនៅតំបន់ជនបទ ត្រូវផ្តោតលើការជំរុញ ការបង្កើត និងការអភិវឌ្ឍមុខរបរដោយផ្អែកលើសក្តានុពលធនធាន ជំនាញ និងឱកាសទីផ្សារនៅមូលដ្ឋាន តាមរយៈវិធីសាស្ត្រជំរុញ និងគាំទ្រសំខាន់ ២ គឺ ទី ១ ការបណ្តុះបណ្តាល និងពង្រឹងសមត្ថភាពគ្រួសារ និងក្រុមគោលដៅលើចំណេះដឹង ជំនាញបច្ចេកទេសសហគ្រិនភាព ការគ្រប់គ្រងមុខរបរ និងនវានុវត្តន៍ការងារ ដើម្បីឱ្យមានសមត្ថភាពបង្កើត អភិវឌ្ឍ និងធ្វើពិពិធកម្មមុខរបរដោយខ្លួនឯង និងទី ២ ការគាំទ្រការបង្កើត និងអភិវឌ្ឍមុខរបរគំរូ ដែលមានសក្តានុពល និងសមស្របនឹងលក្ខខណ្ឌមូលដ្ឋាន សម្រាប់ការបង្ហាញ ការរៀនសូត្រ ការផ្លាស់ប្តូរបទពិសោធន៍ និងការផ្សព្វផ្សាយ ដើម្បីជំរុញការយកទៅអនុវត្ត និងពង្រីកការអភិវឌ្ឍមុខរបរនៅតំបន់ជនបទ។

ក្នុងបរិបទនេះ ក្រសួងអភិវឌ្ឍន៍ជនបទបានរៀបចំ **"ផែនការយុទ្ធសាស្ត្រស្តីពី ការធ្វើពិពិធកម្មសេដ្ឋកិច្ចគ្រួសារនៅតំបន់ជនបទ ឆ្នាំ២០២៦-២០៣៣"** ឡើង ដើម្បីជាក្របខណ្ឌតម្រង់ទិស និងជាមូលដ្ឋានសម្រាប់ការកំណត់តម្រូវការអាទិភាព ការរៀបចំកម្មវិធី និងផែនការសកម្មភាព ការសម្របសម្រួលការអនុវត្ត និងការប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធភាព។ ផែនការយុទ្ធសាស្ត្រនេះបានកំណត់គោលដៅសំខាន់ ២ យុទ្ធសាស្ត្រ ៤ និងសកម្មភាពអាទិភាព ២៥ ដោយផ្តោតលើការពង្រឹងសមត្ថភាពគ្រួសារនិងក្រុមគោលដៅ និងការគាំទ្រ បង្កើត និងអភិវឌ្ឍមុខរបរគំរូ តាមរយៈកិច្ចសហការនិងការសម្របសម្រួលរវាងអង្គភាពពាក់ព័ន្ធនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ព្រមទាំងការចូលរួមរបស់ប្រជាជននិងសហគមន៍នៅមូលដ្ឋាន។

ការអនុវត្តផែនការយុទ្ធសាស្ត្រនេះ ត្រូវប្រព្រឹត្តទៅជា ២ដំណាក់កាល ស្របតាមផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ ដោយមានការតាមដានត្រួតពិនិត្យនិងវាយតម្លៃជាប្រចាំ សំដៅរួមចំណែកសម្រេចគោលដៅនៃគោលនយោបាយជាតិស្តីពីការអភិវឌ្ឍជនបទ ឆ្នាំ២០២៥-២០៣៥ ជាពិសេសការលើកកម្ពស់កំណើនប្រាក់ចំណូលរបស់ប្រជាជននៅតំបន់ជនបទប្រកបដោយចីរភាព។

២. ចក្ខុវិស័យ

ប្រជាជននៅតំបន់ជនបទមានកំណើនប្រាក់ចំណូលប្រកបដោយចីរភាព។

៣. បេសកកម្ម

ជំរុញការធ្វើពិពិធកម្មមុខរបរ និងនវានុវត្តន៍ការងារគ្រួសារនៅតំបន់ជនបទ ដោយផ្អែកលើសក្តានុពល ធនធាន ជំនាញ និងឱកាសទីផ្សារនៅមូលដ្ឋាន ដើម្បីបង្កើនផលិតភាព ឱកាសការងារ និងប្រាក់ចំណូលគ្រួសារប្រកបដោយចីរភាព។

៤.គោលបំណងនិងគោលដៅ

៤.១. គោលបំណង

រួមចំណែកបង្កើនប្រាក់ចំណូលគ្រួសារប្រកបដោយចីរភាព តាមរយៈការធ្វើពិពិធកម្មមុខរបរ និងជំរុញនវានុវត្តន៍ការងាររបស់គ្រួសារនៅតំបន់ជនបទ។

៤.២. គោលដៅ

ដើម្បីសម្រេចបាននូវគោលបំណងនៃផែនការយុទ្ធសាស្ត្រស្តីពី ការធ្វើពិពិធកម្មសេដ្ឋកិច្ចគ្រួសារនៅតំបន់ជនបទ ឆ្នាំ២០២៦-២០៣៣ ផែនការយុទ្ធសាស្ត្រនេះផ្តោតលើគោលដៅសំខាន់២ គឺ៖**(១)ជំរុញការធ្វើពិពិធកម្មមុខរបរនិងសកម្មភាពសេដ្ឋកិច្ចរបស់គ្រួសារ** តាមរយៈការអភិវឌ្ឍនិងពង្រីកមុខរបរដែលមានស្រាប់ ព្រមទាំងការបង្កើតមុខរបរបន្ថែម ដើម្បីបង្កើនឱកាសការងារ និងពង្រីកប្រភពចំណូលគ្រួសារ និង**(២)ជំរុញនវានុវត្តន៍ការងារនិងទំនើបកម្មមុខរបរ** តាមរយៈការកែលម្អវិធីសាស្ត្រធ្វើការ ការច្នៃប្រឌិត និងការប្រើប្រាស់បច្ចេកទេស បច្ចេកវិទ្យា និងឧបករណ៍សមស្រប ដើម្បីបង្កើនផលិតភាព ប្រសិទ្ធភាព គុណភាព និងតម្លៃបន្ថែមនៃមុខរបរ។

ដើម្បីវាស់វែងលទ្ធផលសម្រេចបានតាមគោលដៅដែលបានកំណត់នៅ ឆ្នាំ២០៣៣ ផែនការយុទ្ធសាស្ត្រនេះបានកំណត់សូចនាករគោលដៅចំនួន២ ដូចខាងក្រោម៖

ក. ពង្រីងសមត្ថភាពគ្រួសារគោលដៅចំនួន **៥៨ ៤០០គ្រួសារ** តាមរយៈការផ្តល់ចំណេះដឹង និងជំនាញ ដើម្បីជំរុញការបង្កើត អភិវឌ្ឍ និងធ្វើពិពិធកម្មមុខរបរ ព្រមទាំងពង្រីកឱកាសការងារ និងប្រភពចំណូលគ្រួសារ។

ខ. ជំរុញការបង្កើតនិងអភិវឌ្ឍមុខរបរគំរូចំនួន **១៥០មុខរបរ** តាមរយៈការគាំទ្របច្ចេកទេស និងធនធាន ដើម្បីជំរុញនវានុវត្តន៍និងទំនើបកម្មមុខរបរ ព្រមទាំងបង្ហាញ និងផ្សព្វផ្សាយលទ្ធផលសម្រាប់ការរៀនសូត្រ និងពង្រីកការអនុវត្តបន្ត។

៥. ក្របខ័ណ្ឌយុទ្ធសាស្ត្រ

ក្របខ័ណ្ឌយុទ្ធសាស្ត្រនៃផែនការយុទ្ធសាស្ត្រស្តីពីការធ្វើពិពិធកម្មសេដ្ឋកិច្ចគ្រួសារនៅតំបន់ជនបទ ឆ្នាំ២០២៦-២០៣៣ តម្រង់ទិស និងគាំទ្រលើការសិក្សាសក្តានុពលសេដ្ឋកិច្ចនៅមូលដ្ឋាន ការកំណត់មុខរបរអាទិភាព ការពង្រីងសមត្ថភាពគ្រួសារ ក្រុម និងសហគមន៍ ការបង្កើតនិងអភិវឌ្ឍមុខរបរគំរូ ការផ្ទេរចំណេះដឹងនិងបច្ចេកវិទ្យាសមស្រប រហូតដល់ការជំរុញនិងគាំទ្រការអនុវត្តជាក់ស្តែងកម្រិតគ្រួសារ ក្រុម ឬសហគមន៍។ ការអនុវត្តយុទ្ធសាស្ត្រនេះត្រូវផ្តោតលើការប្រើប្រាស់ធនធានក្នុងមូលដ្ឋាន និងការពង្រីងភាពជាម្ចាស់របស់ក្រុមអ្នកទទួលផល ចំពោះការគាំទ្របង្កើតនិងអភិវឌ្ឍមុខរបរគំរូ ត្រូវជ្រើសរើសគ្រួសារនិងក្រុម ដែលមានតម្រូវការ ឆន្ទៈ និងលទ្ធភាពបង្កើត ឬអភិវឌ្ឍមុខរបរក្នុងភាពជាម្ចាស់។

៥.១. ការវិភាគជាយុទ្ធសាស្ត្រ

ការវិភាគជាយុទ្ធសាស្ត្រនេះផ្តោតលើស្ថានភាពសេដ្ឋកិច្ចគ្រួសារ ស្ថានភាពកម្លាំងពលកម្ម និងឱកាសការងារនិងមុខរបរនៅតំបន់ជនបទ ដើម្បីកំណត់បញ្ហាប្រឈម សក្តានុពល និងតម្រូវការគាំទ្រ ដែលជាមូលដ្ឋានសម្រាប់ការកំណត់ទិសដៅយុទ្ធសាស្ត្រនៃផែនការ ឆ្នាំ២០២៦-២០៣៣។

ក. ស្ថានភាពសេដ្ឋកិច្ចគ្រួសារនៅតំបន់ជនបទ

យោងតាមលទ្ធផលអង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០២៥ ប្រជាជនរស់នៅតំបន់ជនបទមានប្រមាណ ១០,៦លាននាក់ ស្មើនឹង ៦០,៤% នៃប្រជាជនសរុប ដែលមានប្រមាណ ២,៦លានគ្រួសារ ក្នុងនោះមានគ្រួសារប្រមាណ ៤០,២% ពឹងផ្អែកចម្បងលើចំណូលពីការងារដែលទទួលបានប្រាក់ឈ្នួល ២៥,៩% ពឹងផ្អែកលើអាជីវកម្មគ្រួសារក្រៅពីកសិកម្ម និង ២៥,៨% ពឹងផ្អែកលើការធ្វើកសិកម្ម ឬនេសាទ។[3] ដោយឡែករបាយការណ៍អង្កេតកសិកម្មកម្ពុជា ឆ្នាំ២០២៤ បានបញ្ជាក់ថា មានគ្រួសារប្រមាណ ១,៨៦លានគ្រួសារដែលកាន់កាប់ផ្ទៃដីកសិកម្មសរុបប្រមាណ ៤,៤៣លានហិកតា ដោយជាមធ្យមមាន ២,៤ហិកតា ក្នុងមួយគ្រួសារ ហើយមានគ្រួសារប្រមាណ ៤២% មានផ្ទៃដីកសិកម្មតិចជាង ១ហិកតា ដោយផលិតកម្មកសិកម្មរបស់គ្រួសារប្រមាណ ៥២% ប្រើប្រាស់សម្រាប់តម្រូវការគ្រួសារ ខណៈដែល ៤៨% ទៀតសម្រាប់លក់។[4]

សេដ្ឋកិច្ចគ្រួសារនៅតំបន់ជនបទដែលមានមូលដ្ឋានផ្អែកលើសកម្មភាពកសិកម្មចម្បង ដូចជាការដាំដុះស្រូវនិងដំណាំរួមផ្សំ ការចិញ្ចឹមសត្វ ការនេសាទ ការប្រមូលផល និងការប្រើប្រាស់ធនធានធម្មជាតិ ព្រមទាំងសកម្មភាពក្រៅវិស័យកសិកម្មដូចជា សិប្បកម្ម ការកែច្នៃផលិតផល ពាណិជ្ជកម្មខ្នាតតូច សេវាកម្ម និងការងារទទួលបានប្រាក់ឈ្នួលក្នុង និងក្រៅវិស័យកសិកម្ម។ សកម្មភាពទាំងនេះមានតួនាទីសំខាន់ក្នុងការបង្កើតការងារ និងប្រាក់ចំណូលសម្រាប់គ្រួសារ ប៉ុន្តែកម្រិតនៃការធ្វើពិពិធកម្មមុខរបរ ផលិតភាព និងលទ្ធភាពបង្កើតតម្លៃបន្ថែម អាចមានភាពខុសគ្នាទៅតាមសក្តានុពល ធនធាន លក្ខខណ្ឌកូមិសាស្ត្រ ហេដ្ឋារចនាសម្ព័ន្ធ និងការតភ្ជាប់ទីផ្សារនៃមូលដ្ឋាននិមួយៗ។ ទោះជាយ៉ាងណា គ្រួសារនៅតំបន់ជនបទមួយចំនួននៅតែពឹងផ្អែកខ្លាំងលើប្រភពចំណូលតែមួយ ឬមុខរបរតាមរដូវកាល ជាពិសេស ការដាំដុះស្រូវ និងដំណាំតាមរដូវ ការចិញ្ចឹមសត្វលក្ខណៈគ្រួសារ ការនេសាទ និងការងារស៊ីឈ្នួលក្នុងវិស័យកសិកម្ម។ ការពឹងផ្អែកបែបនេះអាចធ្វើឱ្យប្រាក់ចំណូលគ្រួសារមិនទៀងទាត់ និងងាយរងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ គ្រោះរាំងស្ងួត ទឹកជំនន់ ជំងឺសត្វ និងផលដំណាំ។ ម្យ៉ាងទៀតការប្រែប្រួលតម្លៃផលិតផលកសិកម្ម និងការកើនឡើងនៃថ្លៃដើមផលិតកម្មនាំឱ្យមានផលប៉ះពាល់ដល់ចំណូល ជាពិសេសនៅពេលប្រភពចំណូលចម្បងរងផលប៉ះពាល់ គ្រួសារដែលខ្វះមុខរបរបន្ថែម ឬប្រភពចំណូលជំនួស អាចប្រឈមនឹងការថយចុះប្រាក់ចំណូល ការកើនឡើងបំណុល និងការលំបាកក្នុងការទ្រទ្រង់ជីវភាពប្រចាំថ្ងៃ។ ទន្ទឹមនឹងនេះ សកម្មភាពផលិតកម្ម និងមុខរបររបស់គ្រួសារនៅតំបន់ជនបទមួយចំនួននៅមានលក្ខណៈខ្នាតគ្រួសារ ពឹងផ្អែកលើកម្លាំងពលកម្មគ្រួសារ និងការប្រើប្រាស់បច្ចេកទេសប្រពៃណី។ ការទទួលបានជំនាញបច្ចេកទេស បច្ចេកវិទ្យាសមស្រប ឧបករណ៍ផលិតកម្ម ទុនវិនិយោគ និងព័ត៌មានទីផ្សារនៅមានកម្រិត ដែលអាចប៉ះពាល់ដល់ផលិតភាព គុណភាពផលិតផល និងសមត្ថភាពប្រកួតប្រជែង។ លើសពីនេះ

[3] ឯកសារ "លទ្ធផលអង្កេតកម្លាំងពលកម្មកម្ពុជាឆ្នាំ២០២៥, ទំព័រ ១៣, ១៤, ៤០, និង ៤៥

[4] ឯកសារ "របាយការណ៍អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤, ទំព័រ ៨, ១២, និង ២៦

ការកែច្នៃ ការវេចខ្ចប់ ការរក្សាទុកផលិតផល និងការតភ្ជាប់ទៅកាន់ទីផ្សារដែលមានតម្លៃខ្ពស់ នៅតែជាបញ្ហាប្រឈមសម្រាប់អ្នកផលិតខ្នាតតូចៗកម្រិតគ្រួសារ។ ស្ថានភាពនេះអាចធ្វើឱ្យគ្រួសារទទួលបានតម្លៃបន្ថែមតិច និងមិនទាន់អាចប្រើប្រាស់សក្តានុពលធនធាន ដែលមាននៅមូលដ្ឋានឱ្យអស់លទ្ធភាព។

ខ. ស្ថានភាពកម្លាំងពលកម្មនៅតំបន់ជនបទ

ផ្អែកលើទិន្នន័យអង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០២៥ តំបន់ជនបទមានប្រជាជនក្នុងវ័យធ្វើការ (អាយុ១៥-៦៤ឆ្នាំ) ប្រមាណ ៦,៩៩លាននាក់ ដែលមានអត្រាចូលរួមកម្លាំងពលកម្មប្រមាណ ៧០,២% នៃកម្លាំងពលកម្មសរុប។ អ្នកមានការងារធ្វើនៅតំបន់ជនបទមានប្រមាណ ៥,៣៨លាននាក់ ស្មើនឹង ៥៩,០% នៃប្រជាជនមានការងារធ្វើសរុបទូទាំងប្រទេស ដែលការងារភាគច្រើនគឺការងារក្រៅប្រព័ន្ធមានរហូតដល់ ៨០,៨% បើធៀបនឹងតំបន់ទីប្រជុំជនដែលមានត្រឹម ៦៦,៨% ប៉ុណ្ណោះ។[5]

ទិន្នន័យទាំងនេះបង្ហាញពីទំហំ និងការចូលរួមយ៉ាងសំខាន់របស់កម្លាំងពលកម្មនៅជនបទក្នុងសកម្មភាពសេដ្ឋកិច្ច ព្រមទាំងឆ្លុះបញ្ចាំងពីសក្តានុពលធនធានមនុស្សដែលអាចអភិវឌ្ឍ និងប្រើប្រាស់សម្រាប់ពង្រីកមូលដ្ឋានសេដ្ឋកិច្ចគ្រួសារនៅតំបន់ជនបទ។ ទោះជាយ៉ាងណា ការមានអត្រាចូលរួមកម្លាំងពលកម្មខ្ពស់ និងចំនួនអ្នកមានការងារធ្វើច្រើន មិនមានន័យថាកម្លាំងពលកម្មទាំងអស់ទទួលបានការងារដែលមានគុណភាព ផលិតភាពខ្ពស់ និងប្រាក់ចំណូលសមរម្យនោះទេ។ កម្លាំងពលកម្មនៅតំបន់ជនបទមួយផ្នែកប្រកបការងារក្នុងវិស័យកសិកម្ម ការងារស៊ីឈ្នួលតាមរដូវកាល ការងារប្រើកម្លាំងពលកម្មប្រចាំថ្ងៃ និងសកម្មភាពសេដ្ឋកិច្ចខ្នាតតូចរបស់គ្រួសារ ដែលអាចមានភាពមិនទៀងទាត់នៃម៉ោងធ្វើការ និងប្រាក់ចំណូល។ បញ្ហាប្រឈមសំខាន់មួយទៀត គឺកម្រិតសមត្ថភាព និងជំនាញរបស់កម្លាំងពលកម្មមួយចំនួន ដែលអាចមិនទាន់ឆ្លើយតបបានពេញលេញនឹងតម្រូវការទីផ្សារការងារ និងការអភិវឌ្ឍមុខរបរថ្មីៗ។ កម្លាំងពលកម្មនៅតំបន់ជនបទមួយចំនួនមានបទពិសោធន៍ និងជំនាញដែលទទួលបានពីការអនុវត្តការងារជាក់ស្តែង ប៉ុន្តែអាចនៅខ្វះជំនាញបច្ចេកទេសទំនើប ជំនាញវិជ្ជាជីវៈ ការគ្រប់គ្រងអាជីវកម្ម ចំណេះដឹងហិរញ្ញវត្ថុ ជំនាញឌីជីថល និងសហគ្រិនភាព។ ការខ្វះជំនាញទាំងនេះអាចកម្រិតលទ្ធភាពក្នុងការបង្កើតមុខរបរថ្មី ការកែលម្អមុខរបរដែលមានស្រាប់ ការប្រើប្រាស់បច្ចេកវិទ្យា និងការបង្កើនផលិតភាពការងារ។ ស្ថានភាពនេះបង្ហាញថា ការអភិវឌ្ឍកម្លាំងពលកម្មនៅតំបន់ជនបទមិនគួរផ្តោតត្រឹមតែការបង្កើនចំនួនអ្នកមានការងារធ្វើប៉ុណ្ណោះទេ ប៉ុន្តែត្រូវគិតគូរដល់ការប្រើប្រាស់កម្លាំងពលកម្មឱ្យមានប្រសិទ្ធភាព ការបង្កើនផលិតភាព និងការកែលម្អគុណភាពការងារផងដែរ។

គ. ស្ថានភាពឱកាសការងារ និងមុខរបរនៅតំបន់ជនបទ

ឱកាសការងារ និងមុខរបរនៅតំបន់ជនបទមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយសក្តានុពលធនធានធម្មជាតិ សកម្មភាពផលិតកម្មកសិកម្ម កម្លាំងពលកម្ម ជំនាញប្រពៃណី និងតម្រូវការទីផ្សារនៅមូលដ្ឋាន។ ជាទូទៅសកម្មភាពសេដ្ឋកិច្ចនៅតំបន់ជនបទរួមមាន ការដាំដុះដំណាំ ការចិញ្ចឹមសត្វ ការនេសាទ ការកែច្នៃផលិតផលកសិកម្ម សិប្បកម្ម ពាណិជ្ជកម្មខ្នាតតូច សេវាកម្ម និងការងារទទួលបានប្រាក់ឈ្នួលក្នុង និងក្រៅវិស័យកសិកម្ម។ សកម្មភាពទាំងនេះជាមូលដ្ឋានសម្រាប់បង្កើតការងារ និងប្រាក់ចំណូលរបស់គ្រួសារ ប៉ុន្តែប្រភេទ និងទំហំនៃឱកាសការងារអាចមានភាពខុសគ្នាទៅតាមលក្ខខណ្ឌ

[5] លទ្ធផលអង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០២៥, ទំព័រ ៤៧, ៥១, ៥៦, និង ៦៨

ភូមិសាស្ត្រ សក្តានុពលធនធាន ហេដ្ឋារចនាសម្ព័ន្ធ កម្រិតអភិវឌ្ឍន៍សេដ្ឋកិច្ច និងការតភ្ជាប់ទីផ្សាររបស់មូលដ្ឋាននិមួយៗ។

ទោះជាយ៉ាងណា ឱកាសការងារ និងមុខរបរនៅតំបន់ជនបទមួយចំនួននៅមានកម្រិត ដោយសារសកម្មភាពសេដ្ឋកិច្ចនៅតែពឹងផ្អែកខ្លាំងលើការផលិតកសិកម្មតាមបែបប្រពៃណី និងការងារតាមរដូវកាល។ ការងារក្នុងវិស័យកសិកម្មអាចប្រមូលផ្តុំនៅក្នុងរដូវដាំដុះ និងប្រមូលផល ខណៈឱកាសការងារនៅក្រៅរដូវកាលនៅមានកម្រិត។ ចំណែកមុខរបរក្រៅវិស័យកសិកម្ម ដូចជា ការកែច្នៃផលិតផល សិប្បកម្ម ពាណិជ្ជកម្ម និងសេវាកម្មខ្នាតតូច នៅតំបន់ខ្លះមិនទាន់មានការអភិវឌ្ឍគ្រប់គ្រាន់ ដើម្បីស្រូបយកកម្លាំងពលកម្ម និងបង្កើតប្រភពចំណូលបន្ថែមសម្រាប់គ្រួសារ។ បញ្ហាប្រឈមសំខាន់មួយទៀតក្នុងការបង្កើត និងអភិវឌ្ឍមុខរបរនៅតំបន់ជនបទ គឺការខ្វះលក្ខខណ្ឌគាំទ្រចាំបាច់មួយចំនួន ដូចជា ព័ត៌មានអំពីតម្រូវការទីផ្សារ ជំនាញបច្ចេកទេសនិងវិជ្ជាជីវៈ ចំណេះដឹងអំពីការគ្រប់គ្រងអាជីវកម្ម ទុនចាប់ផ្តើម ឧបករណ៍ផលិតកម្ម បច្ចេកវិទ្យាសមស្រប និងការតភ្ជាប់ទៅកាន់អ្នកទិញ។ កង្វះលក្ខខណ្ឌទាំងនេះអាចធ្វើឱ្យគ្រួសារមានការលំបាកក្នុងការចាប់ផ្តើមមុខរបរថ្មី ការពង្រីកទំហំផលិតកម្ម និងការកែលម្អមុខរបរដែលមានស្រាប់។ ជាពិសេស មុខរបរខ្នាតតូចមួយចំនួនអាចប្រឈមនឹងថ្លៃដើមផលិតកម្មខ្ពស់ គុណភាពផលិតផលមិនទាន់ស្របតាមតម្រូវការទីផ្សារ និងការលំបាកក្នុងការប្រកួតប្រជែងជាមួយផលិតផល ឬសេវាកម្មផ្សេងទៀត។ ស្ថានភាពនេះអាចបណ្តាលឱ្យប្រជាជនមួយចំនួនមានជម្រើសការងារ និងមុខរបរតិច ព្រមទាំងពិបាករកប្រាក់ចំណូលបន្ថែមនៅក្នុងមូលដ្ឋានរបស់ខ្លួន។

ទន្ទឹមនឹងបញ្ហាប្រឈមខាងលើ តំបន់ជនបទក៏មានសក្តានុពល និងឱកាសជាច្រើនសម្រាប់ការបង្កើត និងអភិវឌ្ឍមុខរបរចម្រុះ។ សក្តានុពលទាំងនេះរួមមានធនធានដី ទឹក ផលិតផលកសិកម្ម វត្តុជាតុដើមក្នុងមូលដ្ឋាន កម្លាំងពលកម្ម និងជំនាញសិប្បកម្មប្រពៃណីនានា ព្រមទាំងតម្រូវការផលិតផល និងសេវាកម្មរបស់ប្រជាជន។ ការប្រើប្រាស់សក្តានុពលទាំងនេះប្រកបដោយប្រសិទ្ធភាព អាចបង្កើតឱកាសសម្រាប់អភិវឌ្ឍមុខរបរទាំងក្នុងនិងក្រៅវិស័យកសិកម្ម ដោយផ្អែកលើលក្ខខណ្ឌ និងស្ថានភាពក្នុងមូលដ្ឋាននិមួយៗ។

សម្រាប់វិស័យកសិកម្ម រាជរដ្ឋាភិបាលបានដាក់ពង្រាយមន្ត្រីកសិកចំនួន ១ ៦០០នាក់ នៅតាមឃុំចំនួន ១ ៥៥០ឃុំ ដើម្បីចុះជួយផ្ទាល់ដល់កសិករជាង ២លានគ្រួសារ ក្នុងការផ្ទេរបច្ចេកទេស និងនវានុវត្តន៍ ព្រមទាំងបានត្រៀមកញ្ចប់ថវិកាប្រមាណ ១០០លានដុល្លារ សម្រាប់ធ្វើអន្តរាគមន៍រក្សាស្ថិរភាពតម្លៃកសិផល និងផ្តល់ឥណទានការប្រាក់ទាបដល់ការអភិវឌ្ឍខ្សែច្រវាក់ផលិតកម្មនិងកសិករ។ នេះជាឱកាសក្នុងការបង្កើត និងអភិវឌ្ឍមុខរបរនៅតំបន់ជនបទ ដូចជាការធ្វើកសិកម្មចម្រុះ ការដាំដុះបន្លែនិងដំណាំដែលមានតម្រូវការទីផ្សារ ការចិញ្ចឹមសត្វ វារីវប្បកម្ម និងសកម្មភាពផលិតកម្មកសិកម្មផ្សេងៗ ដែលសមស្របនឹងធនធាន និងលក្ខខណ្ឌអាកាសធាតុ។ ការធ្វើពិពិធកម្មសកម្មភាពកសិកម្មអាចជួយឱ្យគ្រួសារប្រើប្រាស់ដីធ្លី កម្លាំងពលកម្ម និងធនធានដែលមានស្រាប់ឱ្យកាន់តែមានប្រសិទ្ធភាព ព្រមទាំងបង្កើតប្រភពចំណូលបន្ថែម និងកាត់បន្ថយការពឹងផ្អែកលើផលិតផលកសិកម្មតែមួយប្រភេទ។ ទោះជាយ៉ាងណា ការជ្រើសរើស មុខរបរកសិកម្មអាទិភាព ត្រូវផ្អែកលើការវាយតម្លៃពីតម្រូវការទីផ្សារ លទ្ធភាពផ្គត់ផ្គង់ទឹក ថ្លៃដើមផលិតកម្ម បច្ចេកទេស និងហានិភ័យពាក់ព័ន្ធនានា។[6]

[6] ប្រភពពីក្រសួងកសិកម្ម ត្រាប្រមាញ់ និងនេសាទ

ចំណែកឱកាសការងារ និងមុខរបរក្រៅវិស័យកសិកម្ម ក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម ឆ្នាំ២០២៤-២០៣៥ រាជរដ្ឋាភិបាលបានជាក់បញ្ចូលការផ្តល់អាហារូបករណ៍ និងការបណ្តុះបណ្តាលជំនាញបច្ចេកទេសនិងវិជ្ជាជីវៈ (TVET) សម្រាប់យុវជនមកពីគ្រួសារក្រីក្រនិងងាយរងហានិភ័យ ដោយឥតគិតថ្លៃ និងទទួលបានប្រាក់ឧបត្ថម្ភបន្ថែមទៀត។ គោលនយោបាយនេះនឹងចូលរួមចំណែកក្នុងបង្កើតមុខរបរនិងឱកាសការងារបន្ថែម ដូចជា សេវាកម្មជួសជុលឧបករណ៍ សេវាកម្មដឹកជញ្ជូន សេវាកម្មគាំទ្រផលិតកម្មកសិកម្ម សិប្បកម្ម ពាណិជ្ជកម្មខ្នាតតូច ជាពិសេសការអភិវឌ្ឍសកម្មភាពកែច្នៃដែលមានទំនាក់ទំនងជាមួយផលិតកម្មកសិកម្ម អាចរួមចំណែកបង្កើតតម្លៃបន្ថែម និងពង្រឹងខ្សែច្រវាក់តម្លៃផលិតផលនៅមូលដ្ឋាន។ មុខរបរទាំងនេះអាចបង្កើតឱកាសការងារបន្ថែមនៅក្រៅវិស័យកសិកម្ម និងជួយពង្រីកប្រភពចំណូលបន្ថែមរបស់គ្រួសារនៅតំបន់ជនបទ។

ជាមួយគ្នានេះ ការរីកចម្រើននៃបច្ចេកវិទ្យា និងការប្រើប្រាស់ប្រព័ន្ធឌីជីថលក៏អាចបង្កើតឱកាសថ្មីសម្រាប់ការអភិវឌ្ឍមុខរបរនៅតំបន់ជនបទផងដែរ។ ការប្រើប្រាស់ឧបករណ៍ផលិតកម្មសមស្រប បច្ចេកទេសកែច្នៃនិងក្សោទុកផលិតផល ការកែលម្អ ការវេចខ្ចប់ ការគ្រប់គ្រងចំណាយនិងចំណូល ព្រមទាំងការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល សម្រាប់ផ្សព្វផ្សាយផលិតផល និងទទួលបានព័ត៌មានទីផ្សារ អាចជួយបង្កើនផលិតភាព កាត់បន្ថយថ្លៃដើម និងពង្រីកឱកាសទីផ្សារ។ នៅក្នុងបរិបទគ្រួសារនៅតំបន់ជនបទ នវានុវត្តន៍ការងារមិនកំណត់ត្រឹមការប្រើប្រាស់បច្ចេកវិទ្យាទំនើបដែលត្រូវការទុនវិនិយោគខ្ពស់នោះទេ ប៉ុន្តែរួមបញ្ចូលទាំងការកែលម្អរបៀបធ្វើការ ការរៀបចំដំណើរការផលិត ការកាត់បន្ថយការខាតបង់ ការគ្រប់គ្រងថ្លៃដើម និងការប្រើប្រាស់ឧបករណ៍ ឬបច្ចេកទេសសមស្របដែលគ្រួសារអាចទទួលយក និងអនុវត្តបាន។

ការបង្កើត និងអភិវឌ្ឍមុខរបរដោយគាំទ្រការអភិវឌ្ឍតាមខ្សែច្រវាក់តម្លៃដូចជា ការកែលម្អ ការសម្ងួត និងក្សោទុកផលិតផល ការរៀបចំកំណត់ត្រាចំណាយ-ចំណូល ឬការប្រើប្រាស់ព័ត៌មានតម្លៃទីផ្សារតាមទូរស័ព្ទអាចជាជំហានដំបូងនៃនវានុវត្តន៍ដែលជួយបង្កើនប្រសិទ្ធភាព និងតម្លៃបន្ថែម ដោយមិនចាំបាច់វិនិយោគលើឧបករណ៍មានតម្លៃខ្ពស់។ ទោះជាយ៉ាងណា ការកំណត់មុខរបរអាទិភាពមិនគួរផ្តែកតែលើភាពសម្បូរបែបនៃធនធាន ឬការពេញនិយមនៃមុខរបរណាមួយឡើយ តែត្រូវពិចារណារួមគ្នាអំពីតម្រូវការទីផ្សារ លទ្ធភាពរកប្រាក់ចំណេញ ទុន និងជំនាញដែលត្រូវការ ហានិភ័យ ផលប៉ះពាល់បរិស្ថាន និងលទ្ធភាពបន្តអនុវត្តដោយគ្រួសារ ហើយត្រូវមានការសាកល្បងតាមរយៈការអនុវត្តមុខរបរគំរូ និងការវាយតម្លៃលទ្ធផលជាក់ស្តែង អាចជួយកាត់បន្ថយហានិភ័យមុនពេលពង្រីកការអនុវត្តមុខរបរ។

ការវិភាគទាំងបីផ្នែកខាងលើបង្ហាញថា តំបន់ជនបទមានមូលដ្ឋានសេដ្ឋកិច្ច និងធនធានមនុស្សសំខាន់ៗសម្រាប់ការអភិវឌ្ឍមុខរបរ ប៉ុន្តែគ្រួសារមួយចំនួននៅប្រឈមនឹងការពឹងផ្អែកលើប្រភពចំណូលមានកម្រិត ការងារតាមរដូវកាល ផលិតភាព និងតម្លៃបន្ថែមមិនទាន់ខ្ពស់ ព្រមទាំងឧបសគ្គផ្នែកជំនាញ ប្រភពទុន បច្ចេកវិទ្យា និងទីផ្សារ។ បញ្ហាទាំងនេះមានភាពខុសគ្នាតាមមូលដ្ឋាន ឬតំបន់និមួយៗ ហើយទាមទារការវាយតម្លៃពីសក្តានុពល និងតម្រូវការជាក់ស្តែងមុននឹងផ្តល់ការគាំទ្រ។ ផ្អែកលើលទ្ធផលវិភាគជាយុទ្ធសាស្ត្រនេះ ដើម្បីសម្រេចគោលបំណង ព្រមទាំងគោលដៅជាក់លាក់ដែលបានកំណត់នៃផែនការយុទ្ធសាស្ត្រ ឆ្នាំ២០២៦-២០៣៣ ការកំណត់ទិសដៅយុទ្ធសាស្ត្រ ត្រូវផ្តោតលើការប្រើប្រាស់សក្តានុពលនិងធនធានក្នុងមូលដ្ឋាន ការពង្រឹងសមត្ថភាពនិងភាពជាម្ចាស់របស់គ្រួសារ ក្រុមនិងសហគមន៍ ការជំរុញនវានុវត្តន៍និងទំនើបកម្មមុខរបរ ព្រមទាំងការពង្រឹងយន្តការគាំទ្រ និងការអនុវត្ត

នៅថ្នាក់ក្រោមជាតិ តាមរយៈមន្ទីរអភិវឌ្ឍន៍ជនបទរាជធានី-ខេត្ត។ ចំពោះការគាំទ្រ ត្រូវជំរុញការអភិវឌ្ឍមុខរបរដោយខ្លួនឯងផ្អែកលើតម្រូវការទីផ្សារ និងធនធានសមស្រប ព្រមទាំងគាំទ្រមុខរបរគំរូសម្រាប់ការរៀនសូត្រ ការផ្ទេរបទពិសោធន៍ និងពង្រីកការអនុវត្តបន្ត។

ផ្អែកលើលទ្ធផលនៃការវិភាគខាងលើ និងដើម្បីធានាឱ្យការអនុវត្តមានប្រសិទ្ធភាព ស្របតាមគោលបំណង គោលដៅ និងដែនសមត្ថកិច្ចរបស់ក្រសួងអភិវឌ្ឍន៍ជនបទ វិសាលភាពនៃផែនការយុទ្ធសាស្ត្រនេះត្រូវបានកំណត់លើមូលដ្ឋានសំខាន់ចំនួន២ គឺ វិសាលភាពទីតាំងភូមិសាស្ត្រ និងវិសាលភាពគោលដៅអ្នកទទួលផល។ ចំពោះវិសាលភាពភូមិសាស្ត្រ កំណត់ត្រឹមភូមិនៅតំបន់ជនបទនៃព្រះរាជាណាចក្រកម្ពុជា ដែលយោងតាមទិន្នន័យក្នុងឯកសារ **"សៀវភៅព័ត៌មានរាជធានី-ខេត្ត ឆ្នាំ២០២៤"** របស់ក្រសួងមហាផ្ទៃ នៅទូទាំងប្រទេសមានភូមិសរុបចំនួន ១៤ ៥៧៧ភូមិ ក្នុងនោះនៅតំបន់ជនបទមានចំនួន ១២ ៤៤៤ភូមិ ស្ថិតក្នុង ១ ៣៨៣ឃុំ។ ចំណែកវិសាលភាពគោលដៅអ្នកទទួលផល ត្រូវកំណត់ត្រឹមគ្រួសារ ក្រុម និងសហគមន៍នៅតំបន់ជនបទ ដែលជាគោលដៅនៃការពង្រឹងសមត្ថភាព និងការគាំទ្រការបង្កើត អភិវឌ្ឍ និងធ្វើពិពិធកម្មមុខរបរ។[7]

៥.២. ទិសដៅយុទ្ធសាស្ត្រ

ដើម្បីសម្រេចបាននូវគោលបំណង និងគោលដៅនៃផែនការយុទ្ធសាស្ត្រស្តីពី ការធ្វើពិពិធកម្មសេដ្ឋកិច្ចគ្រួសារនៅតំបន់ជនបទ ឆ្នាំ២០២៦-២០៣៣ ការអនុវត្តត្រូវផ្តោតលើការប្រើប្រាស់សក្តានុពល និងធនធានក្នុងមូលដ្ឋានប្រកបដោយប្រសិទ្ធភាព ការពង្រឹងសមត្ថភាពនិងភាពជាម្ចាស់របស់គ្រួសារ ក្រុមនិងសហគមន៍ ការលើកកម្ពស់នវានុវត្តន៍ និងទំនើបកម្មមុខរបរ ព្រមទាំងការពង្រឹងយន្តការគាំទ្រ និងការអនុវត្តនៅថ្នាក់ក្រោមជាតិ ដោយមន្ទីរអភិវឌ្ឍន៍ជនបទរាជធានី-ខេត្ត។

ការកំណត់ទិសដៅយុទ្ធសាស្ត្រត្រូវផ្អែកលើគោលការណ៍ជំរុញការអភិវឌ្ឍមុខរបរ ដោយខ្លួនឯង ការប្រើប្រាស់ធនធានសមស្របនឹងលក្ខខណ្ឌជាក់ស្តែង និងការគាំទ្រមុខរបរ ឬសកម្មភាពសេដ្ឋកិច្ចគំរូនៅមូលដ្ឋាន ដើម្បីបង្កើតឱកាសរៀនសូត្រ ផ្ទេរបទពិសោធន៍ និងជំរុញការអនុវត្តបន្ត សំដៅរួមចំណែកដល់ការបង្កើនប្រភពចំណូលចម្រុះ ផលិតភាព និងតម្លៃបន្ថែមនៃសកម្មភាពសេដ្ឋកិច្ចគ្រួសារនៅតំបន់ជនបទ។ ផែនការយុទ្ធសាស្ត្រនេះបានកំណត់ទិសដៅយុទ្ធសាស្ត្រសំខាន់ៗចំនួន៣ ដូចខាងក្រោម៖

១) ការអភិវឌ្ឍមុខរបរ និងសកម្មភាពសេដ្ឋកិច្ចដោយផ្អែកលើសក្តានុពលមូលដ្ឋាន

ផ្តោតលើការជំរុញបង្កើត អភិវឌ្ឍ និងធ្វើពិពិធកម្មមុខរបរ និងសកម្មភាពសេដ្ឋកិច្ចគ្រួសារ ដោយផ្អែកលើសក្តានុពល ធនធាន ជំនាញ ចំណេះដឹង និងឱកាសទីផ្សារនៅមូលដ្ឋាន។ លើកកម្ពស់ការកំណត់និងជ្រើសរើសមុខរបរសក្តានុពលដែលមានលទ្ធភាពអនុវត្តជាក់ស្តែង សមស្របនឹងស្ថានភាពសេដ្ឋកិច្ចនិងស្ថានភាពគ្រួសារ ក្រុម ឬសហគមន៍ ព្រមទាំងមានឱកាសក្នុងការបង្កើតការងារនិងប្រភពចំណូលចម្រុះ។ ទន្ទឹមនឹងនេះ ត្រូវជំរុញការប្រើប្រាស់ធនធាន និងវត្ថុជាតុដើមក្នុងមូលដ្ឋានប្រកបដោយប្រសិទ្ធភាព ព្រមទាំងការអភិវឌ្ឍផលិតផលមូលដ្ឋាន និងការផ្សារភ្ជាប់សកម្មភាពសេដ្ឋកិច្ចគ្រួសារទៅនឹងតម្រូវការទីផ្សារ ដើម្បីបង្កើនលទ្ធភាពអភិវឌ្ឍមុខរបរប្រកបដោយចីរភាព។

[7] សៀវភៅព័ត៌មានរាជធានី ខេត្ត ចុះថ្ងៃទី ២៥ ខែមីនា ឆ្នាំ២០២៤

២) ការពង្រឹងសមត្ថភាព នវានុវត្តន៍ និងការបង្កើនតម្លៃបន្ថែមនៃមុខរបរ

ផ្តោតលើការលើកកម្ពស់ចំណេះដឹង ជំនាញបច្ចេកទេស វិជ្ជាជីវៈ បំណិនជីវិត និងសហគ្រិនភាពរបស់គ្រួសារ ក្រុម និងសហគមន៍ ដើម្បីបង្កើនសមត្ថភាព និងភាពជាម្ចាស់ក្នុងការបង្កើត គ្រប់គ្រង និងអភិវឌ្ឍមុខរបរដោយខ្លួនឯង។ ជំរុញការអនុវត្តនវានុវត្តន៍ការងារ ការប្រើប្រាស់បច្ចេកទេស និងបច្ចេកវិទ្យាសមស្រប ព្រមទាំងការកែលម្អវិធីសាស្ត្រផលិត ការកែច្នៃ គុណភាព និងការគ្រប់គ្រងមុខរបរ ដើម្បីបង្កើនផលិតភាពកាត់បន្ថយការខាតបង់ និងបង្កើនតម្លៃបន្ថែមនៃផលិតផលនិងសេវាកម្ម។ ជាមួយគ្នានេះ ការលើកកម្ពស់ការផ្ទេរចំណេះដឹង និងបទពិសោធន៍ តាមរយៈការរៀនសូត្រ ការអនុវត្តជាក់ស្តែង និងការចូលរួមរបស់ស្ត្រី យុវជន ជនមានពិការភាព និងគ្រួសារងាយរងគ្រោះ ក្នុងការអភិវឌ្ឍមុខរបរប្រកបដោយបរិយាបន្ន។

៣) ការពង្រឹងយន្តការគាំទ្រការបង្កើត អភិវឌ្ឍ និងធ្វើពិពិធកម្មមុខរបរនៅមូលដ្ឋាន

ផ្តោតលើការពង្រឹងយន្តការគាំទ្រ កិច្ចសហការ និងការសម្របសម្រួលរវាងអង្គភាពពាក់ព័ន្ធនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ អាជ្ញាធរមូលដ្ឋាន ដៃគូអភិវឌ្ឍន៍ វិស័យឯកជន និងសហគមន៍ ដើម្បីបង្កលក្ខណៈអំណោយផល និងបង្កើនប្រសិទ្ធភាពនៃការគាំទ្រការបង្កើត ការអភិវឌ្ឍ និងធ្វើពិពិធកម្មមុខរបររបស់គ្រួសារនៅតំបន់ជនបទ។ ជំរុញការប្រើប្រាស់មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទ និងយន្តការគាំទ្រដែលមានស្រាប់ សម្រាប់ការអភិវឌ្ឍចំណេះដឹង និងជំនាញ ការផ្តល់ប្រឹក្សាយោបល់ ការគាំទ្របច្ចេកទេស និងការសម្របសម្រួលធនធាន ដើម្បីឆ្លើយតបនឹងតម្រូវការនៃការបង្កើត និងអភិវឌ្ឍមុខរបរនៅមូលដ្ឋាន។ ទន្ទឹមនឹងនេះ ត្រូវផ្តល់អាទិភាពដល់ការគាំទ្រការបង្កើត និងការអភិវឌ្ឍមុខរបរ ឬសកម្មភាពសេដ្ឋកិច្ចគំរូ ដែលសមស្របនឹងសក្តានុពល ធនធាន និងលក្ខខណ្ឌនៅមូលដ្ឋាន ដើម្បីបង្ហាញលទ្ធផលនៃការអនុវត្តជាក់ស្តែងជាពិសេសការធ្វើពិពិធកម្ម នវានុវត្តន៍ និងទំនើបកម្មមុខរបរ ព្រមទាំងផ្សព្វផ្សាយ ផ្ទេរចំណេះដឹង និងបទពិសោធន៍ និងជំរុញការយកមុខរបរគំរូដែលទទួលបានលទ្ធផលល្អទៅអនុវត្ត និងពង្រីកបន្តដោយគ្រួសារ ក្រុម និងសហគមន៍ តាមសមត្ថភាព និងធនធានដែលមាន។

ការអនុវត្តទិសដៅយុទ្ធសាស្ត្រទាំង៣ ខាងលើត្រូវធានាភាពប្រទាក់ក្រឡា និងការបំពេញបន្ថែមគ្នាដោយផ្តោតលើការប្រើប្រាស់សក្តានុពល និងធនធានមូលដ្ឋានប្រកបដោយប្រសិទ្ធភាព ការពង្រឹងសមត្ថភាព ការចូលរួម និងភាពជាម្ចាស់របស់ប្រជាជន ព្រមទាំងការពង្រឹងយន្តការគាំទ្រ ដើម្បីជំរុញការបង្កើត អភិវឌ្ឍ និងធ្វើពិពិធកម្មមុខរបរ ការអនុវត្តនវានុវត្តន៍ និងទំនើបកម្ម និងការពង្រីកការអនុវត្តមុខរបរគំរូនៅមូលដ្ឋាន។ ទិសដៅយុទ្ធសាស្ត្រទាំងនេះជាមូលដ្ឋានសម្រាប់កំណត់យុទ្ធសាស្ត្រ វិធានការអនុវត្ត និងសកម្មភាពការងារអាទិភាព ដើម្បីសម្រេចគោលដៅដែលបានកំណត់ និងរួមចំណែកដល់កំណើនប្រាក់ចំណូលគ្រួសារនៅតំបន់ជនបទប្រកបដោយចីរភាព។

៥.៣. យុទ្ធសាស្ត្រ

ដើម្បីសម្រេចបាននូវគោលបំណង និងគោលដៅនៃផែនការយុទ្ធសាស្ត្រស្តីពី ការធ្វើពិពិធកម្មសេដ្ឋកិច្ចគ្រួសារនៅតំបន់ជនបទ ឆ្នាំ២០២៦-២០៣៣ និងអនុវត្តទិសដៅយុទ្ធសាស្ត្រទាំង៣ ដែលបានកំណត់ ផែនការយុទ្ធសាស្ត្រនេះកំណត់យុទ្ធសាស្ត្រសំខាន់ៗចំនួន៤ ដែលមានលក្ខណៈប្រទាក់ក្រឡា និងបំពេញបន្ថែមគ្នាទៅវិញទៅមក។ ដើម្បីធានាភាពច្បាស់លាស់ និងសង្គតិភាពនៃការអនុវត្តយុទ្ធសាស្ត្រ

និមួយៗត្រូវបានកំណត់សកម្មភាពគន្លឹះ និងសកម្មភាពអាទិភាពសម្រាប់ជាមូលដ្ឋានក្នុងការកំណត់ផែនការសកម្មភាពការងារប្រចាំឆ្នាំ។

យុទ្ធសាស្ត្រទី១៖ ជំរុញបង្កើតនិងអភិវឌ្ឍការងារ និងមុខរបរនៅតំបន់ជនបទ

យុទ្ធសាស្ត្រនេះមានគោលបំណងជំរុញឱ្យគ្រួសារនៅតំបន់ជនបទមានលទ្ធភាព និងសមត្ថភាពក្នុងការបង្កើត អភិវឌ្ឍ និងធ្វើពិពិធកម្មមុខរបរដោយខ្លួនឯង ផ្អែកលើសក្តានុពល ធនធាន ជំនាញ និងឱកាសទីផ្សារនៅមូលដ្ឋាន។ ការអនុវត្តត្រូវផ្តោតលើការបង្កើតមូលដ្ឋានសម្រាប់ការអភិវឌ្ឍមុខរបរ ដែលមានសក្តានុពល និងលទ្ធភាពអនុវត្តជាក់ស្តែង ព្រមទាំងការជំរុញការអភិវឌ្ឍផលិតផល និងមុខរបរគំរូ ដែលអាចផ្ទេរចំណេះដឹង និងបទពិសោធន៍ទៅគ្រួសារ និងក្រុមផ្សេងៗបន្តទៀត។

- **ការកំណត់មុខរបរអាទិភាពដោយផ្អែកលើសក្តានុពល និងធនធានមូលដ្ឋាន** ដោយសិក្សា វាយតម្លៃ និងជ្រើសរើសមុខរបរដែលមានសក្តានុពល ផ្អែកលើធនធាន ជំនាញ តម្រូវការរបស់គ្រួសារ និងឱកាសទីផ្សារនៅមូលដ្ឋាន ព្រមទាំងពិចារណាលើលទ្ធភាពវិនិយោគ ផលចំណេញ និងហានិភ័យ ដើម្បីកំណត់មុខរបរអាទិភាពដែលសមស្របនឹងលក្ខខណ្ឌសេដ្ឋកិច្ច និងមានលទ្ធភាពអនុវត្តជាក់ស្តែង។
- **ការអភិវឌ្ឍមុខរបរដោយផ្អែកលើសក្តានុពល និងឱកាសនៅមូលដ្ឋាន** ដោយជំរុញការប្រើប្រាស់សក្តានុពល ធនធាន និងឱកាសទីផ្សារនៅមូលដ្ឋាន ដើម្បីបង្កើតមូលដ្ឋានសម្រាប់ការអភិវឌ្ឍមុខរបរដែលសមស្របនឹងលក្ខខណ្ឌសេដ្ឋកិច្ច និងស្ថានភាពរបស់គ្រួសារ ឬតំបន់គោលដៅ។
- **ការលើកកម្ពស់សមត្ថភាព និងភាពជាម្ចាស់ក្នុងការអភិវឌ្ឍមុខរបរ** ដោយពង្រឹងសមត្ថភាពគ្រួសារ និងក្រុមក្នុងការរៀបចំ គ្រប់គ្រង និងអភិវឌ្ឍមុខរបរ ដោយជំរុញការចូលរួម ការសម្រេចចិត្ត និងការទទួលខុសត្រូវរបស់អ្នកប្រកបមុខរបរ ឬអាជីវកម្មផ្ទាល់។
- **ការជំរុញពិពិធកម្មមុខរបរ និងប្រភពចំណូលគ្រួសារ** ដោយលើកកម្ពស់ការបង្កើត និងអភិវឌ្ឍមុខរបរបន្ថែម ដែលសមស្របនឹងសមត្ថភាព និងធនធានរបស់គ្រួសារ ដើម្បីបង្កើនឱកាសការងារ និងកាត់បន្ថយការពឹងផ្អែកលើប្រភពចំណូលតែមួយ។
- **ការអភិវឌ្ឍមុខរបរ និងផលិតផលដែលមានសក្តានុពលសម្រាប់ជាគំរូ** ដោយជំរុញការអភិវឌ្ឍមុខរបរ និងផលិតផលដែលមានលក្ខណៈពិសេស និងអត្តសញ្ញាណនៅមូលដ្ឋាន ដើម្បីបង្កើតគំរូសម្រាប់ការរៀនសូត្រ ការផ្សព្វផ្សាយ និងពង្រីកការអនុវត្តបន្ត។

យុទ្ធសាស្ត្រទី២៖ ជំរុញអភិវឌ្ឍសកម្មភាពសេដ្ឋកិច្ចគ្រួសារ ខ្សែច្រវាក់តម្លៃ និងការភ្ជាប់ទីផ្សារនៅតំបន់ជនបទ

យុទ្ធសាស្ត្រនេះមានគោលបំណងលើកកម្ពស់ប្រសិទ្ធភាព ផលិតភាព គុណភាព និងតម្លៃបន្ថែមនៃសកម្មភាពសេដ្ឋកិច្ចគ្រួសារ តាមរយៈការអភិវឌ្ឍខ្សែច្រវាក់តម្លៃ ការពង្រឹងកិច្ចសហការក្នុងការផលិត ការធ្វើអាជីវកម្ម និងការបង្កើនលទ្ធភាពតភ្ជាប់ទៅទីផ្សារ។ ការអនុវត្តត្រូវផ្តោតលើការប្រើប្រាស់ធនធាននៅមូលដ្ឋានប្រកបដោយប្រសិទ្ធភាព ការកែលម្អដំណើរការផលិត និងការគ្រប់គ្រងមុខរបរ ព្រមទាំងការជំរុញនវានុវត្តន៍ និងការបង្កើនឱកាសសេដ្ឋកិច្ចគ្រួសារនៅតំបន់ជនបទប្រកបដោយបរិយាបន្ន។

- **ការអភិវឌ្ឍសកម្មភាពសេដ្ឋកិច្ចដោយផ្អែកលើធនធានមូលដ្ឋាន និងខ្សែច្រវាក់តម្លៃ** ដោយលើកកម្ពស់ការប្រើប្រាស់ធនធាន និងវត្ថុជាតុដើមក្នុងមូលដ្ឋាន ព្រមទាំងការផ្សារភ្ជាប់ជំណាក់កាលផលិតកម្ម កែច្នៃ និងចែកចាយ ដើម្បីបង្កើនប្រសិទ្ធភាព និងតម្លៃសេដ្ឋកិច្ច។
- **ការលើកកម្ពស់ផលិតភាព គុណភាព និងតម្លៃបន្ថែម** ដោយជំរុញការកែលម្អបច្ចេកទេស និងវិធីសាស្ត្រផលិត ការកែច្នៃ ការវេចខ្ចប់ និងគុណភាពផលិតផល ដើម្បីកាត់បន្ថយការខាតបង់ បង្កើនផលិតភាព និងបង្កើនតម្លៃបន្ថែម។
- **ការជំរុញនវានុវត្តន៍និងទំនើបកម្មសកម្មភាពសេដ្ឋកិច្ច** ដោយលើកកម្ពស់ការប្រើប្រាស់បច្ចេកទេស និងបច្ចេកវិទ្យាសមស្រប ការច្នៃប្រឌិត និងការកែលម្អការគ្រប់គ្រង ដើម្បីបង្កើនប្រសិទ្ធភាព និងសមត្ថភាពប្រកួតប្រជែងរបស់មុខរបរនៅតំបន់ជនបទ។
- **ការពង្រឹងកិច្ចសហការនិងសមត្ថភាពគ្រប់គ្រងសេដ្ឋកិច្ចគ្រួសារ ក្រុម និងសហគមន៍** ដោយជំរុញការសហការរវាងគ្រួសារ ក្រុម និងសហគមន៍ក្នុងការផលិត និងធ្វើអាជីវកម្ម ព្រមទាំងការលើកកម្ពស់ចំណេះដឹងហិរញ្ញវត្ថុ ការសន្សំ និងការគ្រប់គ្រងធនធានសម្រាប់បង្កើត និងអភិវឌ្ឍមុខរបរ។
- **ការពង្រឹងការភ្ជាប់ទីផ្សារនិងការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយបរិយាបន្ន** ដោយបង្កើនសមត្ថភាពក្នុងការឈ្វេងយល់ពីតម្រូវការទីផ្សារ និងការភ្ជាប់ផលិតផលទៅអ្នកទិញ ព្រមទាំងពង្រឹងអំណាចសេដ្ឋកិច្ចចំពោះស្ត្រីនិងលើកកម្ពស់ការចូលរួមរបស់យុវជន ជនមានពិការភាព និងគ្រួសារងាយរងគ្រោះក្នុងសកម្មភាពសេដ្ឋកិច្ច។

យុទ្ធសាស្ត្រទី៣៖ ពង្រឹង និងគាំទ្រមជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទ សម្រាប់ការអភិវឌ្ឍជំនាញ សហគ្រិនភាព និងនវានុវត្តន៍

យុទ្ធសាស្ត្រនេះមានគោលបំណងពង្រឹងតួនាទី និងសមត្ថភាពមជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទឱ្យក្លាយជាយន្តការគាំទ្រដ៏សំខាន់ក្នុងការអភិវឌ្ឍធនធានមនុស្ស និងការផ្ទេរចំណេះដឹង ជំនាញ សហគ្រិនភាព និងនវានុវត្តន៍ ដើម្បីឆ្លើយតបទៅនឹងតម្រូវការអភិវឌ្ឍមុខរបររបស់គ្រួសារ និងក្រុមគោលដៅនានានៅតំបន់ជនបទ។ ការអនុវត្តត្រូវផ្តោតលើការលើកកម្ពស់គុណភាព និងភាពសមស្របនៃការបណ្តុះបណ្តាល ការរៀនសូត្រ តាមរយៈការអនុវត្តជាក់ស្តែង និងការគាំទ្របន្តក្រោយបណ្តុះបណ្តាល ដើម្បីបង្កើនលទ្ធភាពយកចំណេះដឹង និងជំនាញទៅប្រើប្រាស់ក្នុងការបង្កើត និងអភិវឌ្ឍមុខរបរ។

- **ការអភិវឌ្ឍជំនាញបច្ចេកទេសនិងជីវៈ ដែលឆ្លើយតបនឹងតម្រូវការមុខរបរ** ដោយលើកកម្ពស់គុណភាព និងភាពសមស្របនៃការបណ្តុះបណ្តាលជំនាញ ដោយផ្សារភ្ជាប់កម្មវិធីបណ្តុះបណ្តាលទៅនឹងសក្តានុពលនៅមូលដ្ឋាន និងតម្រូវការទីផ្សារ។
- **ការអភិវឌ្ឍបំណិនជីវិតនិងសមត្ថភាពសហគ្រិនភាព** ដោយពង្រឹងសមត្ថភាពគ្រួសារ ក្រុម និងសហគមន៍ក្នុងការគ្រប់គ្រងមុខរបរ ការរៀបចំផែនការ ការសម្រេចចិត្ត ការដោះស្រាយបញ្ហា និងការបង្កើតគំនិតអាជីវកម្ម។
- **ការអភិរក្សនិងអភិវឌ្ឍជំនាញជ្លាជីវៈដូនតា** ដោយលើកកម្ពស់ការអភិរក្ស ការផ្ទេរ និងការធ្វើទំនើបកម្មជំនាញប្រពៃណី ដែលមានសក្តានុពលសេដ្ឋកិច្ច ដើម្បីបង្កើនឱកាសការងារ ព្រមទាំងតម្លៃសេដ្ឋកិច្ច វប្បធម៌ និងចំណេះដឹងនៅមូលដ្ឋាន។

- **ការលើកកម្ពស់នវានុវត្តន៍និងការរៀនសូត្រ** តាមរយៈការអនុវត្តដោយជំរុញការច្នៃប្រឌិត ការប្រើប្រាស់បច្ចេកទេសសមស្រប និងការផ្សារភ្ជាប់ការបណ្តុះបណ្តាលជាមួយការបង្ហាញ និងអនុវត្តជាក់ស្តែង។
- **ការពង្រឹងប្រព័ន្ធគាំទ្រនិងការអភិវឌ្ឍសមត្ថភាពប្រកបដោយបរិយាបន្ន** ដោយលើកកម្ពស់ការទទួលបានឱកាសបណ្តុះបណ្តាលដល់ក្រុមគោលដៅ ជាពិសេសស្ត្រី យុវជន ជនមានពិការភាព និងគ្រួសារងាយរងគ្រោះ ព្រមទាំងការបង្វឹក ការផ្តល់ប្រឹក្សាយោបល់ និងការតាមដានក្រោយបណ្តុះបណ្តាល ដើម្បីជំរុញការប្រើប្រាស់ជំនាញប្រកបដោយប្រសិទ្ធភាព។

យុទ្ធសាស្ត្រទី៤៖ ពង្រឹងតួនាទីថ្នាក់ក្រោមជាតិក្នុងការសម្របសម្រួល សហការ និងគាំទ្រការអនុវត្តពិពិធកម្មសេដ្ឋកិច្ចគ្រួសារនៅតំបន់ជនបទ

យុទ្ធសាស្ត្រនេះមានគោលបំណងពង្រឹងតួនាទី និងការទទួលខុសត្រូវរបស់អង្គភាពពាក់ព័ន្ធនៅថ្នាក់ក្រោមជាតិ ក្នុងការសម្របសម្រួល សហការ និងគាំទ្រការអនុវត្តផែនការយុទ្ធសាស្ត្រដែលអនុវត្តដោយថ្នាក់ជាតិ តាមរយៈការកំណត់សក្តានុពល ធនធាន និងតម្រូវការជាក់ស្តែងនៅមូលដ្ឋាន ការសម្របសម្រួលជាមួយអាជ្ញាធរ និងភាគីពាក់ព័ន្ធ ព្រមទាំងការជំរុញការចូលរួមរបស់ប្រជាជនក្នុងសកម្មភាពបង្កើត អភិវឌ្ឍ និងធ្វើពិពិធកម្មមុខរបរ ដើម្បីធានាឱ្យការងារនៅមូលដ្ឋានមានប្រសិទ្ធភាព។



៦. សកម្មភាពការងារ

ដើម្បីសម្រេចបាននូវគោលបំណង និងគោលដៅនៃផែនការយុទ្ធសាស្ត្រស្តីពី ការធ្វើពិពិធកម្ម សេដ្ឋកិច្ចគ្រួសារនៅតំបន់ជនបទ ឆ្នាំ២០២៦-២០៣៣ ការអនុវត្តយុទ្ធសាស្ត្រទាំង៤ ត្រូវបានប្រែក្លាយទៅជាសកម្មភាពការងារជាក់ស្តែង ដោយផ្តោតលើការពង្រឹងសមត្ថភាពគ្រួសារគោលដៅ និងការគាំទ្រ បង្កើត និងអភិវឌ្ឍមុខរបរ ឬសកម្មភាពសេដ្ឋកិច្ចគំរូ ស្របតាមសក្តានុពល ធនធាន និងតម្រូវការទីផ្សារ នៅមូលដ្ឋាន។ ការរៀបចំ និងអនុវត្តសកម្មភាពការងារត្រូវធានាភាពប្រទាក់ក្រឡារវាងគោលដៅ និងយុទ្ធសាស្ត្រដែលបានកំណត់ ដោយផ្តល់អាទិភាពដល់ការបង្កើនចំណេះដឹង ជំនាញ និងភាពជាម្ចាស់របស់គ្រួសារ ក្រុម និងសហគមន៍ ដើម្បីជំរុញការបង្កើត អភិវឌ្ឍ និងធ្វើពិពិធកម្មមុខរបរដោយខ្លួនឯង ព្រមទាំងការអនុវត្តនវានុវត្តន៍ និងទំនើបកម្មមុខរបរ។

ទន្ទឹមនេះ ការគាំទ្រមុខរបរ ឬសកម្មភាពសេដ្ឋកិច្ចគំរូត្រូវផ្តោតលើការបង្ហាញលទ្ធភាពអនុវត្តជាក់ស្តែង ការផ្សេចំណេះដឹង និងបទពិសោធន៍ និងការជំរុញការយកគំរូដែលមានប្រសិទ្ធភាពទៅអនុវត្តបន្ត ដោយគិតគូរពីលទ្ធភាពថវិកា សមត្ថភាពស្ថាប័ន និងការចូលរួមរបស់អ្នកពាក់ព័ន្ធ។

ដើម្បីធានាប្រសិទ្ធភាព សង្គតិភាព និងនិរន្តរភាពនៃការអនុវត្តសកម្មភាពការងារត្រូវរៀបចំដោយផ្អែកលើគោលការណ៍អនុវត្ត វិធីសាស្ត្រអនុវត្ត បរិយាកាសគាំទ្រ និងសកម្មភាពអាទិភាព ដូចខាងក្រោម៖

៦.១. គោលការណ៍អនុវត្ត

ការអនុវត្តសកម្មភាពការងារក្រោមផែនការយុទ្ធសាស្ត្រនេះ ត្រូវប្រកាន់ខ្ជាប់នូវគោលការណ៍សំខាន់ៗ ដើម្បីធានាថាការគាំទ្រឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងរបស់គ្រួសារនៅតំបន់ជនបទ មានការចូលរួមពីអ្នកពាក់ព័ន្ធ និងអាចបង្កើតលទ្ធផលប្រកបដោយប្រសិទ្ធភាព និងចីរភាព។ គោលការណ៍អនុវត្តសំខាន់ៗ រួមមាន៖

១) ការអភិវឌ្ឍដោយផ្អែកលើសក្តានុពលនិងតម្រូវការមូលដ្ឋាន

ការជ្រើសរើស និងអភិវឌ្ឍមុខរបរ ឬសកម្មភាពសេដ្ឋកិច្ចត្រូវផ្អែកលើលទ្ធផលសិក្សា និងវាយតម្លៃសក្តានុពល ធនធាន ជំនាញ ចំណេះដឹង និងឱកាសទីផ្សារនៅមូលដ្ឋាន។ ការកំណត់មុខរបរអោទិភាពត្រូវគិតគូរពីតម្រូវការ និងសមត្ថភាពរបស់គ្រួសារ លទ្ធភាពរកប្រាក់ចំណូល ហានិភ័យ និងផលប៉ះពាល់បរិស្ថាន ដើម្បីធានាថាមុខរបរដែលត្រូវបានជំរុញមានភាពសមស្រប និងអាចអនុវត្តបានជាក់ស្តែង។

២) ការចូលរួម ភាពជាម្ចាស់និងការទទួលខុសត្រូវ

លើកកម្ពស់ការចូលរួមយ៉ាងសកម្មរបស់គ្រួសារ ក្រុម និងសហគមន៍ក្នុងការកំណត់តម្រូវការជ្រើសរើសមុខរបរ រៀបចំផែនការ និងអនុវត្តសកម្មភាពសេដ្ឋកិច្ច។ ការគាំទ្រត្រូវជំរុញឱ្យអ្នកទទួលផលមានភាពជាម្ចាស់ទទួលខុសត្រូវលើការគ្រប់គ្រង និងអភិវឌ្ឍមុខរបររបស់ខ្លួន និងកាត់បន្ថយការពឹងផ្អែកលើជំនួយពីខាងក្រៅ។

៣) ការពង្រឹងសមត្ថភាពនិងការរៀនសូត្រតាមរយៈការអនុវត្ត

ផ្តល់អាទិភាពដល់ការអភិវឌ្ឍចំណេះដឹង ជំនាញបច្ចេកទេសវិជ្ជាជីវៈ បំណិនជីវិត និងសហគ្រិនភាព ដែលឆ្លើយតបទៅនឹងមុខរបរអោទិភាព។ ការបណ្តុះបណ្តាលត្រូវផ្សារភ្ជាប់ទ្រឹស្តីជាមួយការអនុវត្តជាក់ស្តែង

ការបង្ហាញគំរូមុខរបរ ការបង្កឹក និងការផ្តល់ប្រឹក្សាយោបល់ ដើម្បីជំរុញការយកចំណេះដឹង និងជំនាញទៅប្រើប្រាស់ប្រកបដោយប្រសិទ្ធភាព។

៤) ការជំរុញនវានុវត្តន៍និងការប្រើប្រាស់បច្ចេកវិទ្យាថ្មីសមស្រប និងបច្ចេកវិទ្យាឌីជីថល

លើកកម្ពស់ការច្នៃប្រឌិត និងការកែលម្អវិធីសាស្ត្រធ្វើការ ការផលិត ការកែច្នៃ និងការគ្រប់គ្រងមុខរបរ ដោយជំរុញការប្រើប្រាស់បច្ចេកទេស និងបច្ចេកវិទ្យាដែលមានតម្លៃសមរម្យ ងាយស្រួលប្រើប្រាស់សមស្របនឹងលក្ខខណ្ឌមូលដ្ឋាន។ ការអនុវត្តត្រូវផ្តោតលើការបង្កើនផលិតភាព ប្រសិទ្ធផល ការកាត់បន្ថយការខាតបង់ ការកែលម្អគុណភាព និងការបង្កើនតម្លៃបន្ថែម។

៥) បរិយាបន្ននិងសមធម៌ក្នុងការទទួលបានឱកាស

ជានាការចូលរួម និងការទទួលបានឱកាសដោយសមធម៌របស់គ្រួសារគោលដៅ ជាពិសេសពង្រឹងអំណាចសេដ្ឋកិច្ចចំពោះស្ត្រី ការចូលរួមរបស់យុវជន ជនមានពិការភាព និងគ្រួសារងាយរងគ្រោះ។ ការរៀបចំសកម្មភាពត្រូវគិតគូរពីតម្រូវការ និងឧបសគ្គរបស់ក្រុមគោលដៅផ្សេងៗ ដើម្បីជំរុញការចូលរួមនិងការទទួលបានផលប្រយោជន៍ប្រកបដោយបរិយាបន្ន។

៦) ការប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធភាពនិងចីរភាព

ការអនុវត្តត្រូវផ្អែកលើលទ្ធភាពថវិកា ធនធានមនុស្ស សម្ភារ និងសមត្ថភាពស្ថាប័នដែលមានស្រាប់ ដោយផ្តល់អាទិភាពដល់សកម្មភាពដែលមានប្រសិទ្ធភាពក្នុងការចំណាយ អាចអនុវត្តបាន និងមានលទ្ធភាពបន្តដោយខ្លួនឯង។ ទន្ទឹមនឹងនេះ ត្រូវគិតគូរពីការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយការទទួលខុសត្រូវ និងការកាត់បន្ថយហានិភ័យសេដ្ឋកិច្ច និងបរិស្ថាន។

៧) ការសហការ ការសម្របសម្រួលនិងការទទួលខុសត្រូវរួម

ពង្រឹងកិច្ចសហការរវាងអង្គភាពពាក់ព័ន្ធនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ អាជ្ញាធរមូលដ្ឋាន ដៃគូអភិវឌ្ឍន៍ វិស័យឯកជន និងសហគមន៍ ដើម្បីប្រើប្រាស់សក្តានុពល ធនធាន និងជំនាញឱ្យបានសមស្រប។ ការអនុវត្តត្រូវមានការបែងចែកតួនាទី និងការទទួលខុសត្រូវច្បាស់លាស់ ព្រមទាំងការចែករំលែកព័ត៌មាន និងលទ្ធផល ដើម្បីជៀសវាងការអនុវត្តជាន់គ្នា និងបង្កើនប្រសិទ្ធភាពការងារ។

៦.២. វិធីសាស្ត្រអនុវត្ត

ការអនុវត្តសកម្មភាពការងារត្រូវប្រើប្រាស់វិធីសាស្ត្រដែលមានលក្ខណៈជាប្រព័ន្ធ បត់បែន និងផ្អែកលើទិន្នន័យជាមូលដ្ឋាន ដោយផ្សារភ្ជាប់ការសិក្សាសក្តានុពលនៅមូលដ្ឋាន ការកំណត់មុខរបរអាទិភាព ការពង្រឹងសមត្ថភាព ការគាំទ្រមុខរបរគំរូ និងការផ្សព្វផ្សាយបទពិសោធន៍សម្រាប់ការអនុវត្តបន្ត។ វិធីសាស្ត្រនេះត្រូវផ្តល់អាទិភាពដល់ការប្រើប្រាស់យន្តការ និងធនធានដែលមានស្រាប់ ព្រមទាំងការសហការជាមួយអ្នកពាក់ព័ន្ធ ដើម្បីឱ្យការអនុវត្តសមស្របនឹងលក្ខខណ្ឌជាក់ស្តែងនៅមូលដ្ឋាន។

ដំណើរការអនុវត្តត្រូវអនុវត្តតាមជំហានសំខាន់ៗចំនួន៧ ដូចខាងក្រោម៖

១) ការសិក្សានិងវាយតម្លៃសក្តានុពលមូលដ្ឋាន៖ សិក្សា និងប្រមូលព័ត៌មានអំពីស្ថានភាពសេដ្ឋកិច្ចគ្រួសារ ប្រភពចំណូល មុខរបរដែលមានស្រាប់ ធនធាន ជំនាញ និងឱកាសទីផ្សារនៅមូលដ្ឋាន។ វាយតម្លៃលទ្ធភាព និងឧបសគ្គនៃការបង្កើត ឬអភិវឌ្ឍមុខរបរ ដើម្បីកំណត់មូលដ្ឋានព័ត៌មានសម្រាប់ការរៀបចំសកម្មភាពអាទិភាព។

២) ការកំណត់និងជ្រើសរើសមុខរបរអាទិភាព៖ ផ្អែកលើលទ្ធផលសិក្សា និងវាយតម្លៃ ធ្វើការកំណត់ និងជ្រើសរើសមុខរបរដែលមានសក្តានុពល ដោយពិចារណាលើតម្រូវការទីផ្សារ លទ្ធភាពកម្រៃចំណេញ ធនធាន និងដើមទុនដែលត្រូវការ ជំនាញរបស់គ្រួសារ ហានិភ័យ និងផលប៉ះពាល់បរិស្ថាន។ ការជ្រើសរើសមុខរបរត្រូវមានការចូលរួមពីគ្រួសារ ក្រុម និងអ្នកពាក់ព័ន្ធនៅមូលដ្ឋានដើម្បីជានាការភាពសមស្រប និងការទទួលយក។

៣) ការរៀបចំផែនការនិងកំណត់តម្រូវការគាំទ្រ៖ រៀបចំផែនការអនុវត្តសម្រាប់មុខរបរអាទិភាព ដោយកំណត់គ្រួសារ និងក្រុមគោលដៅ តម្រូវការចំណេះដឹង និងជំនាញ ធនធានចាំបាច់ ឱកាសទីផ្សារ និងលទ្ធភាពគាំទ្រពីអង្គភាពពាក់ព័ន្ធ។ ការរៀបចំផែនការត្រូវគិតគូរពីថវិកា ពេលវេលា អ្នកទទួលខុសត្រូវ និងលទ្ធផលរំពឹងទុក ដើម្បីជានាភាពអាចអនុវត្តបាន។

៤) ការពង្រឹងសមត្ថភាពនិងការផ្តល់ការគាំទ្របច្ចេកទេស៖ រៀបចំការបណ្តុះបណ្តាល និងការផ្ទេរចំណេះដឹង ជំនាញបច្ចេកទេស វិជ្ជាជីវៈ បំណិនជីវិត សហគ្រិនភាព និងការគ្រប់គ្រងមុខរបរ តាមតម្រូវការជាក់ស្តែងរបស់គ្រួសារ និងក្រុមគោលដៅ។ អនុវត្តការបណ្តុះបណ្តាលដោយផ្សារភ្ជាប់នឹងការបង្ហាញជាក់ស្តែង ការបង្វឹក និងការផ្តល់ប្រឹក្សាយោបល់ ព្រមទាំងសម្របសម្រួលការទទួលបានព័ត៌មាន និងសេវាគាំទ្រចាំបាច់។

៥) ការបង្កើតនិងអភិវឌ្ឍមុខរបរ ឬសកម្មភាពសេដ្ឋកិច្ចគំរូ៖ ជ្រើសរើស និងគាំទ្រមុខរបរ ឬសកម្មភាពសេដ្ឋកិច្ចគំរូ ដែលមានលទ្ធភាពអនុវត្តជាក់ស្តែង សមស្របនឹងសក្តានុពល និងធនធានមូលដ្ឋាន និងអាចប្រើប្រាស់ជាកន្លែងបង្ហាញ និងរៀនសូត្រ។ ការគាំទ្រត្រូវកំណត់វិសាលភាពឱ្យសមស្របនឹងថវិកា និងសមត្ថភាពអនុវត្ត ដោយផ្តោតលើការបង្ហាញបច្ចេកទេស វិធីសាស្ត្រគ្រប់គ្រង និងការអភិវឌ្ឍមុខរបរដែលអាចយកទៅអនុវត្តបន្តបាន។

៦) ការផ្សព្វផ្សាយ ផ្ទេរបទពិសោធន៍ និងជំរុញការអនុវត្តបន្ត៖ រៀបចំការបង្ហាញលទ្ធផលមុខរបរគំរូ ការធ្វើទស្សនកិច្ចសិក្សា ការផ្លាស់ប្តូរបទពិសោធន៍ និងការផ្សព្វផ្សាយចំណេះដឹងតាមមធ្យោបាយសមស្រប ដើម្បីជំរុញឱ្យគ្រួសារ ក្រុម និងសហគមន៍យកចំណេះដឹង និងបទពិសោធន៍ដែលទទួលបានទៅអនុវត្ត។ ការអនុវត្តបន្តត្រូវផ្អែកលើការស្ម័គ្រចិត្ត សមត្ថភាព ធនធាន និងតម្រូវការទីផ្សាររបស់អ្នកអនុវត្ត។

៧) ការតាមដានត្រួតពិនិត្យ វាយតម្លៃ និងកែលម្អការអនុវត្ត៖ តាមដានវឌ្ឍនភាពនៃការពង្រឹងសមត្ថភាព ការបង្កើតនិងអភិវឌ្ឍមុខរបរគំរូ និងការយកចំណេះដឹង ឬបទពិសោធន៍ទៅអនុវត្តបន្ត។ ប្រមូលនិងវិភាគព័ត៌មានអំពីលទ្ធផល បញ្ហាប្រឈម និងមេរៀនបទពិសោធន៍ ដើម្បីកែលម្អវិធីសាស្ត្រ និងសកម្មភាពការងារ ព្រមទាំងគាំទ្រការរៀបចំផែនការសម្រាប់ការអនុវត្តបន្ត។

ជំណើរការអនុវត្តអាចកែសម្រួលតាមលក្ខខណ្ឌ និងតម្រូវការជាក់ស្តែងរបស់មូលដ្ឋាន ដោយធានាការពង្រឹងសមត្ថភាព និងការគាំទ្រមុខរបរគំរូមានភាពផ្សារភ្ជាប់ និងបំពេញបន្ថែមឱ្យគ្នាទៅវិញទៅមក។

៦.៣. បរិយាកាសគាំទ្រការអនុវត្ត

ដើម្បីធានាឱ្យការអនុវត្តសកម្មភាពការងារប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាព និងសម្រេចបាននូវគោលដៅដែលបានកំណត់ ចាំបាច់ត្រូវមានបរិយាកាសគាំទ្រសមស្រប ទាំងផ្នែកស្ថាប័ន ធនធាន សមត្ថភាពបច្ចេកទេស កិច្ចសហការ និងការចូលរួមពីអ្នកពាក់ព័ន្ធ។ ការរៀបចំបរិយាកាសគាំទ្រត្រូវផ្តោតលើការពង្រឹងយន្តការនិងការប្រើប្រាស់ធនធានដែលមានស្រាប់ ព្រមទាំងការសម្របសម្រួល ការកៀរគរ

និងការគាំទ្របន្ថែមតាមលទ្ធភាព ដើម្បីជំរុញការអនុវត្តសកម្មភាពការងារនៅមូលដ្ឋាន។ កត្តាគាំទ្រការអនុវត្តសំខាន់ៗរួមមាន៖

១) ក្របខណ្ឌស្ថាប័ននិងយន្តការសម្របសម្រួល៖ ពង្រឹងការដឹកនាំ ការសម្របសម្រួល និងការបែងចែកតួនាទីរវាងអង្គភាពពាក់ព័ន្ធនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីធានាភាពស៊ីសង្វាក់គ្នានៃការរៀបចំផែនការ ការអនុវត្ត និងការតាមដានលទ្ធផល។ លើកកម្ពស់ការសហការជាមួយអាជ្ញាធរមូលដ្ឋាន និងស្ថាប័នពាក់ព័ន្ធ ដើម្បីគាំទ្រការជ្រើសរើសកូមិ និងគ្រួសារគោលដៅ ការរៀបចំសកម្មភាព និងការដោះស្រាយបញ្ហាប្រឈមក្នុងការអនុវត្ត។

២) ធនធានហិរញ្ញវត្ថុ សម្ភារ និងការកៀរគរការគាំទ្រ៖ រៀបចំការប្រើប្រាស់ថវិកា និងធនធានដែលមានស្រាប់ឱ្យស្របតាមអាទិភាពនៃផែនការ ដោយផ្តោតលើសកម្មភាពពង្រឹងសមត្ថភាព និងការគាំទ្រមុខរបរគំរូ ដែលមានលទ្ធភាពអនុវត្តជាក់ស្តែង។ ជំរុញការកៀរគរធនធាន និងកិច្ចសហការពីដៃគូអភិវឌ្ឍន៍ វិស័យឯកជន និងអ្នកពាក់ព័ន្ធផ្សេងៗ តាមលទ្ធភាពស្របតាមបទប្បញ្ញត្តិជាធរមាន ដើម្បីបំពេញតម្រូវការគាំទ្រដែលចាំបាច់។

៣) សមត្ថភាពបច្ចេកទេសនិងប្រព័ន្ធផ្តល់សេវាគាំទ្រ៖ ពង្រឹងសមត្ថភាពមន្ត្រីជំនាញ គ្រូបណ្តុះបណ្តាល និងអ្នកសម្របសម្រួលនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងលើកកម្ពស់តួនាទីមជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទ ក្នុងការផ្តល់ការបណ្តុះបណ្តាល ការបង្ហាញបច្ចេកទេស ការបង្វឹក និងការប្រឹក្សាយោបល់។ ជំរុញការរៀបចំឯកសារបច្ចេកទេស សម្ភារបណ្តុះបណ្តាល និងគំរូផែនការអាជីវកម្មសាមញ្ញៗ ដែលអាចប្រើប្រាស់បានតាមតម្រូវការរបស់គ្រួសារ និងក្រុមគោលដៅ។

៤) កិច្ចសហការ ការភ្ជាប់ទៅសេវានិងឱកាសទីផ្សារ៖ លើកកម្ពស់កិច្ចសហការជាមួយស្ថាប័នជំនាញ វិស័យឯកជន អ្នកប្រើប្រាស់ផលិតផល គ្រឹះស្ថានហិរញ្ញវត្ថុ និងដៃគូពាក់ព័ន្ធ ដើម្បីសម្របសម្រួលការទទួលបានព័ត៌មានទីផ្សារ ចំណេះដឹងបច្ចេកទេស សេវាហិរញ្ញវត្ថុ និងឱកាសអភិវឌ្ឍមុខរបរ។ ការសម្របសម្រួលត្រូវផ្តោតលើការបង្កើនសមត្ថភាពគ្រួសារ ក្រុម និងសហគមន៍ក្នុងការស្វែងរក និងការប្រើប្រាស់ឱកាសដែលមាន ដោយមិនពឹងផ្អែកលើការគាំទ្រពីខាងក្រៅ។

៥) ប្រព័ន្ធព័ត៌មាន ការតាមដានត្រួតពិនិត្យ និងការចែករំលែកបទពិសោធន៍៖ ពង្រឹងការប្រមូលនិងគ្រប់គ្រងព័ត៌មានអំពីគ្រួសារគោលដៅ សកម្មភាពពង្រឹងសមត្ថភាព មុខរបរគំរូ និងលទ្ធផលនៃការអនុវត្ត ដើម្បីគាំទ្រការតាមដានត្រួតពិនិត្យ និងវាយតម្លៃ។ ជំរុញការចែករំលែកព័ត៌មាន លទ្ធផល និងមេរៀនបទពិសោធន៍រវាងអង្គភាពអនុវត្ត និងអ្នកពាក់ព័ន្ធ ដើម្បីកែលម្អគុណភាពសកម្មភាព និងជំរុញការយកគំរូដែលមានប្រសិទ្ធភាពទៅអនុវត្តបន្ត។

ការពង្រឹងបរិយាកាសគាំទ្រទាំងនេះ ត្រូវអនុវត្តជាបន្តបន្ទាប់ ស្របតាមសមត្ថភាព និងធនធានដែលមាន ដោយផ្តោតលើការបង្កើនប្រសិទ្ធភាពនៃយន្តការដែលមានស្រាប់ និងការបង្កើតលក្ខខណ្ឌអំណោយផលសម្រាប់គ្រួសារ ក្រុម និងសហគមន៍ក្នុងការអភិវឌ្ឍមុខរបរដោយខ្លួនឯង។

៦.៤. សកម្មភាពអាទិភាព

ការកំណត់សកម្មភាពអាទិភាពត្រូវបានរៀបចំឡើង ដើម្បីសម្រេចយុទ្ធសាស្ត្រ គោលបំណង និងគោលដៅនៃផែនការយុទ្ធសាស្ត្រនេះ។ សកម្មភាពអាទិភាពនីមួយៗត្រូវបម្លែងទៅជាសកម្មភាពការងារជាក់លាក់ ស្របតាមតួនាទី និងការកិច្ចរបស់អង្គភាពទទួលខុសត្រូវអនុវត្តផែនការថវិកាប្រចាំឆ្នាំ ព្រមទាំង

ស្ថានភាព លទ្ធភាពធនធាន និងតម្រូវការនៅមូលដ្ឋាន ដើម្បីជានាប្រសិទ្ធភាព និងការសម្រេចលទ្ធផលតាមគោលដៅដែលបានកំណត់។ សកម្មភាពអាទិភាពសំខាន់ៗ ត្រូវបានរៀបចំផ្តែកលើយុទ្ធសាស្ត្រទាំង៤ ដែលបានកំណត់៖

៦.៤.១. សកម្មភាពអាទិភាពស្ថិតក្រោមយុទ្ធសាស្ត្រទី១ មានដូចខាងក្រោម៖

- សិក្សា វាយតម្លៃ និងកំណត់មុខរបរអោទិភាពដោយផ្តែកលើសក្តានុពលនិងធនធានមូលដ្ឋាន
- រៀបចំនិងផ្សព្វផ្សាយផែនការគំរូអាជីវកម្មសម្រាប់មុខរបរដែលមានសក្តានុពលសេដ្ឋកិច្ច
- ពង្រឹងសមត្ថភាពគ្រួសារ ក្រុម និងសហគមន៍ក្នុងការបង្កើត អភិវឌ្ឍ និងធ្វើពិពិធកម្មមុខរបរ
- ជំរុញនិងគាំទ្រការចាប់ផ្តើមមុខរបរថ្មី និងការពង្រីកមុខរបរដែលមានស្រាប់របស់គ្រួសារ ក្រុម និងសហគមន៍នៅមូលដ្ឋាន
- គាំទ្រការបង្កើតនិងអភិវឌ្ឍមុខរបរ ឬផលិតផលគំរូ ដោយភ្ជាប់នឹងចលនា "ភូមិមួយ ផលិតផលមួយ"
- ពង្រឹងសមត្ថភាពគ្រួសារ ក្រុម និងសហគមន៍គោលដៅក្នុងការគ្រប់គ្រងហានិភ័យ និងជានានិរន្តរភាពនៃមុខរបរ
- រៀបចំ និងអនុវត្តកម្មវិធីបង្ហាញមុខរបរគំរូ ដើម្បីផ្សព្វផ្សាយ និងផ្ទេរបទពិសោធន៍
- តាមដាន និងផ្តល់ការណែនាំបច្ចេកទេសដល់គ្រួសារដែលបានទទួលការគាំទ្រមុខរបរ។

៦.៤.២. សកម្មភាពអាទិភាពស្ថិតក្រោមយុទ្ធសាស្ត្រទី២ មានដូចខាងក្រោម៖

- លើកកម្ពស់ការប្រើប្រាស់ធនធាន និងវត្ថុធាតុដើមក្នុងមូលដ្ឋានសម្រាប់បង្កើតនិងអភិវឌ្ឍមុខរបរ
- ពង្រឹងចំណេះដឹង និងសមត្ថភាពគ្រួសារ ក្រុម និងសហគមន៍ក្នុងការអភិវឌ្ឍមុខរបរតាមខ្សែច្រវាក់តម្លៃ
- ជំរុញការសហការរវាងគ្រួសារ និងការធ្វើអាជីវកម្មជាក្រុម/សហគមន៍ ព្រមទាំងការប្រមូលផ្តុំនិងការទិញ-លក់រួម
- ផ្សព្វផ្សាយនិងបង្ហាញការប្រើប្រាស់នវានុវត្តន៍ បច្ចេកវិទ្យាសមស្រប និងបច្ចេកវិទ្យាឌីជីថលសម្រាប់មុខរបរ និងការធ្វើអាជីវកម្មនៅតំបន់ជនបទ
- ពង្រឹងសមត្ថភាពកែច្នៃ កែលម្អគុណភាព និងបង្កើនតម្លៃបន្ថែមនៃផលិតផលមូលដ្ឋាន
- ពង្រឹងចំណេះដឹងហិរញ្ញវត្ថុ និងសម្របសម្រួលការទទួលបានទុន ធនធាន ឧបករណ៍ និងសម្ភារសម្រាប់ការបង្កើត និងអភិវឌ្ឍមុខរបរ
- ពង្រឹងសមត្ថភាពគ្រប់គ្រងក្រុមសន្សំ និងក្រុម/សហគមន៍ធុរកិច្ចក្នុងវិស័យកសិកម្ម សិប្បកម្ម សេវាកម្ម និងទេសចរណ៍
- ពង្រឹងចំណេះដឹងទីផ្សារ និងសម្របសម្រួលការតភ្ជាប់ទីផ្សារ ការផ្សព្វផ្សាយផលិតផល បណ្តាញអ្នកផ្គត់ផ្គង់ អ្នកប្រើប្រាស់ និងការពង្រីកទីផ្សារ
- លើកកម្ពស់ការចូលរួមរបស់យុវជន ស្ត្រី ជនមានពិការភាព និងគ្រួសារងាយរងគ្រោះក្នុងការបង្កើត អភិវឌ្ឍមុខរបរ និងសកម្មភាពសេដ្ឋកិច្ច
- រៀបចំ និងអនុវត្តកម្មវិធីបង្ហាញ និងផ្សព្វផ្សាយផលិតផលមូលដ្ឋាន ដើម្បីជំរុញការភ្ជាប់ទីផ្សារ។

៦.៤.៣. សកម្មភាពអាទិភាពស្ថិតក្រោមយុទ្ធសាស្ត្រទី៣ មានដូចខាងក្រោម៖

- រៀបចំនិងអនុវត្តការបណ្តុះបណ្តាលជំនាញបច្ចេកទេស និងវិជ្ជាជីវៈសមស្របតាមមុខរបរអាទិភាព និងតម្រូវការទីផ្សារ
- ពង្រឹងប់ណិនជីវិតនិងសមត្ថភាពគ្រប់គ្រងមុខរបររបស់គ្រួសារ ក្រុម និងសហគមន៍នៅមូលដ្ឋាន
- អភិរក្ស ផ្ទេរជំនាញ និងធ្វើទំនើបកម្មវិជ្ជាជីវៈដូនតាដែលមានសក្តានុពលសេដ្ឋកិច្ច និងវប្បធម៌
- ពង្រឹងសមត្ថភាពសហគ្រិនភាព និងនវានុវត្តន៍សម្រាប់ការបង្កើត និងអភិវឌ្ឍមុខរបរ
- លើកកម្ពស់ការចូលរួម និងអភិវឌ្ឍសមត្ថភាពក្រុមយុវជន ស្ត្រី ជនមានពិការភាព និងក្រុមគ្រួសារងាយរងគ្រោះក្នុងការបង្កើត និងអភិវឌ្ឍមុខរបរប្រកបដោយបរិយាបន្ន
- បង្កើតនិងពង្រឹងយន្តការតាមដាន បង្ហឹក ប្រឹក្សាយោបល់ និងគាំទ្របច្ចេកទេសដល់អ្នកទទួលការបណ្តុះបណ្តាលក្នុងការអនុវត្ត និងការអភិវឌ្ឍមុខរបរ
- រៀបចំ និងអនុវត្តកម្មវិធីបង្ហាញ និងផ្ទេរជំនាញ តាមរយៈការអនុវត្តជាក់ស្តែងនៅមជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទ។

៦.៤.៤. សកម្មភាពអាទិភាពស្ថិតក្រោមយុទ្ធសាស្ត្រទី៤ មានដូចខាងក្រោម៖

- សម្របសម្រួលនិងសហការក្នុងការសិក្សា និងកំណត់មុខរបរអាទិភាពនៅមូលដ្ឋាន
- សម្របសម្រួលនិងសហការក្នុងការពង្រឹងសមត្ថភាពប្រជាពលរដ្ឋ និងការបង្ហាញមុខរបរគំរូ
- សម្របសម្រួលនិងគាំទ្រការបង្កើត អភិវឌ្ឍ និងធ្វើពិពិធកម្មមុខរបរនៅមូលដ្ឋាន
- សម្របសម្រួលនិងសហការក្នុងការពង្រឹងសមត្ថភាព និងការគ្រប់គ្រងក្រុមសន្សំ និងឥណទានជនបទ។

៧. ធនធានហិរញ្ញវត្ថុ

ការអនុវត្តផែនការយុទ្ធសាស្ត្រនេះ ត្រូវផ្អែកលើការប្រើប្រាស់សក្តានុពល និងធនធានដែលមានស្រាប់នៅមូលដ្ឋាន រួមផ្សំជាមួយការគាំទ្រពីថវិកាជាតិ និងប្រភពធនធានស្របច្បាប់ផ្សេងទៀត ដើម្បីជំរុញការបង្កើត ការអភិវឌ្ឍ ការធ្វើពិពិធកម្មមុខរបរ និងសកម្មភាពសេដ្ឋកិច្ចរបស់គ្រួសារនៅតំបន់ជនបទ។ ការរៀបចំ និងប្រើប្រាស់ធនធានហិរញ្ញវត្ថុត្រូវផ្តោតជាអាទិភាពលើ ការបណ្តុះបណ្តាលពង្រឹងសមត្ថភាពគ្រួសារ ក្រុម និងសហគមន៍គោលដៅ ព្រមទាំងការគាំទ្រការបង្កើត និងអភិវឌ្ឍមុខរបរគំរូសម្រាប់ការបង្ហាញ ការរៀនសូត្រ និងការផ្សព្វផ្សាយបទពិសោធន៍ ដើម្បីជំរុញការយកចំណេះដឹង និងជំនាញទៅអនុវត្តជាក់ស្តែង។

ការគ្រោង និងវិភាជន៍ធនធានហិរញ្ញវត្ថុត្រូវធ្វើឡើងស្របតាមផែនការថវិកាជាតិប្រចាំឆ្នាំ និងផែនការថវិកាកំណត់ដោយផ្អែកលើអាទិភាពនៃសកម្មភាព និងលទ្ធភាពថវិកាជាក់ស្តែង។ ការគ្រប់គ្រង និងប្រើប្រាស់ធនធានត្រូវអនុវត្តស្របតាមបទប្បញ្ញត្តិ និងនីតិវិធីហិរញ្ញវត្ថុសាធារណៈជាធរមានដោយធានាប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព។

៧.១. តម្រូវការធនធានហិរញ្ញវត្ថុ

តម្រូវការធនធានហិរញ្ញវត្ថុសម្រាប់អនុវត្តផែនការយុទ្ធសាស្ត្រត្រូវកំណត់ដោយផ្អែកលើគោលដៅយុទ្ធសាស្ត្រ សកម្មភាពអាទិភាព និងសកម្មភាពការងារជាក់ស្តែង ព្រមទាំងវិសាលភាពនៃការអនុវត្ត

ផ្តោតលើចំនួនគ្រួសារ ក្រុម និងសហគមន៍គោលដៅនៅមូលដ្ឋាន។ ការកំណត់តម្រូវការធនធានហិរញ្ញវត្ថុ ត្រូវផ្តោតលើការងារគន្លឹះចំនួន២ ដូចខាងក្រោម៖

១) ការបណ្តុះបណ្តាលនិងពង្រឹងសមត្ថភាពគ្រួសារ ក្រុម និងសហគមន៍គោលដៅ៖ ផ្តោតលើការអភិវឌ្ឍចំណេះដឹង និងជំនាញបច្ចេកទេស វិជ្ជាជីវៈ បំណិនជីវិត សហគ្រិនភាព ការគ្រប់គ្រងមុខរបរ និងការប្រើប្រាស់នវានុវត្តន៍ និងបច្ចេកវិទ្យាសមស្រប។ ការគាំទ្ររួមមានការរៀបចំកម្មវិធីបណ្តុះបណ្តាល ឯកសារនិងសម្ភារបង្រៀន ការបង្ហាញ ការអនុវត្តជាក់ស្តែង ការបង្វឹក និងការផ្តល់ប្រឹក្សាបច្ចេកទេស ព្រមទាំងការតាមដានលទ្ធផលក្រោយបណ្តុះបណ្តាល។

២) ការគាំទ្រ ការបង្កើត និងអភិវឌ្ឍមុខរបរគំរូ៖ ផ្តោតលើការជ្រើសរើស និងគាំទ្រមុខរបរ ឬសកម្មភាពសេដ្ឋកិច្ចដែលមានសក្តានុពលនៅមូលដ្ឋាន ដើម្បីរៀបចំជាគំរូសម្រាប់ការបង្ហាញ ការរៀនសូត្រ និងការផ្ទេរបទពិសោធន៍។ ការគាំទ្រអាចរួមមានការផ្តល់ការណែនាំបច្ចេកទេស ការបង្ហាញវិធីសាស្ត្រផលិត ឬកែច្នៃ ការប្រើប្រាស់ឧបករណ៍ បច្ចេកវិទ្យាសមស្រប និងបច្ចេកវិទ្យាឌីជីថល ការកែលម្អគុណភាពផលិតផល និងការផ្សព្វផ្សាយលទ្ធផលនៃមុខរបរគំរូ ដោយផ្អែកលើតម្រូវការ និងលទ្ធភាពថវិកាជាក់ស្តែង។

ក្រៅពីការងារគន្លឹះទាំង២ តម្រូវការធនធានហិរញ្ញវត្ថុក៏ត្រូវគិតគូរដល់ការសិក្សាកំណត់មុខរបរអាទិភាព ការសម្របសម្រួលការអនុវត្តការងារនៅមូលដ្ឋាន ការតាមដានត្រួតពិនិត្យ និងវាយតម្លៃលទ្ធផលផងដែរ។ ការប៉ាន់ប្រមាណតម្រូវការថវិកាត្រូវធ្វើឡើង តាមរយៈការរៀបចំផែនការអនុវត្ត និងផែនការសកម្មភាពតាមឆ្នាំនិមួយៗ ដោយកំណត់សកម្មភាពការងារជាក់លាក់ បរិមាណការងារ លទ្ធផលរំពឹងទុក និងតម្រូវការចំណាយស្របតាមលទ្ធភាពថវិកាដែលអាចរកបាន។

៧.២. ប្រភពហិរញ្ញប្បទាន

ប្រភពហិរញ្ញប្បទានសំខាន់ៗសម្រាប់អនុវត្តផែនការយុទ្ធសាស្ត្រនេះគឺ៖

- ថវិកាជាតិដែលត្រូវបានវិភាជន៍ តាមរយៈផែនការថវិកាប្រចាំឆ្នាំ និងផែនការថវិការបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- បន្ថែមពីថវិកាជាតិ ការអនុវត្តផែនការយុទ្ធសាស្ត្រក៏អាចទទួលបានការគាំទ្រពីកម្មវិធី គម្រោងពាក់ព័ន្ធដៃគូអភិវឌ្ឍន៍ និងប្រភពស្របច្បាប់ផ្សេងៗទៀត
- ការកៀរគរធនធាន និងការគាំទ្រពីប្រភពផ្សេងៗត្រូវធ្វើឡើងដោយផ្អែកលើគោលការណ៍ស្ម័គ្រចិត្ត កិច្ចព្រមព្រៀង និងលទ្ធភាពជាក់ស្តែងរបស់ភាគីពាក់ព័ន្ធ ព្រមទាំងធានាការប្រើប្រាស់ធនធានទាំងនោះស្របតាមគោលបំណង និងអាទិភាពនៃផែនការយុទ្ធសាស្ត្រ។

៧.៣. ការគ្រប់គ្រងនិងប្រើប្រាស់ធនធានហិរញ្ញវត្ថុ

- ការគ្រប់គ្រង និងប្រើប្រាស់ធនធានហិរញ្ញវត្ថុត្រូវអនុវត្តតាមគោលការណ៍ប្រសិទ្ធភាព សន្សំសំចៃ តម្លាភាព និងគណនេយ្យភាព ដោយធានាឱ្យការវិភាជន៍ និងប្រើប្រាស់ថវិកាឆ្លើយតបនឹងគោលដៅ និងសកម្មភាពអាទិភាពដែលបានកំណត់
- អង្គភាពទទួលខុសត្រូវ ត្រូវរៀបចំតម្រូវការថវិកាប្រចាំឆ្នាំ និងផែនការថវិកា ដោយភ្ជាប់ជាមួយផែនការអនុវត្ត សកម្មភាពការងារជាក់លាក់ សូចនាករ និងលទ្ធផលរំពឹងទុក

- ការប្រើប្រាស់ថវិកាត្រូវផ្តល់អាទិភាពដល់សកម្មភាពក្នុងការសម្រេចគោលដៅសំខាន់គឺ ការពង្រឹងសមត្ថភាពគ្រួសារ ក្រុម និងសហគមន៍គោលដៅ ព្រមទាំងគាំទ្រមុខរបរគំរូដែលមានសក្តានុពលសម្រាប់ការបង្ហាញ និងពង្រីកការអនុវត្ត។

៨. ការតាមដានត្រួតពិនិត្យ និងវាយតម្លៃ

ការតាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការយុទ្ធសាស្ត្រស្តីពីការធ្វើពិពិធកម្មសេដ្ឋកិច្ចគ្រួសារនៅតំបន់ជនបទ ឆ្នាំ២០២៦-២០៣៣ គឺជាយន្តការសំខាន់សម្រាប់ពិនិត្យវឌ្ឍនភាព និងវាស់វែងលទ្ធផលសម្រេចបានធៀបនឹងគោលដៅ ព្រមទាំងកំណត់បញ្ហាប្រឈមនានាក្នុងដំណើរការអនុវត្ត ដើម្បីកែលម្អប្រសិទ្ធភាពនៃការអនុវត្ត និងធានាការសម្រេចគោលដៅដែលបានកំណត់។ លទ្ធផលនៃការតាមដានត្រួតពិនិត្យ និងវាយតម្លៃ ត្រូវប្រើប្រាស់ជាមូលដ្ឋានសម្រាប់កែលម្អវិធីសាស្ត្រអនុវត្ត ការកំណត់អាទិភាព និងការរៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ ព្រមទាំងការកែសម្រួលការអនុវត្តតាមដំណាក់កាលនិមួយៗ។ ការតាមដានត្រួតពិនិត្យ និងវាយតម្លៃត្រូវអនុវត្តជា៣ កម្រិតដូចខាងក្រោម៖

ក) ការវាយតម្លៃប្រចាំឆ្នាំ

ត្រូវអនុវត្តប្រចាំឆ្នាំដោយផ្អែកលើផែនការសកម្មភាព សូចនាករ និងគោលដៅក្នុងឆ្នាំ ដើម្បីវាយតម្លៃវឌ្ឍនភាពនៃការអនុវត្តសកម្មភាព ការប្រើប្រាស់ធនធាន និងលទ្ធផលសម្រេចបាន។ ក្នុងនោះការប្រមូលព័ត៌មាន និងរាយការណ៍វឌ្ឍនភាពត្រូវធ្វើប្រចាំខែ ត្រីមាស ឆមាស នព្វមាន និងប្រចាំឆ្នាំ។ ការវាយតម្លៃប្រចាំឆ្នាំដើម្បីកំណត់បញ្ហាប្រឈម វិធានការកែលម្អ និងគាំទ្រការរៀបចំផែនការសកម្មភាព និងថវិកាសម្រាប់ឆ្នាំបន្ទាប់។

ខ) ការវាយតម្លៃដំណាក់កាលទី១ ឆ្នាំ២០២៦-២០២៨

ដំណាក់កាលទី១ ផ្តោតលើការរៀបចំលក្ខខណ្ឌ និងការចាប់ផ្តើមអនុវត្តផែនការយុទ្ធសាស្ត្រ ក្នុងនោះឆ្នាំ២០២៦ ជាឆ្នាំរៀបចំ និងត្រៀមលក្ខខណ្ឌសម្រាប់អនុវត្ត ខណៈឆ្នាំ២០២៧-២០២៨ ជារយៈពេលចាប់ផ្តើមអនុវត្តសកម្មភាពជាក់ស្តែង ស្របតាមផែនការសកម្មភាព និងថវិកា ដោយផ្តោតលើការពង្រឹងសមត្ថភាពគ្រួសារ និងក្រុមគោលដៅ ព្រមទាំងការគាំទ្រការបង្កើត និងអភិវឌ្ឍមុខរបរ ឬសកម្មភាពសេដ្ឋកិច្ចគំរូ។ នៅចុងឆ្នាំ២០២៨ ត្រូវធ្វើការត្រួតពិនិត្យ និងវាយតម្លៃលទ្ធផលអនុវត្តដំណាក់កាលទី១ ដើម្បីកំណត់វឌ្ឍនភាព លទ្ធផលសម្រេចបាន បញ្ហាប្រឈម និងមេរៀនបទពិសោធន៍ ព្រមទាំងរៀបចំអនុសាសន៍សម្រាប់ការកែលម្អ និងបន្តអនុវត្តនៅដំណាក់កាលទី២។

គ) ការវាយតម្លៃដំណាក់កាលទី២ ឆ្នាំ២០២៩-២០៣៣

ដំណាក់កាលទី២ ផ្តោតលើការបន្ត ពង្រឹង និងពង្រីកការអនុវត្តសកម្មភាពអាទិភាព ដោយផ្អែកលើលទ្ធផល និងអនុសាសន៍នៃការវាយតម្លៃដំណាក់កាលទី១។ ការអនុវត្តត្រូវផ្តោតលើការកែលម្អ គុណភាព និងប្រសិទ្ធភាពនៃការពង្រឹងសមត្ថភាព ការអភិវឌ្ឍមុខរបរគំរូ និងការផ្សព្វផ្សាយ ផ្ទេរចំណេះដឹង និងបទពិសោធន៍ ដើម្បីជំរុញការអនុវត្តបន្តដោយគ្រួសារ ក្រុម និងសហគមន៍គោលដៅនៅមូលដ្ឋាន។ នៅចុងឆ្នាំ២០៣៣ ត្រូវធ្វើការវាយតម្លៃបញ្ចប់ផែនការយុទ្ធសាស្ត្រ ដើម្បីវាស់វែងលទ្ធផលសរុប និងកម្រិតសម្រេចបាននៃគោលដៅដែលបានកំណត់ ព្រមទាំងវាយតម្លៃប្រសិទ្ធភាពនៃការអនុវត្ត ស្រង់មេរៀនបទពិសោធន៍ និងរៀបចំអនុសាសន៍សម្រាប់ការកំណត់ទិសដៅ និងរៀបចំផែនការយុទ្ធសាស្ត្របន្ត។

៨.១. ក្របខ័ណ្ឌលទ្ធផលនិងសូចនាករ

ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការយុទ្ធសាស្ត្រ ត្រូវផ្តែកលើក្របខណ្ឌលទ្ធផល និងសូចនាករដែលមានភាពច្បាស់លាស់ អាចវាស់វែងបាន និងសមស្របនឹងសមត្ថភាពប្រមូលទិន្នន័យរបស់អង្គភាពអនុវត្ត។ ក្របខណ្ឌនេះផ្តោតលើការវាស់វែងសមិទ្ធផល និងលទ្ធផលនៃការអនុវត្តគោលដៅជាក់លាក់ទាំង២ ដោយកំណត់លទ្ធផលសំខាន់ៗដូចខាងក្រោម៖

(១) ការពង្រឹងសមត្ថភាពគ្រួសារគោលដៅ និងការយកចំណេះដឹង និងជំនាញទៅអនុវត្ត៖ ផ្តោតលើការតាមដានចំនួនគ្រួសារគោលដៅ ដែលបានទទួលការពង្រឹងសមត្ថភាព តាមរយៈការផ្តល់ចំណេះដឹង និងជំនាញ ព្រមទាំងកម្រិតនៃការយកចំណេះដឹងនិងជំនាញទាំងនោះទៅអនុវត្តក្នុងការបង្កើតអភិវឌ្ឍ និងធ្វើពិពិធកម្មមុខរបរ ដើម្បីពង្រីកឱកាសការងារ និងប្រភពចំណូលគ្រួសារ។ សូចនាករសំខាន់ៗរួមមាន ចំនួនគ្រួសារគោលដៅដែលបានពង្រឹងសមត្ថភាព ភាគរយគ្រួសារដែលបានយកចំណេះដឹងនិងជំនាញទៅអនុវត្ត និងចំនួនគ្រួសារដែលបានបង្កើត ឬបន្តែមមុខរបរ។

(២) ការបង្កើត និងអភិវឌ្ឍមុខរបរគំរូ និងការពង្រីកការអនុវត្តនវានុវត្តន៍ និងទំនើបកម្មមុខរបរ៖ ផ្តោតលើការតាមដានចំនួនមុខរបរគំរូដែលបានបង្កើត និងអភិវឌ្ឍ តាមរយៈការគាំទ្របច្ចេកទេស និងធនធាន ព្រមទាំងលទ្ធផលនៃការអនុវត្តនវានុវត្តន៍ និងទំនើបកម្មមុខរបរ ដើម្បីបង្កើនផលិតភាព ប្រសិទ្ធភាព គុណភាព និងតម្លៃបន្តែម។ ទន្ទឹមនេះ ត្រូវតាមដានការប្រើប្រាស់មុខរបរគំរូសម្រាប់ការបង្ហាញ ការរៀនសូត្រ ការផ្សព្វផ្សាយ និងការផ្ទេរចំណេះដឹងនិងបទពិសោធន៍ ដើម្បីជំរុញការយកមុខរបរគំរូទៅអនុវត្ត និងពង្រីកបន្តដោយគ្រួសារ ក្រុម និងសហគមន៍។ សូចនាករសំខាន់ៗរួមមាន ចំនួនមុខរបរគំរូដែលបានបង្កើត និងអភិវឌ្ឍ ភាគរយមុខរបរគំរូដែលបានអនុវត្តនវានុវត្តន៍ ឬទំនើបកម្ម និងចំនួនគ្រួសារ ឬក្រុមដែលបានយកចំណេះដឹងនិងបទពិសោធន៍ពីមុខរបរគំរូទៅអនុវត្ត។

ទិន្នន័យនិងលទ្ធផលនៃការអនុវត្តត្រូវប្រមូល ធ្វើបច្ចុប្បន្នភាព និងផ្ទៀងផ្ទាត់ជាប្រចាំ ដោយមានការសហការរវាងអង្គភាពពាក់ព័ន្ធនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីធានាភាពត្រឹមត្រូវ ភាពអាចទុកចិត្តបាន និងជៀសវាងការរាប់ត្រួតគ្នា ព្រមទាំងប្រើប្រាស់ជាមូលដ្ឋានសម្រាប់ការវាយតម្លៃវឌ្ឍនភាព និងការកែលម្អការអនុវត្តផែនការយុទ្ធសាស្ត្រ។

៨.២. យន្តការ និងការទទួលខុសត្រូវ

ការតាមដានត្រួតពិនិត្យ និងវាយតម្លៃត្រូវអនុវត្តតាមយន្តការសម្របសម្រួលរវាងអង្គភាពពាក់ព័ន្ធនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដោយមានការបែងចែកតួនាទី ការកិច្ច និងការទទួលខុសត្រូវច្បាស់លាស់ស្របតាមរចនាសម្ព័ន្ធ និងការចាត់តាំងរបស់ក្រសួងអភិវឌ្ឍន៍ជនបទ។

ក) នាយកដ្ឋានអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ ទទួលបន្ទុកដឹកនាំ និងសម្របសម្រួលការតាមដានត្រួតពិនិត្យ និងវាយតម្លៃវឌ្ឍនភាពការងារជារួម រៀបចំក្របខណ្ឌលទ្ធផល និងសូចនាករ ប្រមូលនិងបូកសរុបទិន្នន័យ ព្រមទាំងរៀបចំរបាយការណ៍វឌ្ឍនភាព និងលទ្ធផលវាយតម្លៃ។

ខ) មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទ ទទួលបន្ទុកតាមដានលទ្ធផលនៃការបណ្តុះបណ្តាល និងអភិវឌ្ឍសមត្ថភាព ការយកចំណេះដឹងនិងជំនាញទៅអនុវត្តក្រោយការបណ្តុះបណ្តាល ព្រមទាំងការបង្ហាញនវានុវត្តន៍នៃការអនុវត្តមុខរបរគំរូ និងរាយការណ៍លទ្ធផលជូនអង្គភាពទទួលបន្ទុក។

គ) មន្ទីរអភិវឌ្ឍន៍ជនបទរាជធានី-ខេត្ត ទទួលបន្ទុកសហការ និងសម្របសម្រួលការងារតាមដាន ត្រួតពិនិត្យ និងវាយតម្លៃវឌ្ឍនភាពការងារដែលអនុវត្តដោយថ្នាក់ជាតិ ដោយចូលរួមប្រមូល និងផ្ទៀងផ្ទាត់ទិន្នន័យអំពីគ្រួសារ ក្រុម និងសហគមន៍គោលដៅ និងមុខរបរគំរូ កំណត់បញ្ហាប្រឈម និងរៀបចំរបាយការណ៍ពីវឌ្ឍនភាព និងលទ្ធផលវាយតម្លៃ។

៨.៣. ការប្រើប្រាស់លទ្ធផលនៃការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

លទ្ធផលនៃការតាមដានត្រួតពិនិត្យ និងវាយតម្លៃត្រូវប្រើប្រាស់សម្រាប់កែលម្អប្រសិទ្ធភាពនៃការអនុវត្តផែនការយុទ្ធសាស្ត្រ ជាពិសេសការកែលម្អកម្មវិធីបណ្តុះបណ្តាល និងវិធីសាស្ត្រពង្រឹងសមត្ថភាព ការជ្រើសរើស និងគាំទ្រមុខរបរគំរូ ព្រមទាំងការផ្សព្វផ្សាយបទពិសោធន៍ និងការអនុវត្តល្អៗទៅមូលដ្ឋានផ្សេងទៀត។ លទ្ធផលទាំងនេះក៏ត្រូវប្រើប្រាស់ជាមូលដ្ឋានសម្រាប់កំណត់អាទិភាព រៀបចំ និងកែសម្រួលផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ ផែនការថវិកា៣ឆ្នាំរំកិល ព្រមទាំងការរៀបចំផែនការយុទ្ធសាស្ត្របន្តក្រោយឆ្នាំ២០៣៣។

៩. សេចក្តីសន្និដ្ឋាន

ក្រសួងអភិវឌ្ឍន៍ជនបទបានរៀបចំផែនការយុទ្ធសាស្ត្រស្តីពី ការធ្វើពិពិធកម្មសេដ្ឋកិច្ចគ្រួសារនៅតំបន់ជនបទ ឆ្នាំ២០២៦-២០៣៣ ដើម្បីជាក្របខណ្ឌតម្រង់ទិសសម្រាប់ជំរុញការបង្កើត អភិវឌ្ឍ និងធ្វើពិពិធកម្មមុខរបរ និងសកម្មភាពសេដ្ឋកិច្ចរបស់គ្រួសារ ព្រមទាំងការជំរុញនវានុវត្តន៍ការងារ និងទំនើបកម្មមុខរបរ ដោយផ្អែកលើសក្តានុពល ធនធាន ជំនាញ និងឱកាសទីផ្សារនៅមូលដ្ឋាន សំដៅបង្កើនឱកាសការងារ ផលិតភាព តម្លៃបន្ថែម និងពង្រីកប្រភពចំណូលរបស់គ្រួសារនៅតំបន់ជនបទប្រកបដោយចីរភាព។

ផែនការយុទ្ធសាស្ត្រនេះបានកំណត់ទិសដៅយុទ្ធសាស្ត្រ យុទ្ធសាស្ត្រ និងសកម្មភាពការងារអាទិភាពសម្រាប់ការអនុវត្ត ដោយផ្តោតលើការពង្រឹងសមត្ថភាពគ្រួសារគោលដៅតាមរយៈការផ្តល់ចំណេះដឹង និងជំនាញ ព្រមទាំងការគាំទ្រការបង្កើត និងអភិវឌ្ឍមុខរបរគំរូ ដើម្បីបង្ហាញលទ្ធផលនៃការអនុវត្តជាក់ស្តែង ជំរុញការរៀនសូត្រ ការផ្សព្វផ្សាយ និងការផ្ទេរចំណេះដឹង និងបទពិសោធន៍សម្រាប់ការយកទៅអនុវត្ត និងពង្រីកបន្ត។ ការអនុវត្តប្រកបដោយប្រសិទ្ធភាពនឹងរួមចំណែកជំរុញការធ្វើពិពិធកម្មមុខរបរ ការកែលម្អវិធីសាស្ត្រធ្វើការ ការបង្កើនផលិតភាព និងតម្លៃបន្ថែម ព្រមទាំងការពង្រីកឱកាសសេដ្ឋកិច្ចរបស់គ្រួសារនៅតំបន់ជនបទ។

ដើម្បីជានាប្រសិទ្ធភាពនិងការសម្រេចបាននូវគោលដៅនៃផែនការយុទ្ធសាស្ត្រ ចាំបាច់ត្រូវមានការដឹកនាំ និងសម្របសម្រួលប្រកបដោយប្រសិទ្ធភាពពីអង្គភាពពាក់ព័ន្ធនៅថ្នាក់ជាតិ ព្រមទាំងការចូលរួមសហការ និងគាំទ្រពីថ្នាក់ក្រោមជាតិ អាជ្ញាធរមូលដ្ឋាន ដៃគូអភិវឌ្ឍន៍ វិស័យឯកជន និងសហគមន៍ ដោយផ្តោតលើការប្រើប្រាស់យន្តការ ធនធាន និងថវិកាដែលមានប្រកបដោយប្រសិទ្ធភាព ការពង្រឹងភាពជាម្ចាស់ និងការចូលរួមរបស់ប្រជាជន ព្រមទាំងការតាមដាន និងវាយតម្លៃលទ្ធផលជាប្រចាំ។ ការអនុវត្តផែនការយុទ្ធសាស្ត្រនេះនឹងរួមចំណែកដល់ការសម្រេចគោលដៅនៃគោលនយោបាយជាតិ **ស្តីពី ការអភិវឌ្ឍជនបទ ឆ្នាំ២០២៥-២០៣៥** ជាពិសេសការលើកកម្ពស់កំណើនប្រាក់ចំណូលរបស់ប្រជាជននៅតំបន់ជនបទប្រកបដោយចីរភាព។

បរិសិដ្ឋ

បរិសិដ្ឋនេះត្រូវបានរៀបចំឡើង ដើម្បីកំណត់និយមន័យ និងបកស្រាយពាក្យបច្ចេកទេសសំខាន់ៗ ដែលប្រើប្រាស់ក្នុងផែនការយុទ្ធសាស្ត្រនេះ៖ សំដៅជានាឱ្យមានការយល់ដឹងរួមភាពច្បាស់លាស់ និងឯកភាព ក្នុងការរៀបចំ ការអនុវត្ត ការតាមដាន និងការវាយតម្លៃលទ្ធផលនៃផែនការ។

បរិសិដ្ឋទី១. ពាក្យគន្លឹះសំខាន់ៗនៃផែនការយុទ្ធសាស្ត្រ

ល.រ	ពាក្យបច្ចេកទេស	និយមន័យ និងការពន្យល់
១	**សេដ្ឋកិច្ចគ្រួសារ**	សំដៅដល់សកម្មភាពសេដ្ឋកិច្ចទាំងឡាយដែលសមាជិកគ្រួសារប្រកបមុខរបរ ដោយប្រើប្រាស់កម្លាំងពលកម្ម ជំនាញ ទុន និងធនធានដែលមាន ដើម្បីបង្កើតប្រាក់ចំណូល ផ្គត់ផ្គង់ជីវភាព និងលើកកម្ពស់សុខុមាលភាពគ្រួសារ។
២	**ពិពិធកម្មសេដ្ឋកិច្ចគ្រួសារ**	សំដៅដល់ដំណើរការបង្កើត អភិវឌ្ឍ និងពង្រីកមុខរបរ ឬសកម្មភាពសេដ្ឋកិច្ចច្រើនប្រភេទរបស់គ្រួសារ ដើម្បីបង្កើនឱកាសការងារ ពង្រីកប្រភពចំណូល កាត់បន្ថយការពឹងផ្អែកលើប្រភពចំណូលតែមួយ និងពង្រឹងភាពធន់នៃសេដ្ឋកិច្ចគ្រួសារ។
៣	**ពិពិធកម្មមុខរបរ**	សំដៅដល់ការបង្កើត ឬបន្ថែមមុខរបរប្រភេទថ្មី ក្រៅពីមុខរបរដែលគ្រួសារកំពុងប្រកប ដើម្បីពង្រីកជម្រើសសកម្មភាពសេដ្ឋកិច្ច និងប្រភពចំណូល។
៤	**មុខរបរ**	សំដៅដល់ការងារ ឬសកម្មភាពសេដ្ឋកិច្ចដែលបុគ្គល គ្រួសារ ឬក្រុមប្រកបជាប្រចាំ ឬតាមរដូវកាល ដើម្បីទទួលបានប្រាក់ចំណូល ឬផលប្រយោជន៍សេដ្ឋកិច្ច។
៥	**មុខរបរអាទិភាព**	សំដៅដល់មុខរបរដែលត្រូវបានសិក្សា វាយតម្លៃ និងជ្រើសរើសសម្រាប់ការគាំទ្រ និងអភិវឌ្ឍ ដោយផ្អែកលើសក្តានុពល ធនធាន ជំនាញ តម្រូវការគ្រួសារ ឱកាសទីផ្សារ លទ្ធភាពវិនិយោគ និងកម្រិតហានិភ័យ។
៦	**សក្តានុពលសេដ្ឋកិច្ចមូលដ្ឋាន**	សំដៅដល់ធនធាន លក្ខខណ្ឌ និងឱកាសដែលមាននៅមូលដ្ឋាន និងអាចប្រើប្រាស់សម្រាប់បង្កើត ឬអភិវឌ្ឍមុខរបរ ដូចជា ធនធានធម្មជាតិ កម្លាំងពលកម្ម ជំនាញ ប្រពៃណី ផលិតផល និងឱកាសទីផ្សារ។
៧	**ការបង្កើត និងអភិវឌ្ឍមុខរបរ**	សំដៅដល់ដំណើរការចាប់ផ្តើមមុខរបរថ្មី ឬកែលម្អ និងពង្រឹងមុខរបរដែលមានស្រាប់ ដើម្បីបង្កើនសមត្ថភាពផលិតកម្ម ប្រសិទ្ធភាព គុណភាព ឱកាសទីផ្សារ និងលទ្ធភាពបង្កើតប្រាក់ចំណូល។
៨	**ខ្សែច្រវាក់តម្លៃ**	សំដៅដល់លំដាប់សកម្មភាពដែលមានទំនាក់ទំនងគ្នា ចាប់ពីការផ្គត់ផ្គង់ធាតុចូល ការផលិត ការកែច្នៃ ការវេចខ្ចប់ ការដឹកជញ្ជូន រហូតដល់ការចែកចាយ និងលក់ផលិតផលដល់អ្នកប្រើប្រាស់ ដោយមានការបង្កើត ឬបន្ថែមតម្លៃនៅតាមដំណាក់កាលនីមួយៗ។

៩	**ការភ្ជាប់ទីផ្សារ**	សំដៅដល់ដំណើរការបង្កើត និងពង្រឹងទំនាក់ទំនងរវាងអ្នកផលិត អ្នកកែច្នៃ អ្នកប្រមូលទិញ អ្នកចែកចាយ និងអ្នកប្រើប្រាស់ ដើម្បីបង្កើនឱកាសលក់ផលិតផល និងសេវាកម្ម។
១០	**នវានុវត្តន៍ការងារ**	សំដៅដល់ការបង្កើត ឬយកគំនិត វិធីសាស្ត្រ ដំណើរការ បច្ចេកទេស ឬឧបករណ៍ថ្មី ឬដែលបានកែលម្អ មកអនុវត្តក្នុងការងារ និងមុខរបរ ដើម្បីបង្កើនផលិតភាព ប្រសិទ្ធភាព គុណភាព និងតម្លៃបន្ថែម ដោយសមស្របនឹងសមត្ថភាព និងលក្ខខណ្ឌរបស់គ្រួសារ។
១១	**ទំនើបកម្មមុខរបរ**	សំដៅដល់ដំណើរការកែលម្អ និងលើកកម្ពស់ការប្រកបមុខរបរឱ្យមានប្រសិទ្ធភាព ផលិតភាព គុណភាព និងសមត្ថភាពប្រកួតប្រជែងកាន់តែប្រសើរ តាមរយៈការកែលម្អវិធីសាស្ត្រធ្វើការ ការរៀបចំផលិតកម្ម និងការប្រើប្រាស់បច្ចេកទេស បច្ចេកវិទ្យា ឬឧបករណ៍សមស្រប។
១២	**បច្ចេកវិទ្យាសមស្រប**	សំដៅដល់បច្ចេកវិទ្យា ឬឧបករណ៍ដែលសមស្របនឹងតម្រូវការ ជំនាញ សមត្ថភាព លទ្ធភាពវិនិយោគ និងលក្ខខណ្ឌសេដ្ឋកិច្ច សង្គម និងបរិស្ថាននៅមូលដ្ឋាន។
១៣	**ការពង្រឹងសមត្ថភាព**	សំដៅដល់ដំណើរការលើកកម្ពស់ចំណេះដឹង ជំនាញ និងសមត្ថភាពអនុវត្តរបស់បុគ្គល គ្រួសារ ក្រុម ឬសហគមន៍ តាមរយៈការបណ្តុះបណ្តាល ការណែនាំបច្ចេកទេស ការបង្វឹក និងការរៀនសូត្រពីការអនុវត្តជាក់ស្តែង។
១៤	**មុខរបរគំរូ**	សំដៅដល់មុខរបរ ឬសកម្មភាពសេដ្ឋកិច្ចដែលត្រូវបានជ្រើសរើស បង្កើត ឬអភិវឌ្ឍដោយមានការគាំទ្របច្ចេកទេស ឬធនធាន ដើម្បីបង្ហាញពីវិធីសាស្ត្រអនុវត្តល្អ ការធ្វើពិពិធកម្ម នវានុវត្តន៍ ឬទំនើបកម្មមុខរបរ និងផ្តល់ជាគំរូសម្រាប់ការរៀនសូត្រ ផ្ទេរបទពិសោធន៍ និងពង្រីកការអនុវត្តនៅមូលដ្ឋាន។
១៥	**ការគាំទ្របច្ចេកទេស**	សំដៅដល់ការផ្តល់ចំណេះដឹង ជំនាញ ការណែនាំ ការបង្វឹក ឬសេវាប្រឹក្សាបច្ចេកទេស ដើម្បីជួយដល់ការបង្កើត កែលម្អ និងអភិវឌ្ឍមុខរបរ។
១៦	**សហគ្រិនភាព**	សំដៅដល់សមត្ថភាពក្នុងការស្វែងរកឱកាស បង្កើតគំនិត រៀបចំ និងគ្រប់គ្រងសកម្មភាពអាជីវកម្ម ព្រមទាំងចេះវាយតម្លៃ និងគ្រប់គ្រងហានិភ័យ ដើម្បីបង្កើតតម្លៃ និងប្រាក់ចំណូល។
១៧	**ភាពធន់នៃសេដ្ឋកិច្ចគ្រួសារ**	សំដៅដល់សមត្ថភាពរបស់គ្រួសារក្នុងការត្រៀមខ្លួន ទប់ទល់ សម្របខ្លួន និងស្តារសកម្មភាពសេដ្ឋកិច្ចឡើងវិញ នៅពេលជួបប្រទះហានិភ័យ ឬវិបត្តិ ដើម្បីរក្សាជីវភាព និងប្រភពចំណូល។
១៨	**និរន្តរភាពមុខរបរ**	សំដៅដល់លទ្ធភាពដែលមុខរបរអាចបន្តដំណើរការ រក្សាប្រសិទ្ធភាព និងបង្កើតផលប្រយោជន៍សេដ្ឋកិច្ចក្នុងរយៈពេលវែង ដោយប្រើប្រាស់ធនធាន និងគ្រប់គ្រងហានិភ័យបានសមស្រប។

បរិសិដ្ឋទី២. ពាក្យបច្ចេកទេសគាំទ្រការអនុវត្ត និងការគាមដានវាយតម្លៃ

ល.រ	ពាក្យបច្ចេកទេស	និយមន័យ និងការពន្យល់
១៩	**សកម្មភាពសេដ្ឋកិច្ចគ្រួសារ**	សំដៅដល់សកម្មភាពផលិតកម្ម ការកែច្នៃ ការជួញដូរ ការផ្តល់សេវាកម្ម និងសកម្មភាពផ្សេងទៀតដែលសមាជិកគ្រួសារអនុវត្ត ដើម្បីបង្កើតតម្លៃសេដ្ឋកិច្ច ឬប្រាក់ចំណូល។
២០	**ប្រភពចំណូលគ្រួសារ**	សំដៅដល់ប្រភពដែលគ្រួសារទទួលបានប្រាក់ចំណូលពីការងារ មុខរបរអាជីវកម្ម ការផលិត ការផ្តល់សេវាកម្ម ឬប្រភពផ្សេងទៀត ដូចជាប្រាក់ឈ្នួល និងប្រាក់ផ្ញើពីសមាជិកគ្រួសារ។
២១	**តម្លៃបន្ថែម**	សំដៅដល់តម្លៃសេដ្ឋកិច្ចដែលបានបង្កើតបន្ថែម តាមរយៈសកម្មភាពផលិតកម្ម ការកែច្នៃ ការកែលម្អគុណភាព ការរៀចខ្ចប់ ឬការផ្តល់សេវាកម្មដែលធ្វើឱ្យផលិតផល ឬសេវាកម្មមានតម្លៃកាន់តែខ្ពស់។
២២	**ផែនការអាជីវកម្ម**	សំដៅដល់ឯកសារដែលកំណត់គោលបំណង សកម្មភាព ទុន ចំណាយ ចំណូល ទីផ្សារ ហានិភ័យ និងវិធីសាស្ត្រគ្រប់គ្រងមុខរបរ ដើម្បីតម្រង់ទិសការបង្កើត និងអភិវឌ្ឍអាជីវកម្ម។
២៣	**បច្ចេកវិទ្យាឌីជីថល**	សំដៅដល់ឧបករណ៍ ប្រព័ន្ធ ឬកម្មវិធីដែលប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងទំនាក់ទំនង ដើម្បីគាំទ្រការគ្រប់គ្រង ការផ្សព្វផ្សាយ ការទំនាក់ទំនង ការលក់ និងការធ្វើអាជីវកម្ម។
២៤	**គ្រួសារគោលដៅ**	សំដៅដល់គ្រួសារនៅតំបន់ជនបទដែលត្រូវបានជ្រើសរើសតាមលក្ខណៈវិនិច្ឆ័យរបស់ផែនការ ឬកម្មវិធី ដើម្បីទទួលបានការពង្រឹងសមត្ថភាព ការគាំទ្របច្ចេកទេស ឬធនធានសម្រាប់បង្កើត និងអភិវឌ្ឍមុខរបរ។
២៥	**ការគាំទ្រធនធាន**	សំដៅដល់ការផ្តល់ ឬសម្របសម្រួលឱ្យទទួលបានធនធានចាំបាច់ ដូចជា ទុន សម្ភារ ឧបករណ៍ ជាតុចូល និងប្រភពហិរញ្ញប្បទាន ស្របតាមលទ្ធភាព និងយន្តការគាំទ្រដែលបានកំណត់។
២៦	**ការបង្ហាញមុខរបរគំរូ**	សំដៅដល់ការរៀបចំសកម្មភាពបង្ហាញពីវិធីសាស្ត្រ បច្ចេកទេស ដំណើរការ និងលទ្ធផលនៃការអនុវត្តមុខរបរគំរូ ដើម្បីឱ្យគ្រួសារ ក្រុម និងសហគមន៍គោលដៅអាចសិក្សា រៀនសូត្រ និងយកទៅអនុវត្តបន្ត។
២៧	**សូចនាករ**	សំដៅដល់ង្វាស់បរិមាណ ឬគុណភាពដែលប្រើប្រាស់សម្រាប់តាមដាន និងវាយតម្លៃវឌ្ឍនភាព សមិទ្ធផល និងលទ្ធផលនៃការអនុវត្តផែនការយុទ្ធសាស្ត្រ។
២៨	**ទិន្នន័យផ្នាំគោល**	សំដៅដល់ព័ត៌មាន ឬតម្លៃសូចនាករដែលបានកំណត់នៅឆ្នាំយោង ឬមុនការអនុវត្តអន្តរាគមន៍ ដើម្បីប្រើជាមូលដ្ឋានសម្រាប់ប្រៀបធៀប និងវាស់វែងការផ្លាស់ប្តូរ។

២៩	**ការតាមដាន**	សំដៅដល់ដំណើរការប្រមូល ពិនិត្យ និងវិភាគទិន្នន័យជាប្រចាំ ដើម្បីវាស់វែងវឌ្ឍនភាពនៃការអនុវត្តសកម្មភាព ការប្រើប្រាស់ធនធាន និងការសម្រេចគោលដៅដែលបានកំណត់។
៣០	**ការវាយតម្លៃ**	សំដៅដល់ដំណើរការពិនិត្យ និងវិភាគជាប្រព័ន្ធ ដោយផ្អែកលើទិន្នន័យ និងភស្តុតាង ដើម្បីវាយតម្លៃភាពពាក់ព័ន្ធ ប្រសិទ្ធភាព ប្រសិទ្ធផល លទ្ធផល និងនិរន្តរភាពនៃការអនុវត្តផែនការយុទ្ធសាស្ត្រ។

បរិសិដ្ឋទី៣. ម៉ាទ្រីសបង្ហាញពីសកម្មភាពអាទិភាព និងលទ្ធផលរំពឹងទុក

ដើម្បីធានាឱ្យការអនុវត្តផែនការយុទ្ធសាស្ត្រស្តីពី ការធ្វើពិពិធកម្មសេដ្ឋកិច្ចគ្រួសារនៅតំបន់ជនបទ ឆ្នាំ២០២៦-២០៣៣ មានភាពច្បាស់លាស់ ប្រទាក់ក្រឡា និងអាចវាស់វែងលទ្ធផលបាន ផែនការយុទ្ធសាស្ត្រនេះបានរៀបចំម៉ាទ្រីសសកម្មភាពអាទិភាព និងលទ្ធផលរំពឹងទុក ដោយផ្អែកលើយុទ្ធសាស្ត្រទាំង៤ និងសកម្មភាពអាទិភាពដែលបានកំណត់។ តារាងម៉ាទ្រីសនេះបង្ហាញពីទំនាក់ទំនងរវាងសកម្មភាពអាទិភាពនិមួយៗ និងលទ្ធផលរំពឹងទុក ដើម្បីជាមូលដ្ឋានសម្រាប់ការរៀបចំផែនការអនុវត្ត ការបែងចែកការទទួលខុសត្រូវ ការកំណត់តម្រូវការធនធាន និងការតាមដាន វាយតម្លៃលទ្ធផល។ សកម្មភាពអាទិភាព និងលទ្ធផលរំពឹងទុកតាមយុទ្ធសាស្ត្រទាំង៤ មានបង្ហាញលម្អិតក្នុងតារាងខាងក្រោម៖

តារាងម៉ាទ្រីសសកម្មភាពអាទិភាព និងលទ្ធផលរំពឹងទុក

យុទ្ធសាស្ត្រទី១៖ ជំរុញបង្កើតនិងអភិវឌ្ឍការងារ និងមុខរបរនៅតំបន់ជនបទ		
ល.រ	សកម្មភាពអាទិភាព	លទ្ធផលរំពឹងទុក
១	សិក្សា វាយតម្លៃ និងកំណត់មុខរបរអាទិភាពដោយផ្អែកលើសក្តានុពលនិងធនធានមូលដ្ឋាន	មុខរបរអាទិភាពដែលមានសក្តានុពលនៅមូលដ្ឋានត្រូវបានកំណត់ សម្រាប់ជាមូលដ្ឋាននៃការគាំទ្របង្កើត និងអភិវឌ្ឍមុខរបរ។
២	រៀបចំនិងផ្សព្វផ្សាយផែនការគំរូអាជីវកម្មសម្រាប់មុខរបរដែលមានសក្តានុពលសេដ្ឋកិច្ច	ផែនការគំរូអាជីវកម្មសម្រាប់មុខរបរអាទិភាពត្រូវបានរៀបចំ ដើម្បីជួយគ្រួសារ ក្រុម និងសហគមន៍ក្នុងការជ្រើសរើស និងអនុវត្តប្រកបដោយប្រសិទ្ធភាព។
៣	ពង្រឹងសមត្ថភាពគ្រួសារ ក្រុម និងសហគមន៍ក្នុងការបង្កើត អភិវឌ្ឍ និងធ្វើពិពិធកម្មមុខរបរ	គ្រួសារ ក្រុម និងសហគមន៍គោលដៅមានចំណេះដឹង ជំនាញ និងសមត្ថភាពកាន់តែប្រសើរក្នុងការបង្កើត អភិវឌ្ឍ និងធ្វើពិពិធកម្មមុខរបរ។
៤	ជំរុញនិងគាំទ្រការចាប់ផ្តើមមុខរបរថ្មី និងការពង្រីកមុខរបរដែលមានស្រាប់របស់គ្រួសារ ក្រុម និងសហគមន៍នៅមូលដ្ឋាន	គ្រួសារ ក្រុម និងសហគមន៍គោលដៅអាចបង្កើតមុខរបរថ្មី ឬពង្រីកមុខរបរដែលមានស្រាប់ ដើម្បីបង្កើនឱកាសការងារ និងប្រភពចំណូល។
៥	គាំទ្រការបង្កើតនិងអភិវឌ្ឍមុខរបរ ឬផលិតផលគំរូ ដោយភ្ជាប់នឹងចលនា "ភូមិមួយ ផលិតផលមួយ"	មុខរបរ ឬផលិតផលគំរូដែលមានសក្តានុពលត្រូវបានបង្កើត និងអភិវឌ្ឍ ដោយផ្សារភ្ជាប់នឹងធនធានមូលដ្ឋាន អត្តសញ្ញាណ និងចលនា "ភូមិមួយ ផលិតផលមួយ"។

៦	ពង្រឹងសមត្ថភាពគ្រួសារ ក្រុម និងសហគមន៍គោលដៅក្នុងការគ្រប់គ្រងហានិភ័យ និងធានានិរន្តរភាពនៃមុខរបរ	គ្រួសារ ក្រុម និងសហគមន៍គោលដៅមានសមត្ថភាពកាន់តែប្រសើរក្នុងការកំណត់បង្ការ និងគ្រប់គ្រងហានិភ័យ ដើម្បីរក្សានិរន្តរភាពនៃមុខរបរ និងប្រភពចំណូល។
៧	រៀបចំ និងអនុវត្តកម្មវិធីបង្ហាញមុខរបរគំរូ ដើម្បីផ្សព្វផ្សាយ និងផ្ទេរបទពិសោធន៍	មុខរបរគំរូ និងបទពិសោធន៍អនុវត្តល្អត្រូវបានបង្ហាញ និងផ្សព្វផ្សាយ ដើម្បីជំរុញការរៀនសូត្រ ការយកទៅអនុវត្ត និងការពង្រីកមុខរបរនៅមូលដ្ឋាន។
៨	តាមដាន និងផ្តល់ការណែនាំបច្ចេកទេសដល់គ្រួសារដែលបានទទួលការគាំទ្រមុខរបរ	គ្រួសារដែលបានទទួលការគាំទ្រមុខរបរទទួលបានការណែនាំ និងជំនួយបច្ចេកទេសជាបន្តបន្ទាប់ ដើម្បីដោះស្រាយបញ្ហាប្រឈម កែលម្អការអនុវត្ត និងបង្កើននិរន្តរភាពនៃមុខរបរ។
យុទ្ធសាស្ត្រទី២៖ ជំរុញអភិវឌ្ឍសកម្មភាពសេដ្ឋកិច្ចគ្រួសារ ខ្សែច្រវាក់តម្លៃ និងការភ្ជាប់ទីផ្សារនៅតំបន់ជនបទ		
ល.រ	**សកម្មភាពអាទិភាព**	**លទ្ធផលរំពឹងទុក**
១	លើកកម្ពស់ការប្រើប្រាស់ធនធាន និងវត្ថុធាតុដើមក្នុងមូលដ្ឋានសម្រាប់បង្កើតនិងអភិវឌ្ឍមុខរបរ	ធនធាន និងវត្ថុធាតុដើមក្នុងមូលដ្ឋានត្រូវបានប្រើប្រាស់កាន់តែមានប្រសិទ្ធភាព និងចីរភាព សម្រាប់បង្កើត និងអភិវឌ្ឍមុខរបរ ព្រមទាំងបង្កើនតម្លៃសេដ្ឋកិច្ចនៅមូលដ្ឋាន
២	ពង្រឹងចំណេះដឹង និងសមត្ថភាពគ្រួសារ ក្រុម និងសហគមន៍ក្នុងការអភិវឌ្ឍមុខរបរតាមខ្សែច្រវាក់តម្លៃ	គ្រួសារ ក្រុម និងសហគមន៍គោលដៅមានចំណេះដឹង និងសមត្ថភាពក្នុងការអភិវឌ្ឍមុខរបរ និងចូលរួមក្នុងខ្សែច្រវាក់តម្លៃកាន់តែប្រសើរ។
៣	ជំរុញការសហការរវាងគ្រួសារ និងការធ្វើអាជីវកម្មជាក្រុម/សហគមន៍ ព្រមទាំងការប្រមូលផ្តុំ និងការទិញ-លក់រួម	កិច្ចសហការរវាងគ្រួសារ ក្រុម និងសហគមន៍ត្រូវបានពង្រឹង ដើម្បីបង្កើនប្រសិទ្ធភាពផលិតកម្ម ការប្រមូលផ្តុំផលិតផល អំណាចចរចា និងឱកាសទីផ្សារ។
៤	ផ្សព្វផ្សាយនិងបង្ហាញការប្រើប្រាស់នវានុវត្តន៍ បច្ចេកវិទ្យាសមស្រប និងបច្ចេកវិទ្យាឌីជីថលសម្រាប់មុខរបរ និងការធ្វើអាជីវកម្មនៅតំបន់ជនបទ	គ្រួសារ ក្រុម និងសហគមន៍គោលដៅមានការយល់ដឹង និងអាចយកនវានុវត្តន៍ បច្ចេកវិទ្យាសមស្រប និងឧបករណ៍ឌីជីថលទៅប្រើប្រាស់ក្នុងការអភិវឌ្ឍមុខរបរ និងការធ្វើអាជីវកម្ម។
៥	ពង្រឹងសមត្ថភាពកែច្នៃ កែលម្អគុណភាព និងបង្កើនតម្លៃបន្ថែមនៃផលិតផលមូលដ្ឋាន	គ្រួសារ ក្រុម និងសហគមន៍គោលដៅមានសមត្ថភាពកែច្នៃ និងកែលម្អគុណភាពផលិតផលកាន់តែប្រសើរ ដើម្បីបង្កើនតម្លៃបន្ថែម និងសមត្ថភាពប្រកួតប្រជែងទីផ្សារ

៦	ពង្រឹងចំណេះដឹងហិរញ្ញវត្ថុ និងសម្របសម្រួលការទទួលបានទុន ធនធាន ឧបករណ៍ និង សម្ភារសម្រាប់ការបង្កើត និងអភិវឌ្ឍមុខរបរ	គ្រួសារ ក្រុម និងសហគមន៍គោលដៅមានចំណេះដឹងហិរញ្ញវត្ថុកាន់តែប្រសើរ និងមានលទ្ធភាពទទួលបានទុន ធនធាន ឧបករណ៍ និងសម្ភារសមស្របសម្រាប់អភិវឌ្ឍមុខរបរ។
៧	ពង្រឹងសមត្ថភាពគ្រប់គ្រងក្រុមសន្សំ និងក្រុម/សហគមន៍ធុរកិច្ចក្នុង វិស័យកសិកម្ម សិប្បកម្ម សេវាកម្ម និងទេសចរណ៍	ក្រុមសន្សំ និងក្រុម/សហគមន៍ធុរកិច្ចគោលដៅមានសមត្ថភាពគ្រប់គ្រង ប្រតិបត្តិការ និងអភិវឌ្ឍសកម្មភាពសេដ្ឋកិច្ចកាន់តែប្រសើរ។
៨	ពង្រឹងចំណេះដឹងទីផ្សារ និងសម្របសម្រួលការតភ្ជាប់ទីផ្សារ ការផ្សព្វផ្សាយផលិតផល បណ្តាញអ្នកផ្គត់ផ្គង់ អ្នកប្រើប្រាស់ និងការពង្រីកទីផ្សារ	គ្រួសារ ក្រុម និងសហគមន៍គោលដៅមានចំណេះដឹងទីផ្សារ បណ្តាញទំនាក់ទំនងអាជីវកម្ម និងឱកាសចូលទៅកាន់ទីផ្សារកាន់តែប្រសើរ។
៩	លើកកម្ពស់ការចូលរួមរបស់យុវជន ស្ត្រី ជនមានពិការភាព និងគ្រួសារងាយរងគ្រោះក្នុងការបង្កើត អភិវឌ្ឍមុខរបរ និងសកម្មភាពសេដ្ឋកិច្ច	យុវជន ស្ត្រី ជនមានពិការភាព និងគ្រួសារងាយរងគ្រោះមានឱកាស និងការចូលរួមកាន់តែច្រើនក្នុងការបង្កើត និងអភិវឌ្ឍមុខរបរ និងសកម្មភាពសេដ្ឋកិច្ច។
១០	រៀបចំ និងអនុវត្តកម្មវិធីបង្ហាញ និងផ្សព្វផ្សាយផលិតផលមូលដ្ឋាន ដើម្បីជំរុញការភ្ជាប់ទីផ្សារ	ផលិតផលមូលដ្ឋានត្រូវបានបង្ហាញ និងផ្សព្វផ្សាយកាន់តែទូលំទូលាយ ព្រមទាំងមានការតភ្ជាប់ជាមួយអ្នកទិញ និងបណ្តាញទីផ្សារថ្មីៗ។
យុទ្ធសាស្ត្រទី៣៖ ពង្រឹង និងគាំទ្រមជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទ សម្រាប់ការអភិវឌ្ឍជំនាញ សហគ្រិនភាព និងនវានុវត្តន៍		
ល.រ	**សកម្មភាពអាទិភាព**	**លទ្ធផលរំពឹងទុក**
១	រៀបចំនិងអនុវត្តការបណ្តុះបណ្តាលជំនាញបច្ចេកទេស និងវិជ្ជាជីវៈសមស្របតាមមុខរបរអាទិភាព និងតម្រូវការទីផ្សារ	ប្រជាពលរដ្ឋគោលដៅមានចំណេះដឹង និងជំនាញបច្ចេកទេស វិជ្ជាជីវៈសមស្របតាមមុខរបរអាទិភាព និងតម្រូវការទីផ្សារ សម្រាប់បង្កើតការងារ និងអភិវឌ្ឍមុខរបរ។
២	ពង្រឹងបំណិនជីវិតនិងសមត្ថភាពគ្រប់គ្រងមុខរបររបស់គ្រួសារ ក្រុម និងសហគមន៍នៅមូលដ្ឋាន	គ្រួសារ ក្រុម និងសហគមន៍គោលដៅមានបំណិនជីវិត និងសមត្ថភាពគ្រប់គ្រងមុខរបរកាន់តែប្រសើរ ដើម្បីអនុវត្តមុខរបរប្រកបដោយប្រសិទ្ធភាព។

៣	អភិរក្ស ផ្ទេរជំនាញ និងធ្វើទំនើបកម្មវិជ្ជាជីវៈដូនតាដែលមានសក្តានុពលសេដ្ឋកិច្ច និងវប្បធម៌	ជំនាញ និងវិជ្ជាជីវៈដូនតាដែលមានសក្តានុពលត្រូវបានអភិរក្ស ផ្ទេរទៅអ្នកជំនាន់ក្រោយ និងកែលម្អឱ្យសមស្របនឹងតម្រូវការទីផ្សារ ដោយរក្សាអត្តសញ្ញាណវប្បធម៌មូលដ្ឋាន។
៤	ពង្រឹងសមត្ថភាពសហគ្រិនភាព និងនវានុវត្តន៍សម្រាប់ការបង្កើត និងអភិវឌ្ឍមុខរបរ	ប្រជាពលរដ្ឋគោលដៅមានចំណេះដឹង សមត្ថភាពសហគ្រិនភាព និងការច្នៃប្រឌិតកាន់តែប្រសើរ សម្រាប់បង្កើត និងអភិវឌ្ឍមុខរបរ។
៥	លើកកម្ពស់ការចូលរួម និងអភិវឌ្ឍសមត្ថភាពក្រុមយុវជន ស្ត្រី ជនមានពិការភាព និងក្រុមគ្រួសារងាយរងគ្រោះក្នុងការបង្កើត និងអភិវឌ្ឍមុខរបរប្រកបដោយបរិយាបន្ន	យុវជន ស្ត្រី ជនមានពិការភាព និងគ្រួសារងាយរងគ្រោះទទួលបានឱកាសអភិវឌ្ឍជំនាញ និងសមត្ថភាពសម្រាប់បង្កើត និងអភិវឌ្ឍមុខរបរប្រកបដោយបរិយាបន្ន។
៦	បង្កើតនិងពង្រឹងយន្តការតាមដាន បង្វឹក ប្រឹក្សាយោបល់ និងគាំទ្របច្ចេកទេសដល់អ្នកទទួលការបណ្តុះបណ្តាលក្នុងការអនុវត្ត និងការអភិវឌ្ឍមុខរបរ	យន្តការតាមដាន បង្វឹក និងផ្តល់ប្រឹក្សាបច្ចេកទេសត្រូវបានបង្កើត និងដំណើរការដើម្បីជួយអ្នកទទួលការបណ្តុះបណ្តាលយកជំនាញទៅអនុវត្ត និងអភិវឌ្ឍមុខរបរជាក់ស្តែង។
៧	រៀបចំ និងអនុវត្តកម្មវិធីបង្ហាញ និងផ្ទេរជំនាញតាមរយៈការអនុវត្តជាក់ស្តែងនៅមជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទ។	មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទមានកម្មវិធីបង្ហាញ និងផ្ទេរជំនាញតាមរយៈការអនុវត្តជាក់ស្តែង ដែលជួយឱ្យអ្នកចូលរួមអាចយកចំណេះដឹង និងជំនាញទៅអនុវត្តក្នុងមុខរបរ។
យុទ្ធសាស្ត្រទី៤៖ ពង្រឹងតួនាទីថ្នាក់ក្រោមជាតិក្នុងការសម្របសម្រួល សហការ និងគាំទ្រការអនុវត្តពិពិធកម្មសេដ្ឋកិច្ចគ្រួសារនៅតំបន់ជនបទ		
ល.រ	**សកម្មភាពអាទិភាព**	**លទ្ធផលរំពឹងទុក**
១	សម្របសម្រួលនិងសហការក្នុងការសិក្សា និងកំណត់មុខរបរអាទិភាពនៅមូលដ្ឋាន	អង្គភាពថ្នាក់ក្រោមជាតិមានការសហការ និងសម្របសម្រួលប្រកបដោយប្រសិទ្ធភាពក្នុងការសិក្សា វាយតម្លៃ និងកំណត់មុខរបរអាទិភាពសមស្របតាមសក្តានុពលមូលដ្ឋាន។
២	សម្របសម្រួលនិងសហការក្នុងការពង្រឹងសមត្ថភាពប្រជាពលរដ្ឋ និងការបង្ហាញមុខរបរគំរូ	ការបណ្តុះបណ្តាល ពង្រឹងសមត្ថភាព និងបង្ហាញមុខរបរគំរូនៅមូលដ្ឋានត្រូវបានសម្របសម្រួល និងគាំទ្រឱ្យអនុវត្តប្រកបដោយប្រសិទ្ធភាព។

៣	សម្របសម្រួលនិងគាំទ្រការបង្កើត អភិវឌ្ឍ និងធ្វើពិពិធកម្មមុខរបរនៅមូលដ្ឋាន	គ្រួសារ ក្រុម និងសហគមន៍គោលដៅទទួលបានការសម្របសម្រួល និងការគាំទ្រពីអង្គភាពថ្នាក់ក្រោមជាតិ និងភាគីពាក់ព័ន្ធក្នុងការបង្កើត អភិវឌ្ឍ និងធ្វើពិពិធកម្មមុខរបរ។
៤	សម្របសម្រួលនិងសហការក្នុងការពង្រឹងសមត្ថភាព និងការគ្រប់គ្រងក្រុមសន្សំ និងឥណទានជនបទ	ក្រុមសន្សំ និងឥណទានជនបទគោលដៅទទួលបានការសម្របសម្រួល និងការពង្រឹងសមត្ថភាពគ្រប់គ្រង ការប្រតិបត្តិការប្រកបដោយប្រសិទ្ធភាព និងការទទួលខុសត្រូវ។

បរិសិដ្ឋទី៤. ផែនការអនុវត្តសកម្មភាព ឆ្នាំ២០២៦-២០៣៣

ផែនការអនុវត្តសកម្មភាពនេះត្រូវបានរៀបចំឡើង ដើម្បីកំណត់លំដាប់អាទិភាព និងពេលវេលាអនុវត្តសកម្មភាពអាទិភាពតាមយុទ្ធសាស្ត្រទាំង៤ សំដៅធានាឱ្យការអនុវត្តផែនការយុទ្ធសាស្ត្រស្តីពី ការធ្វើពិពិធកម្មសេដ្ឋកិច្ចគ្រួសារនៅតំបន់ជនបទ ឆ្នាំ២០២៦-២០៣៣ មានភាពច្បាស់លាស់ ប្រទាក់ក្រឡា និងសមស្របតាមលទ្ធភាពធនធាន និងសមត្ថភាពអនុវត្តរបស់អង្គភាពពាក់ព័ន្ធ។

ដើម្បីធានាបាននូវភាពជាក់ស្តែង និងសមស្របតាមលំដាប់អាទិភាពការងារ ការអនុវត្តផែនការយុទ្ធសាស្ត្រត្រូវបានបែងចែកជា២ ដំណាក់កាលដូចខាងក្រោម៖

១. ដំណាក់កាលទី១ ឆ្នាំ២០២៦-២០២៨ ៖ ការរៀបចំ និងចាប់ផ្តើមអនុវត្ត

- **ឆ្នាំ២០២៦ ៖** រៀបចំផែនការអនុវត្ត យន្តការសម្របសម្រួល សិក្សាសក្តានុពលមុខរបរនៅមូលដ្ឋាន និងរៀបចំលក្ខខណ្ឌចាំបាច់សម្រាប់ការអនុវត្ត។
- **ឆ្នាំ២០២៧-២០២៨ ៖** ចាប់ផ្តើមអនុវត្តសកម្មភាពពង្រឹងសមត្ថភាពគ្រួសារគោលដៅ និងគាំទ្រការបង្កើត និងអភិវឌ្ឍមុខរបរគំរូ ព្រមទាំងតាមដាន និងផ្តល់ការណែនាំបច្ចេកទេស។
- **ចុងឆ្នាំ២០២៨ ៖** បូកសរុប និងវាយតម្លៃលទ្ធផលអនុវត្តដំណាក់កាលទី១ ដើម្បីកំណត់បទពិសោធន៍ បញ្ហាប្រឈម និងវិធានការកែលម្អសម្រាប់ដំណាក់កាលបន្ទាប់។

២. ដំណាក់កាលទី២ ឆ្នាំ២០២៩-២០៣៣ ៖ ការពង្រឹង និងពង្រីកការអនុវត្ត

- **ឆ្នាំ២០២៩-២០៣១ ៖** បន្តពង្រឹង និងពង្រីកសកម្មភាពអាទិភាពដែលទទួលបានលទ្ធផលល្អ ដោយផ្អែកលើលទ្ធផលវាយតម្លៃដំណាក់កាលទី១ និងសក្តានុពលមូលដ្ឋាន។

- **ឆ្នាំ២០៣២-២០៣៣ ៖** បន្តពង្រីក និងពង្រឹងនិរន្តរភាពនៃមុខរបរ និងលទ្ធផលដែលសម្រេចបាន ព្រមទាំងបូកសរុបបទពិសោធន៍ និងរៀបចំការវាយតម្លៃបញ្ចប់ផែនការ។
- **ចុងឆ្នាំ២០៣៣ ៖** វាយតម្លៃបញ្ចប់ផែនការយុទ្ធសាស្ត្រ ដើម្បីវាស់វែងលទ្ធផលសម្រេចបានធៀបនឹងគោលដៅ និងសូចនាករដែលបានកំណត់។

កាលវិភាគអនុវត្តសកម្មភាពអាទិភាពតាមយុទ្ធសាស្ត្រទាំង៤ និងដំណាក់កាលទាំង២ មានបង្ហាញលម្អិតក្នុងតារាងខាងក្រោម។

តារាងបែងចែកពេលវេលានៃការអនុវត្តសកម្មភាពអាទិភាព តាមយុទ្ធសាស្ត្រនិមួយៗ

ល.រ	យុទ្ធសាស្ត្រទី១៖ ជំរុញបង្កើត និងអភិវឌ្ឍការងារ និងមុខរបរនៅតំបន់ជនបទ			ពេលវេលា
	ការអនុវត្តសកម្មភាពអាទិភាព	**ដំណាក់កាលទី១**	**ដំណាក់កាលទី២**	
១	សិក្សា វាយតម្លៃ និងកំណត់មុខរបរអាទិភាព	ចាប់ផ្តើម	បន្តតាមទីតាំងថ្មី	២០២៦-២០៣០
២	រៀបចំ និងផ្សព្វផ្សាយផែនការគំរូអាជីវកម្ម	ចាប់ផ្តើម	កែលម្អនិងផ្សព្វផ្សាយបន្ត	២០២៦-២០៣១
៣	ពង្រឹងសមត្ថភាពគ្រួសារ ក្រុម និងសហគមន៍	ចាប់ផ្តើម	បន្ត និងពង្រីក	២០២៧-២០៣៣
៤	គាំទ្រការចាប់ផ្តើម និងពង្រីកមុខរបរ	ចាប់ផ្តើម	បន្ត និងពង្រីក	២០២៧-២០៣៣
៥	គាំទ្រការបង្កើត និងអភិវឌ្ឍមុខរបរគំរូ	ចាប់ផ្តើម	បន្ត និងពង្រីក	២០២៧-២០៣៣
៦	ពង្រឹងការគ្រប់គ្រងហានិភ័យ និងនិរន្តរភាពមុខរបរ	ចាប់ផ្តើម	បន្ត	២០២៧-២០៣៣
៧	បង្ហាញមុខរបរគំរូ និងផ្ទេរបទពិសោធន៍	ចាប់ផ្តើម ២០២៨	ពង្រីក	២០២៨-២០៣៣
៨	តាមដាន និងផ្តល់ការណែនាំបច្ចេកទេស	ចាប់ផ្តើម	បន្ត	២០២៧-២០៣៣
ល.រ	យុទ្ធសាស្ត្រទី២៖ អភិវឌ្ឍសកម្មភាពសេដ្ឋកិច្ច ខ្សែច្រវាក់តម្លៃ និងការភ្ជាប់ទីផ្សារ			ពេលវេលា
	ការអនុវត្តសកម្មភាពអាទិភាព	**ដំណាក់កាលទី១**	**ដំណាក់កាលទី២**	
១	ប្រើប្រាស់ធនធាន និងវត្ថុធាតុដើមមូលដ្ឋាន	ចាប់ផ្តើម	បន្ត	២០២៧-២០៣៣
២	ពង្រឹងសមត្ថភាពអភិវឌ្ឍមុខរបរតាមខ្សែច្រវាក់តម្លៃ	ចាប់ផ្តើម	បន្ត និងពង្រីក	២០២៧-២០៣៣
៣	ជំរុញការសហការធ្វើអាជីវកម្មជាក្រុម និងសហគមន៍	ចាប់ផ្តើម	ពង្រឹង និងពង្រីក	២០២៧-២០៣៣
៤	ផ្សព្វផ្សាយនវានុវត្តន៍ និងបច្ចេកវិទ្យាសមស្រប	ចាប់ផ្តើម	បន្ត	២០២៧-២០៣៣

៥	ពង្រឹងសមត្ថភាពកែច្នៃ គុណភាព និងតម្លៃបន្ថែម	ចាប់ផ្តើម	បន្ត និងពង្រីក	២០២៧-២០៣៣
៦	ពង្រឹងចំណេះដឹងហិរញ្ញវត្ថុ និងសម្របសម្រួលធនធាន	ចាប់ផ្តើម	បន្ត	២០២៧-២០៣៣
៧	ពង្រឹងសមត្ថភាពក្រុមសន្សំ និងក្រុមសហគមន៍ធុរកិច្ច	ចាប់ផ្តើម	បន្ត	២០២៧-២០៣៣
៨	ពង្រឹងចំណេះដឹងទីផ្សារ និងការតភ្ជាប់ទីផ្សារ	ចាប់ផ្តើម	ពង្រីក	២០២៧-២០៣៣
៩	លើកកម្ពស់ការចូលរួមរបស់ក្រុមគោលដៅងាយរងគ្រោះ	ចាប់ផ្តើម	បន្ត	២០២៧-២០៣៣
១០	បង្ហាញ និងផ្សព្វផ្សាយផលិតផលមូលដ្ឋាន	ចាប់ផ្តើម២០២៨	ពង្រីក	២០២៨-២០៣៣
ល.រ	យុទ្ធសាស្ត្រទី៣៖ ពង្រឹង និងគាំទ្រមជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទ			ពេលវេលា
	ការអនុវត្តសកម្មភាពអាទិភាព	**ដំណាក់កាលទី១**	**ដំណាក់កាលទី២**	
១	រៀបចំ និងអនុវត្តការបណ្តុះបណ្តាលជំនាញបច្ចេកទេស និងវិជ្ជាជីវៈ	ចាប់ផ្តើម	បន្ត និងពង្រឹង	២០២៧–២០៣៣
២	ពង្រឹងបំណិនជីវិត និងការគ្រប់គ្រងមុខរបរ	ចាប់ផ្តើម	បន្ត និងពង្រឹង	២០២៧–២០៣៣
៣	អភិរក្ស និងផ្ទេរជំនាញវិជ្ជាជីវៈដូនតា	ចាប់ផ្តើម	បន្ត និងពង្រឹង	២០២៧–២០៣៣
៤	ពង្រឹងសហគ្រិនភាព និងនវានុវត្តន៍	ចាប់ផ្តើម	បន្ត និងពង្រឹង	២០២៧–២០៣៣
៥	លើកកម្ពស់ការចូលរួម និងអភិវឌ្ឍសមត្ថភាពក្រុមគោលដៅ	ចាប់ផ្តើម	បន្ត និងពង្រឹង	២០២៧–២០៣៣
៦	តាមដាន បង្វឹកនិងប្រឹក្សាយោបល់ដល់អ្នកទទួលការបណ្តុះបណ្តាល	ចាប់ផ្តើម	បន្ត និងពង្រឹង	២០២៧–២០៣៣
៧	បង្ហាញ និងផ្ទេរជំនាញតាមរយៈការអនុវត្តជាក់ស្តែង	ចាប់ផ្តើមឆ្នាំ២០២៨	បន្ត និងពង្រីក	២០២៨–២០៣៣
ល.រ	យុទ្ធសាស្ត្រទី៤៖ ពង្រឹងតួនាទីថ្នាក់ក្រោមជាតិក្នុងការសហការ សម្របសម្រួល និងគាំទ្រការអនុវត្តរបស់ថ្នាក់ជាតិ			ពេលវេលា
	ការអនុវត្តសកម្មភាពអាទិភាព	**ដំណាក់កាលទី១**	**ដំណាក់កាលទី២**	
១	សម្របសម្រួលការសិក្សា និងកំណត់មុខរបរអាទិភាព	រៀបចំ និងចាប់ផ្តើម	បន្ត និងពង្រឹង	២០២៦–២០៣៣
២	សម្របសម្រួលការពង្រឹងសមត្ថភាព និងការបង្ហាញមុខរបរគំរូ	ចាប់ផ្តើម	បន្ត និងពង្រឹង	២០២៧–២០៣៣
៣	សម្របសម្រួល និងគាំទ្រការបង្កើត អភិវឌ្ឍ និងធ្វើពិពិធកម្មមុខរបរ	ចាប់ផ្តើម	បន្ត និងពង្រឹង	២០២៧–២០៣៣
៤	សម្របសម្រួលការពង្រឹងសមត្ថភាពក្រុមសន្សំ និងឥណទានជនបទ	ចាប់ផ្តើម	បន្ត និងពង្រឹង	២០២៧–២០៣៣

បរិសិដ្ឋទី៥. តម្រូវការធនធានហិរញ្ញវត្ថុ និងប្រភពហិរញ្ញប្បទាន

ដើម្បីធានាឱ្យការអនុវត្តផែនការយុទ្ធសាស្ត្រស្តីពី ការធ្វើពិពិធកម្មសេដ្ឋកិច្ចគ្រួសារនៅតំបន់ជនបទ ឆ្នាំ២០២៦-២០៣៣ ប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាព និងសម្រេចបានតាមគោលដៅដែលបានកំណត់ ការរៀបចំ និងកៀរគរធនធានហិរញ្ញវត្ថុត្រូវផ្អែកលើតម្រូវការអនុវត្តសកម្មភាពអាទិភាពតាមយុទ្ធសាស្ត្រទាំង៤ និងដំណាក់កាលអនុវត្តទាំង២ ដោយគិតគូរពីលំដាប់អាទិភាពការងារ ទំហំសកម្មភាព និងលទ្ធភាពធនធានជាក់ស្តែង។

ថវិកាជាតិជាប្រភពហិរញ្ញប្បទានចម្បងសម្រាប់ការអនុវត្តផែនការយុទ្ធសាស្ត្រនេះ ដោយមានការកៀរគរការគាំទ្របន្ថែមពីដៃគូអភិវឌ្ឍន៍ និងភាគីពាក់ព័ន្ធ តាមរយៈជំនួយហិរញ្ញវត្ថុ បច្ចេកទេស សម្ភារ និងធនធានផ្សេងៗ ស្របតាមតម្រូវការអនុវត្ត និងយន្តការសហការដែលបានកំណត់។ ការប៉ាន់ប្រមាណតម្រូវការថវិកា និងការកំណត់ប្រភពហិរញ្ញប្បទាន ត្រូវធ្វើឡើងដោយផ្អែកលើផែនការអនុវត្តប្រចាំឆ្នាំ លទ្ធភាពថវិកា និងនីតិវិធីហិរញ្ញវត្ថុសាធារណៈជាធរមាន។ តម្រូវការធនធានហិរញ្ញវត្ថុ និងប្រភពហិរញ្ញប្បទានសម្រាប់ការអនុវត្តផែនការយុទ្ធសាស្ត្រនេះ ដូចមានបង្ហាញលម្អិតក្នុងតារាងខាងក្រោម។

តារាងតម្រូវការធនធានហិរញ្ញវត្ថុ និងប្រភពហិរញ្ញប្បទាន

កាលបរិច្ឆេទ	ថវិកា(គិតជាខ្នង់លានរៀល)					ប្រភពធនធាន និងថវិកា (២០២៦-២០៣៣)
	យុទ្ធសាស្ត្រទី១	**យុទ្ធសាស្ត្រទី២**	**យុទ្ធសាស្ត្រទី៣**	**យុទ្ធសាស្ត្រទី៤**	**សរុបក្នុងឆ្នាំ**	
បានចំណាយ ឆ្នាំ២០២៦	១៤១.១	១៦៨.០	៨៣៧.៩	៥២៤.០	**១,៦៧១.០**	ថវិកាជាតិ និងដៃគូ
គ្រោងចំណាយ ឆ្នាំ២០២៧	១៤១.១	១៦៨.៧	៨៣៧.៩	៣៣០.៣	**១,៤៧៨.០**	ថវិកាជាតិ និងដៃគូ
គ្រោងចំណាយ ឆ្នាំ២០២៨	១៥៥.២	១៨៥.៦	៩៤១.៨	៣៦៣.៣	**១,៦៤៥.៩**	ថវិកាជាតិ និងដៃគូ
គ្រោងចំណាយ ឆ្នាំ២០២៩	១៧០.៧	២០៤.១	១,០៦០.១	៣៩៩.៧	**១,៨៣៤.៦**	ថវិកាជាតិ និងដៃគូ
គ្រោងចំណាយ ឆ្នាំ២០៣០	១៨៧.៨	២២៤.៥	១,១៩៥.១	៤៣៩.៦	**២,០៩១.០**	ថវិកាជាតិ និងដៃគូ
គ្រោងចំណាយ ឆ្នាំ២០៣១	២០៦.៦	២៤៧.០	១,៣៤៩.៤	៤៨៣.៦	**២,២៨៦.៦**	ថវិកាជាតិ និងដៃគូ
គ្រោងចំណាយ ឆ្នាំ២០៣២	២២៧.២	២៧១.៧	១,៥២៦.១	៥៣២.០	**២,៥៥៧.០**	ថវិកាជាតិ និងដៃគូ
គ្រោងចំណាយ ឆ្នាំ២០៣៣	២៥០.០	២៩៨.៩	១,៧២៨.៧	៥៨៥.១	**២,៨៦២.៧**	ថវិកាជាតិ និងដៃគូ
សរុបចំណាយរួម	១,៤៧៩.៧	១,៧៦៨.៥	៩,៤៧៧.០	៣,៦៥៧.៦	១៦,៣៨២.៨	



បរិសិដ្ឋទី៦. ក្របខណ្ឌលទ្ធផល និងសូចនាករ

ដើម្បីឱ្យការកំណត់តម្លៃគោលដៅសូចនាករមានភាពប្រាកដនិយម និងអាចអនុវត្តបាន ផែនការយុទ្ធសាស្ត្រនេះ ត្រូវបានកំណត់សូចនាករគោលដៅជាក់លាក់គឺ ចំនួនគ្រួសារគោលដៅទទួលបានការពង្រឹងសមត្ថភាព និងចំនួនមុខរបរគំរូដែលបានគាំទ្រ ដោយផ្អែកលើសមត្ថភាពអង្គភាពអនុវត្ត ធនធានមនុស្ស ថវិកាប្រចាំឆ្នាំ និងការគាំទ្រពីដៃគូពាក់ព័ន្ធ សូចនាករគោលដៅត្រូវបែងចែកជា២ ដំណាក់កាល ដូចខាងក្រោម៖

តារាងគោលដៅសូចនាករ ដំណាក់កាលទី១ ឆ្នាំ២០២៦-២០២៨

សូចនាករគោលដៅជាក់លាក់(ឆ្នាំ២០២៦-២០៣៣)	ឯកតាវាស់	ឆ្នាំ២០២៦ (N)	ឆ្នាំ២០២៧ (N+1)	ឆ្នាំ២០២៨ (N+2)
ក. ពង្រឹងសមត្ថភាពគ្រួសារគោលដៅចំនួន **៥៨ ៤០០គ្រួសារ** តាមរយៈការផ្តល់ចំណេះដឹង និងជំនាញ ដើម្បីជំរុញការបង្កើត អភិវឌ្ឍ និងធ្វើពិពិធកម្មមុខរបរ ព្រមទាំងពង្រីកឱកាសការងារនិងប្រភពចំណូលគ្រួសារ	នាក់/គ្រួសារ	៣ ១០០	៧ ៤០០	១២ ៩០០
ខ. ជំរុញការបង្កើតនិងអភិវឌ្ឍមុខរបរគំរូចំនួន **១៥០មុខរបរ** តាមរយៈការគាំទ្របច្ចេកទេស និងធនធាន ដើម្បីជំរុញនវានុវត្តន៍និងទំនើបកម្មមុខរបរ ព្រមទាំងបង្ហាញ និងផ្សព្វផ្សាយលទ្ធផលសម្រាប់ការរៀនសូត្រ និងពង្រីកការអនុវត្តបន្ត	មុខរបរគំរូ	០	៥	១៥

តារាងគោលដៅសូចនាករ ដំណាក់កាលទី២ ឆ្នាំ២០២៩-២០៣៣

សូចនាករគោលដៅជាក់លាក់(ឆ្នាំ២០២៦-២០៣៣)	ឯកតាវាស់	ឆ្នាំ២០២៩ (N+3)	ឆ្នាំ២០៣០ (N+4)	ឆ្នាំ២០៣១ (N+5)	ឆ្នាំ២០៣២ (N+6)	ឆ្នាំ២០៣៣ (N+7)
ក. ពង្រឹងសមត្ថភាពគ្រួសារគោលដៅចំនួន **៥៨ ៤០០គ្រួសារ** តាមរយៈការផ្តល់ចំណេះដឹង និងជំនាញ ដើម្បីជំរុញការបង្កើត អភិវឌ្ឍ និងធ្វើពិពិធកម្មមុខរបរ ព្រមទាំងពង្រីកឱកាសការងារនិងប្រភពចំណូលគ្រួសារ	នាក់/គ្រួសារ	១៩ ៦០០	២៧ ៥០០	៣៦ ៦០០	៤៦ ៩០០	៥៨ ៤០០
ខ. ជំរុញការបង្កើតនិងអភិវឌ្ឍមុខរបរគំរូចំនួន **១៥០មុខរបរ** តាមរយៈការគាំទ្របច្ចេកទេស និងធនធាន ដើម្បីជំរុញនវានុវត្តន៍និងទំនើបកម្មមុខរបរ ព្រមទាំងបង្ហាញ និងផ្សព្វផ្សាយលទ្ធផលសម្រាប់ការរៀនសូត្រ និងពង្រីកការអនុវត្តបន្ត	មុខរបរគំរូ	៣០	៥០	៧៥	១១០	១៥០





បរិសិដ្ឋទី៧. យន្តការអនុវត្ត និងការទទួលខុសត្រូវ

ការអនុវត្តផែនការយុទ្ធសាស្ត្រស្តីពី ការធ្វើពិពិធកម្មសេដ្ឋកិច្ចគ្រួសារនៅតំបន់ជនបទ ឆ្នាំ២០២៦-២០៣៣ ត្រូវអនុវត្តតាមយន្តការដឹកនាំ សម្របសម្រួល និងសហការរវាងអង្គភាពជំនាញនៅថ្នាក់ជាតិ មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទ និងអង្គភាពថ្នាក់ក្រោមជាតិ ដោយមានការបែងចែកតួនាទី និងការទទួលខុសត្រូវច្បាស់លាស់ ស្របតាមមុខងារ ភារកិច្ច និងសមត្ថកិច្ចរបស់អង្គភាពនិមួយៗ។ ក្នុងនោះ៖ នាយកដ្ឋានអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទទទួលខុសត្រូវដឹកនាំ និងអនុវត្តដោយផ្ទាល់នូវយុទ្ធសាស្ត្រទី១ និងទី២ ព្រមទាំងផ្តល់ការតម្រង់ទិស និងគាំទ្របច្ចេកទេសដល់ការអនុវត្តយុទ្ធសាស្ត្រទី៣។ មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទទទួលខុសត្រូវអនុវត្តយុទ្ធសាស្ត្រទី៣ ដោយផ្តោតលើការអភិវឌ្ឍជំនាញ សហគ្រិនភាព និងនវានុវត្តន៍។ ចំណែកអង្គភាពថ្នាក់ក្រោមជាតិ មានតួនាទីសម្របសម្រួល សហការ និងគាំទ្រការអនុវត្តសកម្មភាពនៅមូលដ្ឋាន ជាពិសេសក្នុងក្របខណ្ឌយុទ្ធសាស្ត្រទី៤។

ការអនុវត្តត្រូវធានាឱ្យមានភាពប្រទាក់ក្រឡាវាងការកំណត់មុខរបរអាទិភាព ការពង្រឹងសមត្ថភាព ការគាំទ្របង្កើត និងអភិវឌ្ឍមុខរបរ ការតភ្ជាប់ទីផ្សារ និងការតាមដានលទ្ធផល ដើម្បីសម្រេចគោលដៅរួមនៃផែនការយុទ្ធសាស្ត្រ។

តារាងយន្តការអនុវត្ត និងការទទួលខុសត្រូវតាមយុទ្ធសាស្ត្រ

ល.រ	យុទ្ធសាស្ត្រ	អង្គភាពទទួលខុសត្រូវចម្បង	អង្គភាពសហការ និងគាំទ្រ	តួនាទី និងការទទួលខុសត្រូវសំខាន់ៗ
១	**យុទ្ធសាស្ត្រទី១**	**នាយកដ្ឋានអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ**	• មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទ • មន្ទីរអភិវឌ្ឍន៍ជនបទ រាជធានី-ខេត្ត • ដៃគូពាក់ព័ន្ធ និង • អាជ្ញាធរមូលដ្ឋាន	– ដឹកនាំរៀបចំផែនការ និងអនុវត្តសកម្មភាពអាទិភាព – សិក្សា វាយតម្លៃ និងកំណត់មុខរបរអាទិភាពនៅមូលដ្ឋាន – រៀបចំ និងផ្សព្វផ្សាយផែនការគំរូអាជីវកម្ម – ពង្រឹងសមត្ថភាព និងគាំទ្រការបង្កើត អភិវឌ្ឍ និងធ្វើពិពិធកម្មមុខរបរ – គាំទ្រការបង្កើតមុខរបរគំរូ ការបង្ហាញ និងផ្ទេរបទពិសោធន៍ – តាមដាន ផ្តល់ការណែនាំបច្ចេកទេស និងវាយតម្លៃលទ្ធផលអនុវត្ត។
២	**យុទ្ធសាស្ត្រទី២**	**នាយកដ្ឋានអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ**	• មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទ • មន្ទីរអភិវឌ្ឍន៍ជនបទ រាជធានី-ខេត្ត • ស្ថាប័នពាក់ព័ន្ធ វិស័យឯកជន ដៃគូអភិវឌ្ឍន៍ និង អាជ្ញាធរ មូលដ្ឋាន	– ដឹកនាំ និងអនុវត្តសកម្មភាពអភិវឌ្ឍសេដ្ឋកិច្ចគ្រួសារ និងខ្សែច្រវាក់តម្លៃ – ជំរុញការប្រើប្រាស់ធនធានមូលដ្ឋាន និងការធ្វើអាជីវកម្មជាក្រុម ឬសហគមន៍ – គាំទ្រការកែច្នៃ កែលម្អគុណភាព និងបង្កើនតម្លៃបន្ថែមផលិតផល – ផ្សព្វផ្សាយនវានុវត្តន៍ និងបច្ចេកវិទ្យាសមស្រប – សម្របសម្រួលការទទួលបានទុន ធនធាន និងការតភ្ជាប់ទីផ្សារ – ជំរុញការចូលរួមរបស់ក្រុមគោលដៅ និងតាមដានលទ្ធផលអនុវត្ត។
៣	**យុទ្ធសាស្ត្រទី៣**	**មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទ**	• នាយកដ្ឋានអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ	– រៀបចំ និងអនុវត្តកម្មវិធីបណ្តុះបណ្តាលជំនាញបច្ចេកទេស វិជ្ជាជីវៈ បំណិនជីវិត និងសហគ្រិនភាព

ល.រ	យុទ្ធសាស្ត្រ	អង្គភាពទទួលខុសត្រូវចម្បង	អង្គភាពសហការ និងគាំទ្រ	តួនាទី និងការទទួលខុសត្រូវសំខាន់ៗ
			• គ្រឹះស្ថានបណ្តុះបណ្តាល និងដៃគូពាក់ព័ន្ធ • មន្ទីរអភិវឌ្ឍន៍ជនបទ រាជធានី-ខេត្ត និង • អាជ្ញាធរមូលដ្ឋាន	– រៀបចំកម្មវិធីបង្ហាញ និងផ្សេរដំនាញតាមរយៈការអនុវត្តជាក់ស្តែង – អភិរក្ស ផ្សេរដំនាញ និងធ្វើទំនើបកម្មវិជ្ជាជីវៈជូនតា – បង្កើតយន្តការបង្វឹក ប្រឹក្សាយោបល់ និងគាំទ្របច្ចេកទេសដល់អ្នកទទួលការបណ្តុះបណ្តាល – សហការជាមួយនាយកដ្ឋានអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទក្នុងការកំណត់មុខជំនាញ និងកម្មវិធីបណ្តុះបណ្តាលឱ្យស្របតាមមុខរបរអាទិភាព និងតម្រូវការទីផ្សារ – តាមដាននិងរាយការណ៍លទ្ធផលបណ្តុះបណ្តាល និងការយកដំនាញទៅអនុវត្ត។
៤	**យុទ្ធសាស្ត្រទី៤**	**មន្ទីរអភិវឌ្ឍន៍ជនបទ រាជធានី-ខេត្ត**	• នាយកដ្ឋានអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ • មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទ • អាជ្ញាធរមូលដ្ឋាន និងភាគីពាក់ព័ន្ធ	– សម្របសម្រួល និងសហការជាមួយនាយកដ្ឋានក្នុងការសិក្សា និងកំណត់មុខរបរអាទិភាព – សម្របសម្រួលការជ្រើសរើសតំបន់ គ្រួសារ ក្រុម និងសហគមន៍គោលដៅ – សហការរៀបចំការបណ្តុះបណ្តាល និងការបង្ហាញមុខរបរគំរូនៅមូលដ្ឋាន – គាំទ្រការបង្កើត អភិវឌ្ឍ និងធ្វើពិពិធកម្មមុខរបរ – សម្របសម្រួលការពង្រឹងសមត្ថភាព និងការគ្រប់គ្រងក្រុមសន្សំ និងឥណទានជនបទ – ចូលរួមតាមដាន ប្រមូលព័ត៌មាន និងរាយការណ៍វឌ្ឍនភាពអនុវត្តនៅមូលដ្ឋាន។

បរិសិដ្ឋទី៨៖ ក្របខណ្ឌតាមដាន ត្រួតពិនិត្យ វាយតម្លៃ និងរាយការណ៍

ក្របខ័ណ្ឌតាមដាន ត្រួតពិនិត្យ វាយតម្លៃ និងរាយការណ៍ ត្រូវបានរៀបចំឡើងដើម្បីតាមដានវឌ្ឍនភាព វាស់វែងលទ្ធផលសម្រេចបាន និងវាយតម្លៃប្រសិទ្ធភាពនៃការអនុវត្តផែនការយុទ្ធសាស្ត្រស្តីពី ការធ្វើពិពិធកម្មសេដ្ឋកិច្ចគ្រួសារនៅតំបន់ជនបទ ឆ្នាំ២០២៦–២០៣៣ ដោយផ្អែកលើសកម្មភាពអាទិភាព លទ្ធផលរំពឹងទុក សូចនាករ និងគោលដៅដែលបានកំណត់។

ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ត្រូវអនុវត្តជាប្រចាំតាមកាលកំណត់ ដោយផ្អែកលើទិន្នន័យ និងភស្តុតាងជាក់ស្តែង ព្រមទាំងមានការបែងចែកការទទួលខុសត្រូវច្បាស់លាស់តាមមុខងាររបស់អង្គភាពនិមួយៗ។ លទ្ធផលត្រូវរាយការណ៍ជាប្រចាំ ដើម្បីកំណត់បញ្ហាប្រឈម វិធានការកែលម្អ និងគាំទ្រការសម្រេចចិត្តក្នុងការអនុវត្តផែនការបន្ត។

តារាងទី១៖ កាលវិភាគតាមដាន និងវាយតម្លៃ

ការងារតាមដាន និងវាយតម្លៃ	កាលកំណត់អនុវត្ត	គោលបំណង
ការតាមដានការអនុវត្តសកម្មភាព	ប្រចាំត្រីមាស	ពិនិត្យវឌ្ឍនភាព កំណត់បញ្ហាប្រឈម និងស្វែងរកដំណោះស្រាយ
ការត្រួតពិនិត្យ និងបូកសរុបលទ្ធផល	ប្រចាំឆ្នាំ	ពិនិត្យការសម្រេចគោលដៅប្រចាំឆ្នាំ និងកំណត់វិធានការកែលម្អ
ការវាយតម្លៃលទ្ធផលដំណាក់កាលទី១	ចុងឆ្នាំ២០២៨	វាយតម្លៃលទ្ធផលដំណាក់កាលទី១ និងកំណត់ការកែលម្អសម្រាប់ ដំណាក់កាលទី២
ការវាយតម្លៃចុងផែនការ	ចុងឆ្នាំ២០៣៣	វាយតម្លៃលទ្ធផលសរុប និរន្តរភាព និងដកស្រង់មេរៀនបទពិសោធន៍

តារាងទី២៖ ក្របខណ្ឌតាមដាន ត្រួតពិនិត្យ វាយតម្លៃ និងរាយការណ៍

ល.រ	ការងារតាមដាន និងវាយតម្លៃ	មធ្យោបាយផ្ទៀងផ្ទាត់លទ្ធផល	ពេលវេលា	អង្គភាពទទួលខុសត្រូវ
១	តាមដានការអនុវត្តយុទ្ធសាស្ត្រទី១ និងទី២	របាយការណ៍អនុវត្ត បញ្ជីអ្នកទទួលផល និងលទ្ធផលចុះត្រួតពិនិត្យ	ប្រចាំត្រីមាស និងឆ្នាំ	នាយកដ្ឋានអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ
២	តាមដានការអនុវត្តយុទ្ធសាស្ត្រទី៣	របាយការណ៍បណ្តុះបណ្តាល និងលទ្ធផលតាមដានក្រោយបណ្តុះបណ្តាល	តាមវគ្គបណ្តុះបណ្តាល ប្រចាំត្រីមាស និងឆ្នាំ	មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទ
៣	តាមដានការអនុវត្តយុទ្ធសាស្ត្រទី៤	របាយការណ៍សម្របសម្រួល និងកំណត់ត្រាចុះមូលដ្ឋាន	ប្រចាំត្រីមាស និងឆ្នាំ	មន្ទីរអភិវឌ្ឍន៍ជនបទរាជធានី-ខេត្ត

ល.រ	ការងារតាមដាន និងវាយតម្លៃ	មធ្យោបាយផ្ទៀងផ្ទាត់លទ្ធផល	ពេលវេលា	អង្គភាពទទួលខុសត្រូវ
៤	ត្រួតពិនិត្យ និងបូកសរុបលទ្ធផលអនុវត្តផែនការប្រចាំឆ្នាំ	របាយការណ៍ប្រចាំឆ្នាំ និងរបាយការណ៍ហិរញ្ញវត្ថុ	ប្រចាំឆ្នាំ	អង្គភាពអនុវត្តតាមយុទ្ធសាស្ត្រនិមួយៗ
៥	វាយតម្លៃលទ្ធផលដំណាក់កាលទី១	របាយការណ៍អនុវត្ត ទិន្នន័យស្ទង់មតិ និងលទ្ធផលចុះផ្ទៀងផ្ទាត់	ឆ្នាំ២០២៨	អង្គភាពដែលក្រសួងចាត់តាំង
៦	វាយតម្លៃចុងផែនការ	ទិន្នន័យប្រៀបធៀបដើមគ្រានិងចុងគ្រា ផែនការ របាយការណ៍ សរុប និងលទ្ធផលស្ទង់មតិ	ឆ្នាំ២០៣៣	អង្គភាពដែលក្រសួងចាត់តាំង